

## សហភាពអឺរ៉ុប

## ប្រតិបត្តិការសង្កេតការណ៍បោះឆ្នោត

## កម្ពុជា ២០០៨

# របាយការណ៍ស្ថាពរ







# ព្រះរាជាណាចក្រកម្ពុជា

# របាយការណ៍ស្ថាពរ

## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២៧ កក្កដា ២០០៨

## ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨

**សហភាពអឺរ៉ុប**

**ប្រតិបត្តិការសង្កេតការណ៍បោះឆ្នោត**

---

*របាយការណ៍នេះត្រូវបានរៀបចំឡើងដោយ សហភាពអឺរ៉ុប-ប្រតិបត្តិការសង្កេតការណ៍បោះឆ្នោត (EU EOM) និងបង្ហាញនូវរបកគំហើញរបស់ EU EOM ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ទស្សនៈទាំងនេះមិនត្រូវបានអនុម័ត ឬផ្តល់ការយល់ព្រមដោយគណៈកម្មការសហគមន៍អឺរ៉ុបឡើយ ហើយមិនគួរត្រូវបានចាត់ទុកថាជាសេចក្តីថ្លែងការណ៍របស់គណៈកម្មការសហគមន៍អឺរ៉ុបទេ ។ គណៈកម្មការសហគមន៍អឺរ៉ុបមិនធានាចំពោះភាពត្រឹមត្រូវនៃទិន្នន័យដែលត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍នេះទេ ហើយគណៈកម្មការសហគមន៍អឺរ៉ុបក៏មិនទទួលខុសត្រូវចំពោះការប្រើប្រាស់ណាមួយនូវទិន្នន័យទាំងនេះឡើយ ។*

# មាតិកា


| | | |
|---|---|---|
| ១. | ខ្លឹមសារសង្ខេប | ១ |
| ២. | សេចក្តីផ្តើម | ៨ |
| ៣. | សាវតារនយោបាយ | ៨ |
| ៤. | បញ្ហាច្បាប់ | ១៦ |
| ៥. | រដ្ឋបាលបោះឆ្នោត | ២២ |
| ៦. | ការចុះឈ្មោះអ្នកបោះឆ្នោត | ២៨ |
| ៧. | ការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត | ៣២ |
| ៨. | យុទ្ធនាការឃោសនារកសំឡេងឆ្នោត និងបរិយាកាសនៅមុនការបោះឆ្នោត | ៣៤ |
| ៩. | ប្រព័ន្ធផ្សព្វផ្សាយ និងការបោះឆ្នោត | ៤៤ |
| ១០. | ការចូលរួមរបស់សង្គមស៊ីវិល | ៥៤ |
| ១១. | ការចូលរួមរបស់ស្ត្រី | ៥៥ |
| ១២. | ការចូលរួមរបស់ជនជាតិភាគតិច | ៥៦ |
| ១៣. | ថ្ងៃបោះឆ្នោត | ៥៧ |
| ១៤. | លទ្ធផលនៃការបោះឆ្នោត | ៦១ |
| ១៥. | អនុសាសន៍ | ៦៥ |

ឧបសម្ព័ន្ធ

ក. លទ្ធផលនៃការតាមដានប្រព័ន្ធផ្សព្វផ្សាយ

ខ. ការវិភាគទៅលើបណ្តឹងទាក់ទងនឹងយុទ្ធនាការឃោសនារកសំឡេងឆ្នោត

គ. ការវិភាគទៅលើបណ្តឹងនៅថ្ងៃបោះឆ្នោត

ឃ. ការវិភាគទៅលើបណ្តឹងទាក់ទងនឹងលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន

ង. លទ្ធផលបោះឆ្នោតផ្លូវការ

# ១. ខ្លឹមសារសង្ខេប

### *បេសកកម្មរបស់ EU EOM*

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ១២៣រូបនៃរដ្ឋសភា បានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។ តបតាមការអញ្ជើញពីរាជរដ្ឋាភិបាលកម្ពុជា សហភាពអឺរ៉ុប (EU) បានសម្រេចចិត្តបង្កើត និងបញ្ជូននូវប្រតិបត្តិការសង្កេតការណ៍បោះឆ្នោតមួយ (EU EOM) ទៅកាន់ប្រទេសកម្ពុជា ។ អាណត្តិរបស់ប្រតិបត្តិការនេះ គឺដើម្បីធ្វើការវាយតម្លៃស៊ីជម្រៅទៅលើដំណើរការនៃការបោះឆ្នោត ស្របទៅតាមគោលការណ៍អន្តរជាតិសម្រាប់ការបោះឆ្នោតដែលមានលក្ខណៈប្រជាធិបតេយ្យពិតប្រាកដ ។ ប្រធានប្រតិបត្តិការសង្កេតការណ៍បោះឆ្នោតសហភាពអឺរ៉ុប គឺលោក **ម៉ាទីន ខាឡានេន** (Martin Callanan) ជាសមាជិកសភាអឺរ៉ុប ។ EU EOM បានដាក់ពង្រាយប្រតិបត្តិការសង្កេតការណ៍អន្តរជាតិធំជាងគេបំផុត ដោយមានអ្នក-សង្កេតការណ៍ ១៣០រូបមកពីបណ្តារដ្ឋសមាជិកសហភាពអឺរ៉ុបចំនួន ២៥ និងប្រទេសន័រវេស្ស ។ EU EOM បានចុះធ្វើសង្កេតការណ៍នៅក្នុងគ្រប់ខេត្តក្រុងទាំង ២៤ នៅក្នុងប្រទេសកម្ពុជា ហើយនៅក្នុងអំឡុងពេលនៃថ្ងៃបោះឆ្នោត EU EOM ត្រូវបានចូលរួមដោយគណៈប្រតិភូមួយក្រុមដែលមានសមាជិក ៧រូប មកពីសភាអឺរ៉ុប ។

### *ការសន្និដ្ឋានទូទៅ*

ខណៈដែលយុទ្ធនាការឃោសនារកសំឡេងឆ្នោតជាទូទៅត្រូវបានធ្វើឡើងនៅក្នុងបរិយាកាសមួយ ដែលមានសន្តិភាព និងភាពបើកចំហជាងការបោះឆ្នោតនៅលើកមុនៗ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ នៅមានការខ្វះខាតខ្លះមិនទាន់ស្របតាមបទដ្ឋានអន្តរជាតិសំខាន់ៗមួយចំនួន សម្រាប់ការបោះឆ្នោតដែលមានលក្ខណៈប្រជាធិបតេយ្យនៅឡើយ ។ ទោះបីជាមានការកែលម្អនូវតម្លាភាពក៏ដោយ ក៏អ្នកដែលពាក់ព័ន្ធនឹងការបោះឆ្នោតនៅតែខ្វះទំនុកចិត្តទៅលើភាពមិនលម្អៀងរបស់រដ្ឋបាលបោះឆ្នោតដដែល ។ យុទ្ធនាការឃោសនារកសំឡេងឆ្នោត ត្រូវបានកត់សម្គាល់ដោយការប្រើប្រាស់ដ៏រាលដាលនូវធនធានរបស់រដ្ឋដោយគណបក្សគ្រប់គ្រងអំណាច ហើយការចែកលុយ និងអំណោយដោយបេក្ខជន និងមន្ត្រីគណបក្សនយោបាយត្រូវបានគេរាយការណ៍ជាទូទៅ ។

### *ក្របខ័ណ្ឌច្បាប់*

ក្របខ័ណ្ឌច្បាប់ ជាទូទៅផ្តល់នូវក្របខ័ណ្ឌមួយដែលអាចធ្វើទៅបាន ហើយជារួមមានលក្ខណៈស្របទៅតាមបទដ្ឋានអន្តរជាតិ និងបានបង្កើតនូវស្ថាប័នដែលចាំបាច់សម្រាប់ការរៀបចំការបោះឆ្នោត ។ ប៉ុន្តែ បញ្ហាសំខាន់គឺការអនុវត្តមិនបានគ្រប់ជ្រុងជ្រោយនូវបទប្បញ្ញត្តិច្បាប់ និងការខ្វះឯករាជ្យភាពរបស់ស្ថាប័នទាំងនោះ ។ ជារួម ក្របខ័ណ្ឌច្បាប់នៅតែមិនទាន់មានលក្ខណៈពេញលេញ ហើយលិខិតបទដ្ឋានជាច្រើនដែលមានកម្រិត និងប្រភេទខុសៗគ្នា បានបង្កើតនូវការភាន់ច្រលំដោយសារ

តែច្បាប់មិនបានកំណត់ច្បាស់លាស់អំពីឋានានុក្រមនៃលិខិតបទដ្ឋានទាំងនេះ ។ កង្វះនៃការបង្រួមបញ្ចូលគ្នានូវក្របខ័ណ្ឌច្បាប់បានធ្វើអោយអ្នកដែលពាក់ព័ន្ធមានការលំបាកក្នុងការទទួលបាន និងយល់ច្បាស់អំពីវិធានច្បាប់ទាំងនេះ ។

## *រដ្ឋបាលរៀបចំការបោះឆ្នោត*

បើទោះបីជា នៅខណៈពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (**គ.ជ.ប**) បានបង្ហាញពីសមត្ថភាពរបស់ខ្លួន ក្នុងការរៀបចំការបោះឆ្នោតអោយបានល្អត្រឹមត្រូវតាមបច្ចេកទេស និងបានកែលម្អនូវកម្រិតនៃតម្លាភាព ក៏កង្វះជំនឿទុកចិត្តពីសំណាក់អ្នកដែលពាក់ព័ន្ធនឹងការបោះឆ្នោត ចំពោះអព្យាក្រឹតភាព និងភាពមិនលម្អៀងរបស់ **គ.ជ.ប** និងរដ្ឋបាលបោះឆ្នោតនៅតែកើតមាន ។ ទោះបីជាមានការលើកឡើងនូវការព្រួយបារម្ភស្តីពីការខ្វះឯករាជ្យភាពរបស់មេភូមិនៅក្នុងការបោះឆ្នោតមុនៗក៏ដោយ ក៏ **គ.ជ.ប** នៅតែបន្តអនុញ្ញាតអោយមេភូមិ ចូលរួមនៅក្នុងការចែកប័ណ្ណព័តិមានអ្នកបោះឆ្នោត (VINs) ដដែល ។ ដំណើរការរៀបចំការបោះឆ្នោត និងការបោះឆ្នោតត្រូវបានរំខានដោយការចេញទម្រង់បែបបទបញ្ជាក់អត្តសញ្ញាណ ១០១៨ ។ ខណៈដែល **គ.ជ.ប** និងសមត្ថកិច្ចដែលពាក់ព័ន្ធមិនបានបង្កើតអោយមានការការពារចំពោះការចេញទម្រង់ទាំងនេះ ដំណើរការនេះបានបើកចំហអោយមានការក្លែងបន្លំ ។ ទោះបីជាមិនមានតួលេខជាក់លាក់ណាមួយក៏ដោយ ប៉ុន្តែការចេញទម្រង់ ១០១៨ ក្លែងក្លាយ គឺជាបាតុភាពមួយដ៏រាលដាល ។ មុខងាររដ្ឋបាលទាក់ទងនឹងដំណើរការបោះឆ្នោតដែលបំពេញដោយក្រុមប្រឹក្សាឃុំសង្កាត់ មិនបានឈានដល់កម្រិតនៃប្រសិទ្ធភាព និងភាពប្រកបដោយវិជ្ជាជីវៈ ដូចគ្នានឹង **គ.ជ.ប** ទេ ហើយថែមទាំងបានជះផលប៉ះពាល់អវិជ្ជមានទៅដល់ដំណើរការបោះឆ្នោតទៀតផង ។

## *ការចុះឈ្មោះអ្នកបោះឆ្នោត*

ចំនួនដ៏ច្រើននៃឈ្មោះដែលត្រូវបានលុបចេញពីបញ្ជីអ្នកបោះឆ្នោត បានក្លាយជាបញ្ហាចម្រូងចម្រាសមួយ ដោយសារតែគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិលបានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងអំពីការធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកបោះឆ្នោតនៅឆ្នាំ២០០៧ ជាពិសេសទាក់ទងនឹងចំនួនដ៏ច្រើននៃការលុបឈ្មោះចេញពីបញ្ជីអ្នកបោះឆ្នោត ។ ថ្វីបើមានការរិះគន់យ៉ាងខ្លាំងពីសំណាក់មន្ត្រីតំណាងជាន់ខ្ពស់ពីខាងគណបក្សប្រឆាំង ចំពោះភាពមិនប្រក្រតី និងកំហុសឆ្គងក្នុងបញ្ជីអ្នកបោះឆ្នោតក៏ដោយ ក៏ប៉ុន្តែគេពុំឃើញមានភស្តុតាងច្បាស់លាស់ស្តីពីការលុបឈ្មោះអ្នកគាំទ្រគណបក្សប្រឆាំងជាលក្ខណៈប្រព័ន្ធទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ ក្នុងអំឡុងថ្ងៃបោះឆ្នោត ទាំងអ្នកសង្កេតការណ៍របស់សហភាពអឺរ៉ុប (EU) និងទាំងអ្នកសង្កេតការណ៍ក្នុងស្រុកបានសង្កេតឃើញមានបណ្តឹងជាច្រើនពាក់ព័ន្ធនឹងបញ្ជីអ្នកបោះឆ្នោត ។ EU EOM សន្និដ្ឋានថា មានអ្នកបោះឆ្នោតមួយចំនួនធំត្រូវបានគេធ្វើអោយបាត់បង់សិទ្ធិក្នុងការបោះឆ្នោតដោយកំហុសឆ្គង ឬការច្រលំនៅក្នុងការបោះឆ្នោតឆ្នាំ២០០៨នេះ ។

## *ការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត*

ដំណើរការនៃការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៨ ខែមេសា រហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ដោយពុំមានបញ្ហាណាមួយដែលគួរឱ្យកត់សម្គាល់ឡើយ ។ ប៉ុន្តែ គណបក្ស

សង្គមខ្មែរនិយម (UPCP) ត្រូវបានច្រានចោលដោយ **គ.ជ.ប** ដោយសម្អាងលើមូលហេតុថា បេក្ខជនជាច្រើនដែលគណបក្សនេះបានដាក់ពង្រាយ មិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការទេ ។ ក្នុងចំណោមបេក្ខជន ២១៣នាក់ដែលត្រូវបានច្រានចោលនៅក្នុងបញ្ជីគណបក្សនយោបាយទាំងមូល បេក្ខជនជាង២០០រូប ត្រូវបានបដិសេធដោយសារតែ **គ.ជ.ប** រកឈ្មោះពួកគេមិនឃើញនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការ ។

## *រយៈពេលឃោសនារកសំឡេងឆ្នោត*

យុទ្ធនាការឃោសនារកសំឡេងឆ្នោតផ្លូវការ ជាទូទៅត្រូវបានអ្នកសង្កេតការណ៍ទាំងអស់យល់ឃើញថា មានភាពស្ងប់ស្ងៀម និងបើកចំហជាងនៅក្នុងការបោះឆ្នោតលើកមុនៗ ។ ប៉ុន្តែ ចំណាប់អារម្មណ៍ជារួមរបស់អ្នកសង្កេតការណ៍ EU EOM គឺថា គណបក្សប្រជាជនកម្ពុជា (**គ.ប.ក**) បានប្រើប្រាស់តំណែងជាអ្នកគ្រប់គ្រងអំណាចរបស់ខ្លួនដើម្បីគ្របដណ្តប់លើយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។ ទង្វើនៃការចែកលុយកាក់ និងអំណោយត្រូវបានធ្វើឡើងដោយគណបក្សភាគច្រើនបំផុត ប៉ុន្តែគណបក្សកាន់អំណាចបានចែកលុយកាក់ និងអំណោយក្នុងទ្រង់ទ្រាយធំជាងគណបក្សដទៃទៀត ។ ក្នុងអំឡុងនៃរយៈពេលឃោសនារកសំឡេងឆ្នោតផ្លូវការ គណបក្សប្រជាជនកម្ពុជាបានប្រើប្រាស់នូវប្រភេទជាច្រើននៃធនធានរបស់រដ្ឋក្នុងនោះរួមមាន ទ្រព្យសម្បត្តិ និងរថយន្តរដ្ឋ ព្រមទាំងមន្ត្រីរាជការ ។ អ្នកសង្កេតការណ៍របស់ EU ក៏បានសង្កេតឃើញផងដែរថា អាជ្ញាធរមូលដ្ឋាន និងទីស្នាក់ការគណបក្សប្រជាជន ជារឿយៗ ត្រូវបានដាក់នៅជិតគ្នា ហើយក្នុងករណីមួយចំនួនតូចថែមទាំងស្ថិតនៅក្នុងបរិវេណតែមួយជាមួយគ្នាទៀតផង ដែលធ្វើអោយគេពិបាកនឹងញែកគណបក្សនយោបាយអោយដាច់ចេញពីស្ថាប័នរដ្ឋ ។

## *ប្រព័ន្ធផ្សព្វផ្សាយ*

បរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅក្នុងអំឡុងពេលមុនការបោះឆ្នោត ត្រូវបានធ្វើអោយខូចដោយសារការបិទស្ថានីយវិទ្យុអង្គរវដ្ដា នៅខេត្តក្រចេះ ក្នុងខែឧសភា ការចាប់ និងឃុំខ្លួនលោក **ដាំ សិទ្ធិ** និពន្ធនាយកសារព័ត៌មាន *មនសិការខ្មែរ* បណ្ដោះអាសន្នពីបទបរិហារកេរ្តិ៍ នៅក្នុងខែមិថុនា និងឧប្បត្តិហេតុអាក្រក់បំផុត ៖ ការបាញ់សម្លាប់អ្នកសារព័ត៌មាន *មនសិការខ្មែរ* លោក **ឃឹម សម្បូណ៌** នាថ្ងៃទី១១ ខែកក្កដា ដែលនៅក្នុងព្រឹត្តិការណ៍វាយប្រហារនោះ កូនប្រុសរបស់លោកមួយរូបក៏បានបាត់បង់ជីវិតផងដែរ ។ គណបក្សប្រជាជនកម្ពុជា គ្របដណ្ដប់ការផ្សព្វផ្សាយអំពីការបោះឆ្នោត ដោយប្រព័ន្ធផ្សព្វផ្សាយ ដែលប៉ះពាល់ដល់គណបក្សដទៃទៀតក្នុងកម្រិតមួយ ដែលមិនសមស្របទៅនឹងបទដ្ឋានអន្តរជាតិស្ដីពីលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយសេរី និងស្មើភាពគ្នាសម្រាប់អ្នកប្រកួតប្រជែងក្នុងការបោះឆ្នោតទាំងអស់ ។ គណបក្សប្រឆាំងទាំងអស់បានទទួលលទ្ធភាពក្នុងការផ្សព្វផ្សាយនៅលើស្ថានីយទូរទស្សន៍ជាតិកម្ពុជា **ទ.ទ.ក** និងស្ថានីយវិទ្យុជាតិកម្ពុជា **វ.ជ.ក** ស្របទៅតាមច្បាប់បោះឆ្នោត ព្រមទាំងបានទទួលម៉ោងផ្សាយតាមស្ថានីយវិទ្យុឯកជនមួយចំនួនតូច ដែលមិនមានសមត្ថភាពផ្សាយទៅដល់អ្នកស្ដាប់ទូទាំងប្រទេសឡើយ ។ ការគ្របដណ្ដប់របស់គណបក្សប្រជាជនកម្ពុជាទៅលើប្រព័ន្ធផ្សព្វផ្សាយ អាចធ្វើអោយ

ប៉ះពាល់ដល់លទ្ធភាពរបស់ពលរដ្ឋខ្មែរជាអ្នកបោះឆ្នោតក្នុងការទទួលបានព័ត៌មានគ្រប់គ្រាន់អំពីគណបក្សនយោបាយទាំងឡាយ ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ។

## *ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត*

នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតបានចេញទៅបោះឆ្នោតក្នុងចំនួនដ៏ច្រើន ហើយជាទូទៅ ការបោះឆ្នោតត្រូវបានធ្វើឡើងក្នុងលក្ខណៈមួយដែលមានសណ្តាប់ធ្នាប់ល្អ និងក្នុងបរិយាកាសស្ងប់ស្ងៀម និងសន្តិភាព ។ បុគ្គលិកក្នុងស្ថានីយបោះឆ្នោតរបស់ **គ.ជ.ប** មានការប្តេជ្ញាចិត្ត មានប្រសិទ្ធភាព និងជាទូទៅ ទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ហើយបានបង្ហាញអោយឃើញថា ពួកគេមានការយល់ដឹងច្បាស់អំពីនីតិវិធីនានា ។ បញ្ហាចម្បងដែលបានកើតឡើងនៅក្នុងថ្ងៃបោះឆ្នោតគឺអ្នកបោះឆ្នោតក្នុងចំនួនមួយគួរអោយកត់សម្គាល់ ត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬអ្នកបោះឆ្នោតរកស្ថានីយបោះឆ្នោតរបស់ខ្លួនមិនឃើញ ។ បញ្ហាដ៏គួរអោយកត់សម្គាល់មួយទៀត គឺការចេញដោយខុសច្បាប់នូវបែបបទបញ្ជាក់អត្តសញ្ញាណ ឬហៅថាទម្រង់ ១០១៨ ។ វត្តមានរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងស្រុកនៅគ្រប់ទិសទី បានរួមចំណែកបង្កើតអោយមានតម្លាភាព និងការជឿទុកចិត្តទៅលើដំណើរការរៀបចំការបោះឆ្នោត ។ នីតិវិធីសម្រាប់ការរាប់សន្លឹកឆ្នោត ជាទូទៅត្រូវបានគេគោរព និងអនុវត្តតាម ។ នៅក្នុងស្ថានីយបោះឆ្នោតចំនួនស្ទើរតែពាក់កណ្តាលដែលត្រូវបានសង្កេតការណ៍ ទម្រង់កត់ត្រាលទ្ធផលរាប់សន្លឹកឆ្នោតមិនត្រូវបានបិទនៅខាងក្រៅស្ថានីយបោះឆ្នោតឡើយ ប៉ុន្តែ ភាពមិនប្រក្រតីនេះត្រូវបានវាយតម្លៃថា ជាកំហុសដោយអចេតនា ។

## *ការប្រមូល និងការបូកសរុបលទ្ធផល*

ការប្រមូល និងការបូកសរុបលទ្ធផលនៅថ្នាក់ឃុំបានធ្វើអោយបញ្ហាមួយចំនួនកាន់តែកើតមានច្រើនឡើង ។ នៅក្នុងករណីជាច្រើន កន្លែងរបស់គណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត (**គឃ/សប**) គឺរៀបចំមិនបានល្អទេ ហើយមិនគ្រប់គ្រាន់សម្រាប់ការទទួលឯកសារ ឬសម្ភារៈ និងការបូកសរុបលទ្ធផលឡើយ ។ ការរើយកសម្ភារៈ ក្នុងករណីខ្លះ មានលក្ខណៈរប៉ាត់រប៉ាយ និងខ្វះតម្លាភាព ។ ជាទូទៅ សមាជិក **គឃ/សប** មិនបានបង្ហាញនូវចំណេះដឹង និងការយល់ដឹងអំពីនីតិវិធីក្នុងកម្រិតមួយដែលគេចង់បាននោះទេ ដែលជាភស្តុតាងបញ្ជាក់អំពីការទទួលការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ និងបង្ហាញអោយឃើញច្បាស់នៅក្នុងអំឡុងនៃដំណើរការរៀបចំការបោះឆ្នោត នូវភាពខ្សោយផ្នែកធនធានមនុស្សរបស់ **គឃ/សប** ។ ទោះបីជាមានបញ្ហាអស់ទាំងនេះក៏ដោយ ក៏ **គឃ/សប** បានទំនាក់ទំនងផ្តល់ព័ត៌មានភ្លាមៗអំពីលទ្ធផលទាំងអស់ដែលរាប់រួចទៅគណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត (**គខ/កប**) ។

## ស្ត្រីនៅក្នុងការបោះឆ្នោត

នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨នេះ គេឃើញមានបេក្ខនារីឈរឈ្មោះបោះឆ្នោត និងស្ត្រីដែលបានទទួលអាសនៈនៅក្នុងរដ្ឋសភាចំនួនតិចជាងមុន ។ បេក្ខនារីឈរឈ្មោះបោះឆ្នោត និងស្ត្រីជាអ្នកនយោបាយ បានទទួលរងនូវការរើសអើងនៅក្នុងអំឡុងពេលនៃដំណើរការតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោត និងនៅក្នុងការបោះឆ្នោតផ្ទៃក្នុងរបស់គណបក្សនយោបាយ ។ ជាទូទៅ ស្ត្រីពុំមានតំណាងគ្រប់គ្រាន់នៅក្នុងស្ថាប័នរដ្ឋបាលរៀបចំការបោះឆ្នោតឡើយ ហើយកម្រនឹងកាន់មុខតំណែងធ្វើសេចក្តីសម្រេចចិត្តនៅក្នុងរដ្ឋបាលរៀបចំការបោះឆ្នោតណាស់ ប៉ុន្តែផ្ទុយទៅវិញ ពួកគេច្រើនតែកាន់មុខតំណែងផ្នែកកិច្ចការរដ្ឋបាលនៅថ្នាក់ទាបៗ ។

## ការសង្កេតការណ៍ក្នុងស្រុក

ការចូលរួមរបស់អង្គការសង្គមស៊ីវិល និងអ្នកសង្កេតការណ៍ក្នុងចំនួនដ៏ច្រើន គឺជាទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពវិជ្ជមានជាច្រើននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ហើយបានចូលរួមចំណែកដ៏គួរអោយកត់សម្គាល់ក្នុងការធានានូវតម្លាភាពនៃដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅកម្រិតស្ថានីយបោះឆ្នោត ។ អង្គការសង្គមស៊ីវិលកម្ពុជាសរុបចំនួន ៧២ ត្រូវបានផ្តល់ការទទួលស្គាល់ជាអ្នកសង្កេតការណ៍ក្នុងស្រុកដោយ **គ.ជ.ប** ។ អង្គការទាំងនេះ បានចុះបញ្ជីឈ្មោះអ្នកសង្កេតការណ៍ចំនួន ៣១.២៦២នាក់ សម្រាប់ថ្ងៃបោះឆ្នោត ។

## បណ្តឹង និងបណ្តឹងឧទ្ធរណ៍

ជារួម ដំណើរការនៃការទទួល និងដោះស្រាយបណ្តឹង និងបណ្តឹងឧទ្ធរណ៍ស្តីពីការបោះឆ្នោត មិនបានដោះស្រាយអោយបានសមស្របនូវបញ្ហាចម្បងៗទាក់ទងនឹងដំណើរការរៀបចំការបោះឆ្នោត ហើយមិនបានចូលរួមចំណែកបង្កើតអោយមានជំនឿទុកចិត្តពីសំណាក់អ្នកដែលពាក់ព័ន្ធនឹងការបោះឆ្នោត ទៅលើដំណើរការនេះឡើយ ។ ការដោះស្រាយបណ្តឹង និងបណ្តឹងឧទ្ធរណ៍ដែលទាក់ទងនឹងថ្ងៃបោះឆ្នោត មិនបានត្រឹមត្រូវស្របទៅតាមបទដ្ឋានអន្តរជាតិឡើយ ដោយសារតែស្ថាប័នទាំងនេះមិនបានផ្តល់ដំណោះស្រាយដែលមានប្រសិទ្ធភាព ។ ដូច្នេះ ប្រទេសកម្ពុជាបានរំលោភលើកាតព្វកិច្ចរបស់ខ្លួនក្នុងការធានានូវសិទ្ធិក្នុងការទទួលបានដំណោះស្រាយផ្លូវច្បាប់ដែលមានប្រសិទ្ធភាព[១] ។

---

[១] បទដ្ឋានអន្តរជាតិ : សិទ្ធិក្នុងការទទួលបានដំណោះស្រាយដែលមានប្រសិទ្ធភាព : "ភាគីរដ្ឋនីមួយៗសន្យានឹង : ធានាថា មនុស្សណាម្នាក់ដែលសិទ្ធិ ឬសេរីភាពរបស់ខ្លួនត្រូវបានរំលោភបំពាន នឹងត្រូវមានដំណោះស្រាយដែលមានប្រសិទ្ធភាព ទោះបីជាការរំលោភនោះត្រូវបានប្រព្រឹត្តដោយបុគ្គលដែលធ្វើសកម្មភាពក្នុងមុខតំណែងផ្លូវការក៏ដោយ" cf. ICCPR មាត្រា ២(៣)(ក) និង(គ) ។

***អនុសាសន៍សំខាន់ៗ***

នៅមុនការបោះឆ្នោតនាពេលអនាគត ក្របខ័ណ្ឌបោះឆ្នោតត្រូវការចាំបាច់នូវការកែទម្រង់ ដើម្បីអោយស្របទៅនឹងបទដ្ឋានអន្តរជាតិសម្រាប់ការបោះឆ្នោតដែលមានលក្ខណៈប្រជាធិបតេយ្យ ។ ដើម្បីជាការរួមចំណែកនៅក្នុងដំណើរការនេះ កម្រងនៃអនុសាសន៍សំខាន់ៗលម្អិតត្រូវបានដាក់បញ្ចូលនៅខាងចុងបញ្ចប់នៃរបាយការណ៍នេះ ។ អនុសាសន៍សំខាន់ៗ រួមមាន :

- រាជរដ្ឋាភិបាលកម្ពុជាត្រូវតែចាត់វិធានការដែលអាចជឿទុកចិត្តបានដើម្បីធានាថា **គ.ជ.ប.** ធ្វើការជាស្ថាប័នមួយដែលមានឯករាជ្យភាពពេញលេញនៅគ្រប់កម្រិត ដើម្បីលើកកម្ពស់ជំនឿទុកចិត្ត និងការទទួលយក នៅក្នុងចំណោមអ្នកបោះឆ្នោត ។ សមាជិករបស់ **គ.ជ.ប** គួរតែបានទទួលការយល់ព្រមមូលមតិ (កុងសង់ស៊ុស) ក្នុងចំណោមគណបក្សនយោបាយទាំងអស់ដែលមានអាសនៈនៅក្នុងរដ្ឋសភា ។ ជាពិសេស ប្រធាន **គ.ជ.ប** គួរតែជាមនុស្សម្នាក់ ដែលអាចទទួលយកបានចំពោះគ្រប់គណបក្សនយោបាយទាំងអស់ដែលមានអាសនៈនៅក្នុងរដ្ឋសភា ។ ការកំណត់អាណត្តិនៃការកាន់មុខតំណែងរបស់ប្រធាន និងសមាជិក **គ.ជ.ប** គួរតែធ្វើការពិចារណា ។
- ប្រព័ន្ធច្បាប់ និងក្របខ័ណ្ឌត្រួតពិនិត្យ ជាពិសេសបទប្បញ្ញត្តិ និងនីតិវិធីរបស់ **គ.ជ.ប** គួរតែធ្វើអោយមានភាពងាយស្រួល និងបង្រួមបញ្ចូលគ្នា ដើម្បីលុបបំបាត់ចំណុចមិនស្របគ្នា ភាពមិនច្បាស់លាស់ ការជាន់គ្នា និងចំណុចខ្វះចន្លោះ ។ បទបញ្ជាដែលអនុម័តដោយ **គ.ជ.ប** គួរតែដាក់បញ្ចូលអោយបានច្រើនតាមដែលអាចធ្វើទៅបាន ទៅក្នុងបទប្បញ្ញត្តិ និងនីតិវិធីទាំងនេះ ។
- ការប្រើប្រាស់ទម្រង់ ១០១៨ គួរតែលុបចោលនៅមុនការបោះឆ្នោតណាមួយនាពេលអនាគត ។
- ក្រសួងមហាផ្ទៃគួរតែបង្កើនល្បឿននៃការចែកអត្តសញ្ញាណប័ណ្ណ និងកែលម្អការត្រួតពិនិត្យដំណើរការនេះ ។ ក្នុងករណីដែលអ្នកបោះឆ្នោតមិនមានអត្តសញ្ញាណប័ណ្ណ ឬឯកសារសម្គាល់ខ្លួនដទៃទៀត អាជ្ញាធររដ្ឋអំណាចគួរស្វែងរកដំណោះស្រាយជំនួសមួយ ដើម្បីផ្តល់លទ្ធភាពដល់អ្នកបោះឆ្នោតក្នុងការប្រាប់អំពីអត្តសញ្ញាណរបស់ខ្លួននៅថ្ងៃបោះឆ្នោត ។ ទោះបីជាមានដំណោះស្រាយយ៉ាងណាក៏ដោយ ឯកសាររបស់អ្នកបោះឆ្នោត ដែលប្រើប្រាស់អត្តសញ្ញាណជំនួស គួរតែរក្សាទុកជាការការពារ និងជាព័ត៌មានដើម្បីគាំទ្រការកែលម្អបន្ថែមទៅលើប្រព័ន្ធបោះឆ្នោតនៅកម្ពុជា ។
- មេភូមិមិនគួរត្រូវបានអនុញ្ញាតអោយដើរតួនាទីចម្បង នៅក្នុងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតឡើយ ។ **គ.ជ.ប** គួរស្វែងរកវិធីនៃការចែកប័ណ្ណព័ត៌មានផ្សេងពីនេះ ដែលអាចកើតឡើង ជាមួយនឹងវត្តមានរបស់ភ្នាក់ងារគណបក្ស និងសមាជិក **គឃ/សប** ។
- បរិយាកាសប្រព័ន្ធផ្សព្វផ្សាយសេរី គឺជាកត្តាដ៏ចាំបាច់បំផុតក្នុងការធានាថា កិច្ចប្រឹងប្រែងរបស់ប្រទេសកម្ពុជាដើម្បីដោះស្រាយបញ្ហាពុករលួយ និងការពារសិទ្ធិមនុស្សជាមូលដ្ឋាន នឹងទទួលបានជោគជ័យ ។ រាជរដ្ឋាភិបាលត្រូវតែបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីធានានូវបរិយាកាសប្រព័ន្ធផ្សព្វផ្សាយសេរី តាមរយៈការបង្កើតនូវ

អាជ្ញាធរត្រួតពិនិត្យការផ្សាយឯករាជ្យមួយ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណ និងរលកអាកាសដល់ប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ដោយឈរលើមូលដ្ឋានបើកចំហ និងមានតម្លាភាព ។

- រាជរដ្ឋាភិបាលកម្ពុជា និង **គ.ជ.ប** គួរតែចាប់ផ្តើមដំណើរការពិគ្រោះយោបល់មួយដើម្បីរិះរកជម្រើសសម្រាប់ការធ្វើអោយមានភាពងាយស្រួល និងការកែលម្អនីតិវិធីចុះឈ្មោះអ្នកបោះឆ្នោត។ គួរតែមានការចូលរួមបន្ថែមទៀតរបស់បុគ្គលិក **គ.ជ.ប** នៅក្នុងអំឡុងពេលនៃការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ និងរយៈពេលនៃការចុះឈ្មោះ ។ មូលហេតុសម្រាប់ការលុបឈ្មោះរបស់អ្នកបោះឆ្នោត គួរតែចុះជាឯកសារអោយបានត្រឹមត្រូវ ។
- ស្ថាប័នរដ្ឋាភិបាល ក្នុងនោះរាប់ទាំង **គ.ជ.ប** និងអង្គការសង្គមស៊ីវិល គួរតែផ្តល់អាទិភាពចំពោះគំនិតផ្តួចផ្តើមសម្រាប់ការអប់រំពលរដ្ឋដែលមានលក្ខណៈទូលំទូលាយ និងដែលកំណត់គោលដៅច្បាស់លាស់ ដោយពិចារណាទៅលើអត្រាអក្ខរកម្មទាបនៅក្នុងប្រទេសកម្ពុជា ។ គំនិតផ្តួចផ្តើមបែបនេះ អាចដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាដែលផ្តល់ដោយគ្រឹះស្ថានអប់រំរដ្ឋ និងឯកជននៅគ្រប់កម្រិត ។

EU EOM ជំរុញអោយអាជ្ញាធរ គណបក្សនយោបាយ និងសង្គមស៊ីវិលរបស់ប្រទេសកម្ពុជា ចាប់ផ្តើមអនុវត្តជំហានទាំងនេះ និងជំហានដែលចាំបាច់ផ្សេងទៀតជាបន្ទាន់ ដើម្បីធានាថា ការរៀបចំការបោះឆ្នោតនាពេលអនាគត អាចប្រព្រឹត្តទៅស្របទៅតាមបទដ្ឋានអន្តរជាតិសម្រាប់ការបោះឆ្នោតដែលមានលក្ខណៈប្រជាធិបតេយ្យ ។

## ២. សេចក្តីផ្តើម

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ១២៣រូបនៃរដ្ឋសភា បានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។ តបការអញ្ជើញពីរាជរដ្ឋាភិបាលកម្ពុជា សហភាពអឺរ៉ុប (EU) បានសម្រេចចិត្តបង្កើត និងបញ្ជូននូវប្រតិបត្តិការសង្កេតការណ៍បោះឆ្នោតមួយ (EU EOM) ទៅកាន់ប្រទេសកម្ពុជា ។ EU EOM ឯករាជ្យចេញពីរដ្ឋសមាជិកសហភាពអឺរ៉ុប សភាអឺរ៉ុប និងគណៈកម្មការសហគមន៍អឺរ៉ុប នៅក្នុងរបាយការណ៍ស្តីពីរបកគំហើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន ។ អាណត្តិរបស់ EU EOM គឺធ្វើការវាយតម្លៃស៊ីជម្រៅទៅលើដំណើរការនៃការបោះឆ្នោត យោងទៅតាមគោលការណ៍អន្តរជាតិសម្រាប់ការបោះឆ្នោតដែលមានលក្ខណៈប្រជាធិបតេយ្យពិតប្រាកដ[២] ។ ប្រធានប្រតិបត្តិការសង្កេតការណ៍បោះឆ្នោតរបស់សហភាពអឺរ៉ុប គឺលោក **ម៉ាទីន ខាឡានេន** (Martin Callanan) ជាសមាជិកសភាអឺរ៉ុប ។

ប្រតិបត្តិការ EU EOM ត្រូវបានដាក់ពង្រាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៨ ។ ទីស្នាក់ការកណ្តាលរបស់ប្រតិបត្តិការនេះ ស្ថិតនៅទីក្រុងភ្នំពេញ ហើយប្រតិបត្តិការនេះបានធ្វើការសង្កេតការណ៍នៅក្នុងខេត្តក្រុងទាំង២៤ នៅទូទាំងប្រទេសកម្ពុជា ។ EU EOM បានដាក់ពង្រាយប្រតិបត្តិការសង្កេតការណ៍អន្តរជាតិធំជាងគេបំផុត ដោយមានអ្នកសង្កេតការណ៍១៣០រូបមកពីបណ្តារដ្ឋសមាជិកសហភាពអឺរ៉ុបចំនួន ២៥ និងប្រទេសន័រវេស៊្ស ។ EU EOM ត្រូវបានចូលរួមដោយគណៈប្រតិភូមួយក្រុមមានសមាជិក៧រូបមកពីសភាអឺរ៉ុប ដែលដឹកនាំដោយសមាជិកសភាអឺរ៉ុប **Glyn Ford** ។ នៅថ្ងៃបោះឆ្នោត អ្នកសង្កេតការណ៍បានចុះទៅកាន់ស្ថានីយបោះឆ្នោតចំនួន ៧១៩ នៅក្នុងមណ្ឌលបោះឆ្នោតទាំង២៤ខេត្តក្រុង ដើម្បីសង្កេតការណ៍បោះឆ្នោត ។ ពួកគេឈរជើងនៅទូទាំងប្រទេសក្នុងអំឡុងពេលនៃការរាប់ ការផ្ទៀងផ្ទាត់ និងការធ្វើសវនាការលើពាក្យបណ្តឹងនៅថ្នាក់ក្រោម ។ EU EOM បានចេញផ្សាយសេចក្តីថ្លែងការណ៍របស់ខ្លួនស្តីពីរបកគំហើញ និងសេចក្តីសន្និដ្ឋានបឋមរបស់ខ្លួន នៅថ្ងៃទី២៩ កក្កដា ២០០៨[៣] ។ EU EOM បានបិទប្រតិបត្តិការរបស់ខ្លួននៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ។

EU EOM សូមសម្តែងនូវអំណរគុណចំពោះកិច្ចសហប្រតិបត្តិការ និងជំនួយដែលខ្លួនបានទទួលនៅក្នុងអំឡុងពេលនៃការបំពេញការងាររបស់ខ្លួនពីសំណាក់ : ក្រសួងការបរទេស គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណបក្សនយោបាយ អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ ប្រតិភូគណៈកម្មការសហគមន៍អឺរ៉ុបប្រចាំកម្ពុជា និងតំណាងនៃរដ្ឋសមាជិកសហភាពអឺរ៉ុប និងស្ថានទូតដទៃទៀត ។

## ៣. សាវតារនយោបាយ

### ក. ស្ថាប័នដែលជ្រើសតាំងដោយការបោះឆ្នោត

[២] សូមមើល "សេចក្តីប្រកាសស្តីពីគោលការណ៍សម្រាប់ការសង្កេតការណ៍បោះឆ្នោតអន្តរជាតិ" ដែលថ្លែងនៅឯអង្គការសហប្រជាជាតិ នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ : http://europa.eu.int/comm/external_relations/human_rights/eu_election_ass_observ/docs/code_conduct_en.pdf.

[៣] សូមមើលគេហទំព័ររបស់ EU EOM (www.eueomcambodia.org) និងគេហទំព័រស្តីពីការសង្កេតការណ៍បោះឆ្នោតរបស់គណៈកម្មការសហគមន៍អឺរ៉ុប (http://ec.europa.eu/comm/external_relations/human_rights/eu_election_ass_observ/index.htm) ។

ប្រទេសកម្ពុជាប្រកាន់យកនូវរបបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញពហុបក្ស[៤] ជាមួយនឹងអង្គនីតិប្បញ្ញត្តិចំនួន២ គឺរដ្ឋសភា និងព្រឹទ្ធសភា[៥] ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ គឺជាការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើកទី៤ ចាប់តាំងពីការបោះឆ្នោតលើកទី១ នាឆ្នាំ១៩៩៣ ដែលរៀបចំដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា (**អ៊ុនតាក់**) មក ។ ចាប់តាំងពីឆ្នាំ១៩៩៣មក ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវបានរៀបចំធ្វើឡើងនៅរៀងរាល់៥ឆ្នាំម្តង ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានធ្វើឡើងចំនួនពីរលើក ដោយលើកទីមួយនៅក្នុងឆ្នាំ២០០២ និងលើកទីពីរនៅក្នុងឆ្នាំ២០០៧ ។ រដ្ឋសភាមានអាសនៈចំនួន ១២៣ ដែលជ្រើសតាំងពីមណ្ឌលបោះឆ្នោតទាំង ២៤ (ខេត្តចំនួនម្ភៃ និង ក្រុងចំនួនបួន)[៦] ដែលក្នុងនោះ ១៥មណ្ឌល ជាមណ្ឌលដែលមានអាសនៈច្រើន និង ប្រាំបួនមណ្ឌល ជាមណ្ឌលដែលមានអាសនៈតែមួយ ។

## ខ. បរិបទនយោបាយ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធានាចំពោះសេរីភាពបុគ្គលជាមូលដ្ឋានមួយចំនួន ។ ខណៈដែលប្រទេសកម្ពុជាមានស្ថិរភាពនយោបាយទូទៅដែលបានជួយសម្រួលដល់ការស្តារបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងកំណើនសេដ្ឋកិច្ច របាយ-ការណ៍ជាច្រើនអះអាងថា ការធានាដោយរដ្ឋធម្មនុញ្ញត្រូវបានប្រឈមដោយការអនុវត្តច្បាប់នៅខ្សោយ និន្នាការឆ្ពោះទៅរកអតុល្យភាពដែលកើនឡើងរវាងអំណាចប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ ព្រមទាំងកង្វះនូវការញែកអោយដាច់ពីគ្នាអោយបានច្បាស់លាស់នូវអំណាចទាំងបីនេះ ។ ជាងនេះទៅទៀត ទោះបីជាមានកិច្ចប្រឹងប្រែងជាច្រើនផ្តោតទៅលើកំណែទម្រង់វិស័យសន្តិសុខក្តី ប្រទេសកម្ពុជានៅតែបន្តមានកងកម្លាំងយោធា និងកងរាជអាវុធហត្ថច្រើនដដែល ។

បើទោះបីជាមានស្ថិរភាព និងអត្រាកំណើនសេដ្ឋកិច្ចគួរអោយកត់សម្គាល់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្តី អនាគតនយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក៏ត្រូវបានកំណត់ផងដែរដោយកត្តាមួយចំនួន ដូចជា កម្រិតនៃភាពក្រីក្រខ្ពស់[៧] និងគម្លាតប្រាក់ចំណូលដែលកាន់តែរីកធំឡើង កម្រិតអក្ខរកម្មទាប និងអត្រាបញ្ចប់កម្រិតអប់រំថ្នាក់បឋមសិក្សាទាប

[៤] ព្រះមហាក្សត្រគឺជាប្រមុខរដ្ឋ ប៉ុន្តែតំណែងនេះមិនមានសិទ្ធិអំណាចនយោបាយឡើយ ។ ព្រះមហាក្សត្របច្ចុប្បន្ន សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ឡើងសោយរាជ្យជំនួសអតីតព្រះមហាក្សត្រសម្តេចព្រះបាទ **នរោត្តម សីហនុ** នៅក្នុងខែតុលា ឆ្នាំ២០០៤ នៅពេលដែលព្រះអង្គដាក់រាជ្យដោយមិនបានគ្រោងទុកដោយសារមូលហេតុសុខភាព ។

[៥] សមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតជ្រើសតាំងដោយប្រយោល ។ សមាជិកព្រឹទ្ធសភា ២រូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ ២រូបដោយរដ្ឋសភា ហើយសមាជិកក្រៅពីនោះ ត្រូវបានបោះឆ្នោតជ្រើសតាំងដោយសមាជិករដ្ឋសភា និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ។ ការបោះឆ្នោតបែបនេះលើកដំបូងបង្អស់ ប្រព្រឹត្តទៅនៅខែមករា ឆ្នាំ២០០៦ (មាត្រា ១០០ នៃរដ្ឋធម្មនុញ្ញ) ។

[៦] ការបែងចែកអាសនៈនៅតាមមណ្ឌលបោះឆ្នោត គឺមានដូចតទៅ : មណ្ឌលខេត្តកំពង់ចាម មាន ១៨អាសនៈ, មណ្ឌលភ្នំពេញ មាន ១២អាសនៈ, មណ្ឌលខេត្តកណ្តាល មណ្ឌលខេត្តព្រៃវែង មាន ១១អាសនៈ, មណ្ឌលខេត្តបាត់ដំបង មណ្ឌលខេត្តតាកែវ មាន ៨អាសនៈ, មណ្ឌលខេត្តបន្ទាយមានជ័យ មណ្ឌលខេត្តកំពត មណ្ឌលខេត្តកំពង់ស្ពឺ មណ្ឌលខេត្តកំពង់ធំ មណ្ឌលខេត្តសៀមរាប មាន ៦អាសនៈ, មណ្ឌលខេត្តស្វាយរៀង មាន ៥អាសនៈ, មណ្ឌលខេត្តកំពង់ឆ្នាំង មណ្ឌលខេត្តពោធិ៍សាត់ មាន ៤អាសនៈ, មណ្ឌលខេត្តក្រចេះ មាន ៣អាសនៈ និងមណ្ឌលទាំង ៩ទៀតនេះ ជាមណ្ឌលដែលមានអាសនៈតែមួយៗប៉ុណ្ណោះ : មណ្ឌលខេត្តកោះកុង, មណ្ឌលខេត្តមណ្ឌលគិរី, មណ្ឌលខេត្តព្រះវិហារ, មណ្ឌលខេត្តរតនគិរី, មណ្ឌលខេត្តស្ទឹងត្រែង, មណ្ឌលក្រុងព្រះសីហនុ, មណ្ឌលក្រុងកែប, មណ្ឌលខេត្តឧត្តរមានជ័យ, មណ្ឌលក្រុងប៉ៃលិន ។

[៧] កម្ពុជាត្រូវបានចាត់ចំណាត់ថ្នាក់លេខ ១៣១ ក្នុងចំណោម ១៧៧ នៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់អង្គការ UNDP ប្រចាំឆ្នាំ២០០៧/២០០៨ និងមានផលទុនក្នុងស្រុកសរុប ក្នុងមនុស្សម្នាក់ឡើងដល់ ៥១៣ ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០០៦ ។

វិសមភាពយេនឌ័រ អតិផរណា[៨] ព្រមទាំងជម្លោះព្រំដែនជាមួយប្រទេសវៀតណាម និងប្រទេសថៃ ។ លើសពីនេះទៅទៀត ការរំពឹងចង់បានថា ប្រទេសកម្ពុជាថ្មីនឹងដោះស្រាយបញ្ហាអំពើពុករលួយ[៩] បញ្ហាដីធ្លី/អចលនទ្រព្យ ព្រមទាំងកើ្តឈ្មោះផ្នែកសិទ្ធិមនុស្សមិនល្អ មិនទាន់បំពេញបាននៅឡើយ ។ ទោះបីជាកិច្ចព្រមព្រៀងសន្តិភាពជាផ្លូវការមួយត្រូវបានចុះហត្ថលេខាកាលពី១៧ឆ្នាំមុនក្តី ជម្លោះកាលពីអតីតកាលនៅតែជារឿងបច្ចុប្បន្នកាលនៅក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាបច្ចុប្បន្ននៅឡើយ ដោយពលរដ្ឋភាគច្រើនអះអាងថាបានទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត ឯកសារស្តីពីរបបខ្មែរក្រហម និងសម័យកាលនៃការកាន់កាប់ប្រទេសកម្ពុជាដោយប្រទេសវៀតណាម សេចក្តីថ្លែងការណ៍នយោបាយនៅមានការយោងជាទៀងទាត់ទៅរកជម្លោះកាលពីអតីតកាល និងដំណើរការកាត់ក្តីរបស់សាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ត្រូវបានតាមដានប្រកបដោយការយកចិត្តទុកដាក់ពីសំណាក់ពលរដ្ឋកម្ពុជាជាច្រើន ។

## *ប្រវត្តិសាស្ត្រនយោបាយថ្មីៗ ១៩៥៣-២០០៣*

ក្រោយពេលស្ថិតក្រោមអាណាព្យាបាលរបស់បារាំងអស់រយៈពេល ៩០ឆ្នាំ ប្រទេសកម្ពុជាបានទទួលឯករាជ្យនៅក្នុងឆ្នាំ១៩៥៣ ។ ទោះបីជាប្រទេសកម្ពុជាបានជួបប្រទះនូវកំណើនសេដ្ឋកិច្ច និងការរីកចម្រើននៅក្នុងអំឡុងទសវត្សរ៍ទី១ នៃការទទួលបានឯករាជ្យនៅក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះបាទ **នរោត្តម សីហនុ** ក៏ដោយ ក៏ប៉ុន្តែ ប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសកម្ពុជា ត្រូវបានកត់សម្គាល់ដោយភាពច្របូកច្របល់ផ្នែកនយោបាយ និងជម្លោះអស់រយៈពេលជិត ៤០ឆ្នាំ ។ កិច្ចប្រឹងប្រែងរបស់ប្រទេសកម្ពុជានៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និងដើមទសវត្សរ៍ឆ្នាំ១៩៧០ ដើម្បីប្រកាន់យកផ្លូវអព្យាក្រឹតត្រូវបានខូចអន្តរាយដោយសារឥទ្ធិពលនៃការតស៊ូដណ្តើមអំណាចនៅក្នុងតំបន់ និងនៅថ្នាក់ពិភពលោក និងការបែកខ្ញែកបន្តិចម្តងៗនូវនយោបាយក្នុងប្រទេស ។

សញ្ញាដំបូងៗនៃភាពចលាចលបានកើតឡើងនៅក្នុងឆ្នាំ១៩៧០ នៅពេលដែលឧត្តមសេនីយ៍យោធា (សេនាប្រមុខ) **លន់ នល់** បានធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គម្ចាស់ **សីហនុ** លុបចោលនូវរបបរាជានិយម និងឡើងកាន់អំណាចបន្ត ។ នៅពេលដែលសង្គ្រាមវៀតណាមបានរាលដាលចូលដល់ក្នុងទឹកដីកម្ពុជា ក្រុមបះបោរខ្មែរក្រហមបានពង្រីកការវាយប្រហារទ្រង់ទ្រាយតូចៗរបស់ពួកគេ និងកាន់កាប់តំបន់ជនបទ ដោយកាត់បន្ថយការគ្រប់គ្រងរបស់របប **លន់ នល់** មកនៅត្រឹមតែខ្សែក្រវ៉ាត់តូចៗនៅជុំវិញទីក្រុង និងផ្លូវដឹកជញ្ជូនសំខាន់ៗប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៤ ប្រជាពលរដ្ឋកម្ពុជាប្រមាណ ២លាននាក់ បានស្វែងរកការការពារនៅក្នុងទីក្រុងភ្នំពេញ និងនៅទីក្រុងធំៗដទៃទៀត ។ នៅក្រោយការបើកយុទ្ធនាការវាយប្រហារជាយុទ្ធសាស្ត្រខ្មែរក្រហមបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ រយៈពេល ៤ឆ្នាំបន្ទាប់មកទៀតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម បានក្លាយទៅជាទំព័រដ៏ខ្មៅងងឹតបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដោយ

---

[៨] អត្រាអតិផរណាមាន ១៨,៧% ក្នុងរយៈពេលពីខែមករា ២០០៧ ដល់ខែមករា ២០០៨ យោងតាមស្ថិតិដែលចេញដោយក្រសួងផែនការ ។

[៩] សន្ទស្សន៍ការយល់ឃើញអំពីអំពើពុករលួយឆ្នាំ២០០៧ របស់អង្គការតម្លាភាពអន្តរជាតិ (Transparency International) បានដាក់ប្រទេសកម្ពុជានៅលេខទី ១៦២ ក្នុងចំណោមប្រទេសចំនួន ១៨០ ប្រៀបធៀបជាមួយប្រទេសវៀតណាម ដែលស្ថិតនៅលេខទី ១២៣, ប្រទេសឡាវ នៅលេខទី ១៦៨ និងប្រទេសថៃ នៅលេខទី៨៤ ។ នៅក្នុងរបាយការណ៍ឆ្នាំ២០០៨ ដែលចេញផ្សាយកាលពីខែកញ្ញា ឆ្នាំ២០០៨ ប្រទេសកម្ពុជាបានធ្លាក់ចុះចំនួន ៤លេខ ដែលបង្ហាញពីភាពកាន់តែធ្ងន់ធ្ងរថែមទៀតនៃបញ្ហាអំពើពុករលួយ ។

របបនេះបានប្រែក្លាយកម្ពុជាទៅជាវាលពិឃាត ដែលកត់សម្គាល់ដោយអំពើប្រល័យពូជសាសន៍ ការអត់ឃ្លាន និងការបំផ្លាញចោលទាំងស្រុងនូវរចនាសម្ព័ន្ធនយោបាយ សេដ្ឋកិច្ច រដ្ឋបាល និងសង្គម ព្រមទាំងភាពឯកោផ្នែកនយោបាយ ។ នៅក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលលុកលុយប្រទេសកម្ពុជា និងបានវាយបណ្តេញរបបខ្មែរក្រហមចេញពីរាជធានីភ្នំពេញ ។ រដ្ឋាភិបាលអន្តរកាលមួយ ដែលមានការគាំទ្រពីសំណាក់ប្រទេសវៀតណាមបានបន្តប្រយុទ្ធជាមួយកងទ័ពព្រៃខ្មែរក្រហម និងកងទ័ពខ្មែរក្រុមផ្សេងៗទៀតដែលប្រឆាំងនឹងវត្តមានរបស់វៀតណាម ។ ប្រទេសវៀតណាមបានដកកងទ័ពចេញពីកម្ពុជានៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ ហើយការចរចាដើម្បីកិច្ចព្រមព្រៀងសន្តិភាពមួយបានចាប់ផ្តើមឡើង ហើយដោយមានការជួយជ្រោមជ្រែងខ្លាំងក្លាពីសំណាក់អន្តរជាតិ ការចរចាទាំងនោះក៏បានឈានទៅដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាខែតុលា ឆ្នាំ១៩៩១ ។ កិច្ចព្រមព្រៀងនេះ បានផ្តល់អាណត្តិសម្រាប់ការបើកប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (**អ៊ុនតាក់**) ដើម្បីត្រួតត្រាការឈប់បាញ់ ធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួនខ្មែរប្រហែល ៣៧០.០០០នាក់ពីប្រទេសថៃ ដកហូតអាវុធ និងកាត់រំសាយក្រុមប្រដាប់អាវុធ ព្រមទាំងត្រៀមលក្ខណៈប្រទេសកម្ពុជាដើម្បីការបោះឆ្នោតដែលមានលក្ខណៈប្រជាធិបតេយ្យ ។ សភាធម្មនុញ្ញលើកដំបូង ក៏ត្រូវបានចាត់អោយធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មីសម្រាប់ប្រទេសកម្ពុជា ។

ការបោះឆ្នោតនាឆ្នាំ១៩៩៣ ត្រូវបានកត់សម្គាល់ដោយអំពើហិង្សាកម្រិតខ្ពស់ ប៉ុន្តែត្រូវបានអបអរសាទរជាទូទៅថាជាជំហានដំបូងរបស់ប្រទេសកម្ពុជាឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ស្ថិរភាព និងការស្តាបនាឡើងវិញនូវប្រទេសដែលក្រីក្រ និងទទួលរងការបំផ្លិចបំផ្លាញមួយនេះ ។ ទោះបីជាគណបក្សរណសិរ្សរួបរួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការ (**ហ៊្វុនស៊ិនប៉ិច**) ដែលមាននិន្នាការរាជានិយម ត្រូវបានប្រកាសថាជាអ្នកឈ្នះក្នុងការបោះឆ្នោតនាឆ្នាំ១៩៩៣ក៏ដោយ ក៏ប៉ុន្តែលោក **ហ៊ុន សែន** ជាមេដឹកនាំដែលកាន់តំណែងដ៏យូរនៅក្នុងរដ្ឋាភិបាលអន្តរកាលដែលគាំទ្រដោយវៀតណាម និងជាមេដឹកនាំថ្នាក់មជ្ឈឹមនៃគណបក្សប្រជាជនកម្ពុជា (**គ.ប.ក**) បានចរចាបង្កើតនូវរដ្ឋាភិបាលចម្រុះមួយ ដែលដឹកនាំរួមគ្នាដោយប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ព្រះអង្គម្ចាស់ **នរោត្តម រណឫទ្ធិ** ជានាយករដ្ឋមន្ត្រីទី១ និងខ្លួនលោកជានាយករដ្ឋមន្ត្រីទី២ ។ នេះគឺជាចំណុចចាប់ផ្តើមនៃសម្ព័ន្ធភាពដ៏ផុយស្រួយមួយ ដែលជានិច្ចកាលគណបក្សប្រជាជនកម្ពុជាតែងតែដើរតួនាទីគ្របដណ្តប់ ។

## *សាវតារនយោបាយពីឆ្នាំ១៩៩៣-២០០៣*

រដ្ឋាភិបាលចម្រុះបានជួបប្រទះនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរមួយចំនួន ទាក់ទងនឹងការស្តាបនាប្រទេសឡើងវិញ ការកាត់បន្ថយកម្លាំងបះបោរខ្មែរក្រហម[១០] និងការខ្វែងគំនិតផ្ទៃក្នុងអំពីខ្សែបន្ទាត់នយោបាយ ។ ឧប្បត្តិហេតុនយោបាយជាច្រើន បានបញ្ជាក់សញ្ញាថា បើទោះបីជាមានការប្តេជ្ញាចិត្តក្នុងការផ្លាស់ប្តូរទៅរកលទ្ធិប្រជាធិបតេយ្យក៏ដោយ ក៏នយោបាយកម្ពុជានឹងនៅតែបន្តក្លាយជាបញ្ហាជម្លោះដដែល ។ ខណៈពេលដែលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៨ បានខិតជិតមកដល់ សម្ព័ន្ធភាពរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចបានចុះទន់ខ្សោយ ហើយនៅដើមឆ្នាំ១៩៩៧ រដ្ឋាភិបាលចម្រុះបានចាប់ផ្តើមបែកបាក់ ជាមួយនឹងការប្រយុទ្ធគ្នារវាងគណបក្សគ្រប់គ្រងអំណាចដែលបានបណ្តាលអោយឈានទៅដល់

[១០] រដ្ឋាភិបាលបានបន្តបង្ក្រាបកម្លាំងបះបោរ ហើយដោយសារតែមានការបែកបាក់ផ្ទៃក្នុងរវាងមេដឹកនាំខ្មែរក្រហមដែលនៅសេសសល់ ចលនាតស៊ូរបស់ខ្មែរក្រហម ត្រូវបានបញ្ចប់នៅក្នុងឆ្នាំ១៩៩៨ ។

អ្វីដែលគេហៅថា "រដ្ឋប្រហារឆ្នាំ១៩៩៧"[១១] ។ នៅក្រោយព្រឹត្តិការណ៍នេះ គណបក្សហ៊្វុនស៊ិនប៉ិចដែលត្រូវបានធ្វើអោយចុះខ្សោយបានចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោត ដែលជាលទ្ធផល គណបក្សប្រជាជនកម្ពុជាបានលេចឡើងជាគណបក្សធំជាងគេបំផុត ដោយទទួលបានសំឡេងឆ្នោតគាំទ្រ ៤១,៤% ប៉ុន្តែខ្វះសំឡេង ២ភាគ៣ដើម្បីបង្កើតរដ្ឋាភិបាលតាមការតម្រូវដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ គណបក្សហ៊្វុនស៊ិនប៉ិច ដំបូងឡើយបានប្រកាសបដិសេធលទ្ធផលនៃការបោះឆ្នោតនោះ ប៉ុន្តែក្រោយមកបានយល់ព្រមចូលរួមក្នុងរដ្ឋាភិបាលចម្រុះលើកទី២ជាមួយគណបក្សប្រជាជនកម្ពុជា ដោយទទួលយកតួនាទីដែលមានឥទ្ធិពលតិចជាងមុន ។ ភាពលុបលើគេរបស់គណបក្សប្រជាជនកម្ពុជានៅក្នុងនយោបាយរបស់ប្រទេសកម្ពុជាត្រូវបានពង្រឹងបន្ថែមនៅក្នុងការបោះឆ្នោតថ្នាក់មូលដ្ឋានលើកដំបូងបង្អស់ដែលប្រព្រឹត្តទៅនៅក្នុងឆ្នាំ២០០២ ហើយដែលនៅក្នុងការបោះឆ្នោតនោះ គណបក្សប្រជាជនកម្ពុជាបានទទួលសំឡេងឆ្នោតគាំទ្រ ៦០% និងតំណែងភាគច្រើននៅក្នុងក្រុមប្រឹក្សាឃុំសង្កាត់ ។

## *ដំណើរវិវឌ្ឍន៍ផ្នែកនយោបាយសំខាន់ៗពីឆ្នាំ២០០៣-២០០៨*

រយៈពេលនៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាខែកក្កដា ឆ្នាំ២០០៣ ត្រូវបានកត់សម្គាល់ដោយករណីឃាតកម្មធំៗជាច្រើនករណី និងសេចក្តីរាយការណ៍ពាសពេញអំពីការបំភិតបំភ័យ និងការគំរាមកំហែង[១២] ។ គណបក្សប្រជាជនកម្ពុជា បានធ្វើអោយខ្លួនឃ្លាតឆ្ងាយពីដៃគូប្រកួតប្រជែងនយោបាយដោយការពង្រឹងមូលដ្ឋានគាំទ្ររបស់ខ្លួន តាមរយៈជ័យជំនះនៅក្នុងការបោះឆ្នោតមួយលើកទៀត ខណៈដែលគណបក្សសមរង្ស៊ី (គ.ស.រ) បានលេចឡើងជាគណបក្សធំជាងគេបំផុតទី២ ។ លទ្ធផលនៃការបោះឆ្នោតឆ្នាំ២០០៣ បាននាំទៅរកភាពជាប់គាំងផ្នែកនយោបាយអស់រយៈពេលជាង ១០ខែ ខណៈដែលគណបក្សប្រជាជនកម្ពុជាត្រូវការដៃគូដើម្បីបង្កើតរដ្ឋាភិបាលចម្រុះ ហើយបាននិងកំពុងប្រឈមចំពោះ"សម្ព័ន្ធភាពនៃអ្នកប្រជាធិបតេយ្យ" ដែលជាការរួបរួមគ្នារវាងគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី នៅក្នុងការចរចាទាមទារនូវសម្បទាន ។ នៅក្រោយការចរចាជាច្រើនលើក នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលកំពុងកាន់តំណែងបានផ្តល់តំណែងជាប្រធានរដ្ឋសភាដល់ព្រះអង្គម្ចាស់ **នរោត្តម រណឫទ្ធិ** ដែលការផ្តល់នេះបានត្រួសត្រាយផ្លូវសម្រាប់រដ្ឋាភិបាលចម្រុះដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច អាណត្តិទី៣ ដែលបង្កើតឡើងនៅក្នុងខែកក្កដា ឆ្នាំ២០០៤ ។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៥ រដ្ឋសភាបានបោះឆ្នោតដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងចំនួន ៣រូប ក្នុងនោះរួមទាំងលោក **សម រង្ស៊ី** ដែលជាប្រធានគណបក្សផង ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងការចោទប្រកាន់ថា អ្នកតំណាងរាស្ត្រទាំងនោះគ្រោងផែនការបង្កើតចលនាប្រដាប់អាវុធ ។ តំណាងរាស្ត្រ **ជាម ច័ន្ទនី** ត្រូវបានចាប់ខ្លួន និងកាត់ទោសពីបទចោទប្រកាន់ទាក់ទងនឹងសកម្មភាពយោធា ចំណែកឯលោក **សម រង្ស៊ី** ដែលប្រឈមមុខនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ បាននិរទេសខ្លួនទៅក្រៅប្រទេស[១៣] ។ នៅក្នុងខែតុលា ឆ្នាំ២០០៥ រដ្ឋាភិបាលបានចាប់ខ្លួនអ្នករិះគន់

---

[១១] របាយការណ៍លម្អិតរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) អាចរកមើលបាននៅលើគេហទំព័រ : www.hrw.org ។

[១២] សម្រាប់សេចក្តីលម្អិតបន្ថែម សូមអានរបាយការណ៍ស្ថាពរឆ្នាំ២០០៣ របស់ប្រតិបត្តិការសង្កេតការណ៍បោះឆ្នោតរបស់សហភាពអឺរ៉ុបប្រចាំកម្ពុជា ។

[១៣] តំណាងរាស្ត្រទី៣របស់គណបក្សសមរង្ស៊ី លោក **ជា ប៉ូច** ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ប៉ុន្តែមិនត្រូវបានកាត់ក្តី ឬកាត់អោយជាប់ទោសឡើយ ។

ប្រឆាំងនឹងការចុះហត្ថលេខាលើសន្ធិសញ្ញាព្រំដែនបំពេញបន្ថែមជាមួយប្រទេសវៀតណាម[១៤] ហើយក្រោយមកបានឃុំខ្លួនសកម្មជនសិទ្ធិមនុស្សចំនួន ៤រូប ។ នៅក្នុងខែមករា ឆ្នាំ២០០៦ បរិយាកាសនយោបាយតានតឹងបានធូរស្រាលឡើងវិញនៅពេលដែលនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានសម្រេចចិត្តដោះលែងអ្នកជាប់ឃុំឃាំងដោយសាររឿងនយោបាយទាំងអស់ និងដកការចោទប្រកាន់ប្រឆាំងតំណាងរាស្ត្រគណបក្សសមរង្ស៊ី ហើយបន្ទាប់មក លោក **សម រង្ស៊ី** ក៏បានវិលត្រឡប់មកកម្ពុជាវិញ ។

នៅក្នុងខែមីនា ឆ្នាំ២០០៦ ទោះបីជាមានការជំទាស់ពីសំណាក់គណបក្សហ្វ៊ុនស៊ិនប៉ិចក្តី គណបក្សប្រជាជនកម្ពុជាបានព្រមព្រៀងគ្នាជាមួយគណបក្សសមរង្ស៊ី កែប្រែមាត្រារដ្ឋធម្មនុញ្ញដែលតម្រូវអោយមានសំឡេងគាំទ្រ២ភាគ៣ដើម្បីបង្កើតរដ្ឋាភិបាល ដោយជំនួសដោយរូបមន្ត ៥០% + ១[១៥] វិញ ។ ក្នុងការតវ៉ាជំទាស់ទៅនឹងការកែប្រែនេះ ប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច ព្រះអង្គម្ចាស់ **នរោត្តម រណឫទ្ធិ** បានលាលែងពីមុខតំណែងជាប្រធានរដ្ឋសភា ហើយទំនាក់ទំនងរបស់ព្រះអង្គជាមួយនឹងថ្នាក់ដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា កាន់តែជូរចត់ខ្លាំងឡើងៗ ។ នៅក្នុងខែតុលា ឆ្នាំ២០០៦ ក្រុមមួយនៅក្នុងគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលប្រឆាំងនឹងរបៀបរបបដឹកនាំរបស់ព្រះអង្គម្ចាស់ **រណឫទ្ធិ** បានកោះប្រជុំសមាជវិសមញ្ញគណបក្សដោយបានបោះឆ្នោតអោយលោក **កែវ ពុទ្ធរស្មី** ឡើងកាន់តំណែងជាប្រធានថ្មីរបស់គណបក្សនេះ ។ នៅក្រោយព្រឹត្តិការណ៍នេះ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៦ ព្រះអង្គម្ចាស់ **រណឫទ្ធិ** បានបង្កើតគណបក្សថ្មីមួយទៀត គឺគណបក្ស **នរោត្តម រណឫទ្ធិ** (គ.ន.រ) ដែលការបង្កើតនេះបាននាំអោយព្រះអង្គបាត់បង់អាសនៈនៅរដ្ឋសភាដោយស្វ័យប្រវត្តិ ។

ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់លើកទី២ នាឆ្នាំ២០០៧ បានប្រព្រឹត្តទៅ នៅចំពេលដែលមានការធ្វើបាតុកម្មដោយព្រះសង្ឃខ្មែរកម្ពុជាក្រោម ដើម្បីទាមទារសិទ្ធិសេរីភាពក្នុងការប្រតិបត្តិសាសនា នៅក្នុងដែនដីភាគខាងត្បូងនៃប្រទេសវៀតណាម ។ ការចុះចូលរបស់សកម្មជនគណបក្សសមរង្ស៊ី ជាមួយនឹងគណបក្សប្រជាជនកម្ពុជា ក៏បានបង្ហាញផងដែរនូវនិន្នាការឆ្ពោះទៅរកការបោះឆ្នោតដែលមានអំពើហិង្សាកើតឡើងតិចជាងលើកមុនៗ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក្តីបារម្ភត្រូវបានលើកឡើង អំពីវត្តមានរបស់មេភូមិនៅក្បែរស្ថានីយបោះឆ្នោត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (VINs)[១៦] ។ ចំនួនអ្នកបោះឆ្នោត ដែលចេញទៅបោះឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់លើកទី២នេះ គឺមានតែ ៦៧,៨៧% ប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងចំនួនអ្នកចេញទៅបោះឆ្នោត ៨៧,៤៨% ដែលចូលរួមនៅក្នុងការបោះឆ្នោតដូចគ្នានេះនៅក្នុងឆ្នាំ២០០២ ។

## គ. តួអង្គនយោបាយសំខាន់ៗ

[១៤] សេចក្តីព្រាងច្បាប់ស្តីពីកិច្ចព្រមព្រៀងនៃសន្ធិសញ្ញាបំពេញបន្ថែមរវាងកម្ពុជា និងវៀតណាមទៅលើសន្ធិសញ្ញាព្រំដែនឆ្នាំ ១៩៨៥ ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅទីក្រុងហាណូយ នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ ហើយក្រោយមក ត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ នៅចំពេលដែលមានការរិះគន់ពីសំណាក់គណបក្សសមរង្ស៊ី ។

[១៥] នៅខែមេសា ឆ្នាំ២០០៦ តម្រូវការនូវសំឡេងគាំទ្រ ២/៣នៃសមាជិកសភាទាំងអស់ដើម្បីបង្កើតរដ្ឋាភិបាលដែលមានចែងនៅក្នុងមាត្រា ៨៩ នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ត្រូវបានធ្វើវិសោធនកម្មទៅជា ៥០% បូកមួយ វិញ ។

[១៦] សម្រាប់សេចក្តីលម្អិតបន្ថែមទៀត សូមមើលរបាយការណ៍ចេញផ្សាយដោយអង្គការ UNDP ប្រចាំកម្ពុជា ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧ ដែលមាននៅលើ : http://www.un.org.kh/undp/index.php?option=com_docman&task=doc_details&Itemid=73&gid=68

ទិដ្ឋភាពនយោបាយកម្ពុជានារយៈពេលថ្មីៗចុងក្រោយនេះ មានការចូលរួមពីសំណាក់គណបក្សនយោបាយចំនួន ៤៥ ដែលបានចុះបញ្ជីជាផ្លូវការជាមួយក្រសួងមហាផ្ទៃ ប៉ុន្តែទោះជាយ៉ាងនេះក្តី មានតែគណបក្សមួយចំនួនតូចប៉ុណ្ណោះ ដែលបានជះឥទ្ធិពលទៅលើដំណើរវិវឌ្ឍន៍ផ្នែកនយោបាយនៅក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ។ គណបក្សនយោបាយភាគច្រើនបំផុតនៅក្នុងប្រទេសកម្ពុជា ត្រូវបានកត់សម្គាល់ដោយកង្វះនូវអត្តសញ្ញាណកម្មវិធី/មនោគមន៍វិជ្ជាជាអចិន្ត្រៃយ៍ ហើយផ្តោតសំខាន់ទៅលើកម្មវិធីនយោបាយដែលបង្កើតឡើងជុំវិញមេដឹកនាំដែលមានប្រជាប្រិយភាព ឬឥទ្ធិពល ឬបញ្ហាដែលលេចឡើង ដោយបង្ហាញអោយឃើញនូវការពឹងផ្អែកលើយុទ្ធសាស្ត្រនយោបាយប្រជានិយម ។

កម្លាំងនយោបាយដែលប្រឆាំងនឹងរដ្ឋាភិបាលចម្រុះដែលមានជាយូរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ភាគច្រើនគឺបង្កើតឡើងដោយមេដឹកនាំ និងសកម្មជនដែលបានបែកចេញបន្តិចម្តងៗពីគណបក្សហ៊្វុនស៊ិនប៉ិច ។ អ្នកខ្លះបានបាត់មុខ រីឯអ្នកខ្លះទៀតក៏អាចពង្រឹងតំណែងរបស់ខ្លួនបាន ។ កន្លងមក ក៏មានការចោទប្រកាន់ផងដែរថា គណបក្សថ្មីៗត្រូវបានបង្កើតឡើងក្នុងចេតនាដើម្បីបំបែកសំឡេងឆ្នោតរបស់គណបក្សប្រឆាំង និងដើម្បីកាត់បន្ថយចំនួនម៉ោងផ្សាយដោយមិនគិតថ្លៃដែលត្រូវចែកទៅអោយគណបក្សប្រឆាំងនាំមុខគេ ក្នុងអំឡុងពេលឃោសនារកសំឡេងឆ្នោត ។ ខណៈដែលលទ្ធិប្រជាធិបតេយ្យនៅក្នុងជួរបក្សគឺជាគំនិតថ្មីមួយនៅកម្ពុជា គណបក្សនយោបាយជាច្រើនបានធ្វើកិច្ចប្រឹងប្រែងក្នុងការរៀបចំការបោះឆ្នោតផ្ទៃក្នុងសម្រាប់មុខតំណែងដឹកនាំនៅថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋាន ហើយបានធ្វើការបោះឆ្នោតសាកល្បងជ្រើសរើសបេក្ខជន ចាប់តាំងពីឆ្នាំ២០០៣មក ។ នៅក្នុងចំណោមគណបក្សនយោបាយទាំង ១១[១៧] ដែលប្រកួតប្រជែងសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ គណបក្សចំនួន ៦ ទើបតែត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦ ឬឆ្នាំ២០០៧ ប៉ុណ្ណោះ ។

គណបក្សធំជាងគេបង្អស់នៅកម្ពុជា គឺគណបក្សប្រជាជនកម្ពុជា[១៨] (**គ.ប.ក**) ដែលជាផ្នែកនៃការដឹកនាំនយោបាយរបស់ប្រទេសនេះចាប់តាំងពីការឈ្លានពានរបស់វៀតណាមនៅក្នុងឆ្នាំ១៩៧៩មក ។ ឥស្សរជនជួរមុខរបស់គណបក្សប្រជាជនកម្ពុជា គឺលោក **ហ៊ុន សែន** អនុប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រី ។ ចាប់តាំងពីពេលបង្កើតឡើងមក គណបក្សប្រជាជនកម្ពុជា គឺជាគណបក្សដែលគ្របដណ្តប់លើគេនៅក្នុងនយោបាយរបស់ប្រទេសកម្ពុជា ហើយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គណបក្សប្រជាជនកម្ពុជាបានពង្រឹងតំណែងរបស់ខ្លួនយ៉ាងរឹងមាំ ។ គណបក្សនេះបានឈ្នះសំឡេងភាគច្រើននៅក្នុងរដ្ឋសភានាឆ្នាំ២០០៣, កាន់កាប់សំឡេង ២/៣ នៅក្នុងព្រឹទ្ធសភាបច្ចុប្បន្ន និងគ្រប់គ្រងក្រុមប្រឹក្សាឃុំសង្កាត់ប្រមាណជា ៩៧% ។ គណបក្សនេះមានទំនាក់ទំនងរឹងមាំជាមួយនឹងវិស័យ ពាណិជ្ជកម្មដែលកំពុងរីកលូតលាស់នៅក្នុងប្រទេសកម្ពុជា ព្រមទាំងមានទំនាក់ទំនងការទូតយ៉ាងរឹងមាំជាមួយប្រទេសវៀតណាមដែលនៅជិតខាង និងជាមួយប្រទេសចិន ។ លទ្ធិ-ប្រជាធិបតេយ្យ និងតម្លាភាពផ្ទៃក្នុងរបស់គណបក្សនៅមានភាពទន់ខ្សោយ ហើយ ការធ្លាយចេញនូវព័ត៌មានទាក់ទងនឹងបញ្ហាចម្រូងចម្រាសផ្ទៃក្នុងគឺកម្រនឹងកើតមានណាស់ ។ ជារឿយៗ គណបក្សប្រជាជនកម្ពុជាត្រូវបានកោតសរសើរចំពោះវត្តមាន

[១៧] គណបក្សដែលចូលរួមប្រកួតប្រជែងរួមមាន : គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សនរោត្តម រណឫទ្ធិ គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសិទ្ធិមនុស្ស គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សប្រជាធិបតេយ្យខ្មែរ គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ គណបក្សសាធារណរដ្ឋខ្មែរ គណបក្សខ្មែរឈប់ក្រ និងគណបក្សសង្គមយុត្តិធម៌ ។

[១៨] គណបក្សនេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៩ ជាគណបក្សបដិវត្តន៍ប្រជាជនកម្ពុជា ហើយប្តូរមកជាឈ្មោះបច្ចុប្បន្ននៅក្នុងឆ្នាំ១៩៩១ ។

រឹងមាំ និងទូលំទូលាយរបស់គណបក្សនេះនៅទូទាំងប្រទេសរហូតទៅដល់ភូមិតូចៗបំផុត ។ កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសង្កត់ធ្ងន់ទៅលើតួនាទីរបស់ខ្លួនក្នុងការនាំមកនូវស្ថិរភាព កំណើនសេដ្ឋកិច្ច និងការវិនិយោគថ្មីៗ ក្នុងនោះរាប់ទាំងហេដ្ឋារចនាសម្ព័ន្ធ ជូនប្រទេសកម្ពុជា ។

គណបក្សសមរង្ស៊ី (**គ.ស.រ**) គឺជាគណបក្សសង្គមសេរីមួយ ដែលបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៨ និងដឹកនាំដោយលោក **សម រង្ស៊ី** ជាអតីតរដ្ឋមន្ត្រីរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច និងប្រធានគណបក្សជាតិខ្មែរ ។ គណបក្សសមរង្ស៊ី នៅក្នុងការបោះឆ្នោតជាតិឆ្នាំ២០០៣ បានលេចឡើងជាគណបក្សធំជាងគេបំផុតឈរនៅលំដាប់ទី៣នៅក្នុងប្រទេសកម្ពុជា ដោយទទួលបានសំឡេងឆ្នោត ២១,៩% ក្នុងចំណោមសំឡេងឆ្នោតទាំងអស់[១៩] ។ គណបក្សនេះគឺជាអ្នកប្រឆាំងដែលរិះគន់ឥតសំចៃទៅលើគណបក្សប្រជាជនកម្ពុជា និងផ្សព្វផ្សាយលើកតម្កើងខ្លួនឯងនៅលើរបៀបវារៈសង្គមដែលរួមមានដូចជា ការដំឡើងប្រាក់បៀវត្សរ៍ដល់បុគ្គលិកនិងមន្ត្រីរាជការ ការបង្កើនការវិនិយោគលើវិស័យសុខភាព និងអប់រំ ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ គណបក្សសមរង្ស៊ីបានទទួលសំឡេងឆ្នោតគាំទ្រ ២៥,២% នៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧ ។ នៅមុនការបោះឆ្នោតឃុំសង្កាត់ទាំងនោះ និងជាថ្មីម្តងទៀត នៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ គណបក្សសមរង្ស៊ីបានទទួលរងគ្រោះដោយសារតែមន្ត្រី និងសកម្មជនរបស់ខ្លួនក្នុងចំនួនច្រើនគួរអោយកត់សម្គាល់បានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ ។ អ្នកសង្កេតការណ៍ជាច្រើនយល់ស្របថា ការចុះចូលនេះគឺជាលទ្ធផលនៃយុទ្ធសាស្ត្រមុខពីរ គឺការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងការគំរាមកំហែង ។

គណបក្ស នរោត្តម រណឫទ្ធិ (**គ.ន.រ**) ត្រូវបានបង្កើតឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៦ ដោយអតីតប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច គឺព្រះអង្គម្ចាស់ **នរោត្តម រណឫទ្ធិ** នៅក្រោយពេលដែលព្រះអង្គចាកចេញពីគណបក្សហ្វ៊ុនស៊ិនប៉ិច ។ នៅក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧ គណបក្ស នរោត្តម រណឫទ្ធិ ទទួលបានលទ្ធផលល្អប្រសើរជាង "គណបក្សមេ" របស់ខ្លួន ដោយទទួលបានសំឡេងឆ្នោតគាំទ្រ ៨,១% ។ ព្រះអង្គម្ចាស់ **នរោត្តម រណឫទ្ធិ** បច្ចុប្បន្នកំពុងគង់និរទេសនៅក្រៅប្រទេសដោយសារតែដីកាតាមចាប់ខ្លួនប្រឆាំងព្រះអង្គ[២០] ពាក់ព័ន្ធនឹងករណីរំលោភសេចក្តីទុកចិត្តដែលត្រូវបានគេរាយការណ៍ជាទូទៅ ធ្វើឡើងដោយអតីតសម្ព័ន្ធមិត្តគឺគណបក្សហ្វ៊ុនស៊ិនប៉ិច ។ កម្មវិធីនយោបាយរបស់គណបក្ស នរោត្តម រណឫទ្ធិ សម្រាប់ការបោះឆ្នោត គឺផ្អែកលើការដោះស្រាយបញ្ហាអន្តោប្រវេសន៍ខុសច្បាប់ អតិផរណា និងអំពើពុករលួយ ព្រមទាំងការបង្កើនការវិនិយោគលើវិស័យអភិវឌ្ឍន៍ជនបទ និងការអប់រំ ។ ទោះបីជាប្រធានគណបក្ស នរោត្តម រណឫទ្ធិ អវត្តមានពីក្នុងប្រទេសក្តី សារនយោបាយរបស់ព្រះអង្គត្រូវបានបញ្ជូនតាមរយៈសុន្ទរកថាដែលថតទុកតាមទូរស័ព្ទ នៅក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោតរបស់គណបក្ស នរោត្តម រណឫទ្ធិ ។

[១៩] ដោយសាររូបមន្តបែងចែកអាសនៈ គណបក្សសមរង្ស៊ីបានក្លាយត្រឹមតែជាគណបក្សធំជាងគេទី៣នៅក្នុងរដ្ឋសភា ដោយមានអាសនៈចំនួន ២៤ ចំណែកឯគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលបានទទួលសំឡេងគាំទ្រតែ ២០,៨% ប៉ុន្តែបានអាសនៈចំនួន ២៦ ។

[២០] ដីកាចាប់ខ្លួនត្រូវបានចេញទាក់ទងនឹងសវនាការតុលាការនៅក្នុងរឿងក្តីលក់អតីតទីស្នាក់ការកណ្តាលគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលនៅក្នុងរឿងក្តីនេះ ព្រះអង្គម្ចាស់ត្រូវបានតុលាការកាត់ទោសអោយជាប់ពន្ធនាគាររយៈពេល ១៨ខែ ។ សាលក្រមនេះត្រូវបានតម្កល់ទុកដោយសាលដីការបស់តុលាការកំពូល នាថ្ងៃទី៣០ ខែកក្កដា នៅក្រោយពេលដែលមានបណ្តឹងឧទ្ធរណ៍ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការលើកលែងទោសពីព្រះមហាក្សត្រកន្លងមកបានត្រួសត្រាយផ្លូវសម្រាប់ព្រះអង្គដើម្បីវិលត្រឡប់មកចូលប្រឡូកក្នុងឆាកនយោបាយកម្ពុជាវិញ ។

គណបក្សហ៊្វុនស៊ិនប៉ិច គឺជាពាក្យកាត់ជាភាសាបារាំងថា Front Uni National pour un Cambodge Indépendant, Neutre, Pacifique, et Coopératif ដែលប្រែជាភាសាអង់គ្លេសថា "National United Front for an Independent, Neutral, Peaceful, and Cooperative Cambodia" ឬជាភាសាខ្មែរថា រណសិរ្សរួបរួមជាតិដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការ ។ គណបក្សហ៊្វុនស៊ិនប៉ិច គឺជាគណបក្សរាជានិយម ដែលពីមុនដឹកនាំដោយព្រះអង្គម្ចាស់ **នរោត្តម រណឫទ្ធិ** និងចាប់ពីខែតុលា ឆ្នាំ២០០៦មក ត្រូវបានដឹកនាំដោយលោក **កែវ ពុទ្ធរស្មី** ។ បើប្រៀបធៀបជាមួយគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិចផ្តល់នូវកម្មវិធីនយោបាយដែលមានលក្ខណៈសេរីជាង ហើយនៅក្នុងការបោះឆ្នោត គណបក្សនេះបានធ្វើយុទ្ធនាការឃោសនាផ្អែកទៅលើសារប្រហាក់ប្រហែលគ្នានឹងសាររបស់គណបក្សដែលប្រកាសខ្លួនថាជាគណបក្សប្រឆាំងដែរ ។ គណបក្សហ៊្វុនស៊ិនប៉ិច បានខំប្រឹងប្រណាំងប្រជែងជាមួយនឹងការគាំទ្រកាន់តែកើនឡើងដែលគណបក្សប្រជាជនកម្ពុជាទទួលបាន ហើយបានរងគ្រោះដោយសារតែមន្ត្រី និងសមាជិករបស់ខ្លួនផ្តាច់ខ្លួនចេញពីបក្ស និងការបែកបាក់គ្នាជាបន្តបន្ទាប់ ដែលកើតមានឡើងកាន់តែច្រើននៅពេលដែលមានការផ្លាស់ប្តូរមេដឹកនាំក្នុងឆ្នាំ២០០៦ នៅមុនការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧ និងម្តងទៀត នៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ។ នៅក្នុងឆ្នាំ១៩៩៣ គណបក្សហ៊្វុនស៊ិនប៉ិច បានទទួលសំឡេងឆ្នោតគាំទ្រ ៤៥% នៃសំឡេងឆ្នោតសរុប ប៉ុន្តែការគាំទ្ររបស់ប្រជាជនចំពោះគណបក្សនេះបានធ្លាក់ចុះមកនៅត្រឹម ៣១,៧% នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៨, ២០,៨% នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ និងតែ ២,៤%ប៉ុណ្ណោះ នៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧ ។

គណបក្សសិទ្ធិមនុស្ស (HRP) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៧ និងដឹកនាំដោយលោក **កឹម សុខា** ដែលជាសកម្មជនសិទ្ធិមនុស្ស និងជាអតីតសមាជិកសភា និងព្រឹទ្ធសភារបស់គណបក្សហ៊្វុនស៊ិនប៉ិច ។ ថ្នាក់ដឹកនាំរបស់គណបក្សសិទ្ធិមនុស្ស រួមមានអតីតអ្នកនយោបាយជាច្រើនរូបនៅក្នុងជួរមុខតំណែងជាន់ខ្ពស់របស់ខ្លួន ។ ទោះបីជាលោក **កឹម សុខា** ត្រូវបានគេស្គាល់ថាជាអ្នករិះគន់គណបក្សកាន់អំណាចដែលបានវោហារក្តី អ្នកអត្ថាធិប្បាយមួយចំនួនបានចោទថា គណបក្សសិទ្ធិមនុស្សត្រូវបានបង្កើតឡើងដើម្បីធ្វើអោយគណបក្សប្រឆាំងទន់ខ្សោយ ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ គឺជាការបោះឆ្នោតលើកដំបូងបង្អស់ដែលគណបក្សសិទ្ធិមនុស្សបានចូលរួមប្រកួតប្រជែង ហើយកម្មវិធីនយោបាយរបស់គណបក្សនេះ គឺផ្តោតសំខាន់ទៅលើការប្រឆាំងនឹងអំពើពុករលួយ ការលើកកម្ពស់ការអនុវត្តច្បាប់ (ក្នុងនោះរាប់បញ្ចូលទាំងការគ្រប់គ្រងអន្តោប្រវេសន៍ខុសច្បាប់) ការវិនិយោគទៅលើការធ្វើស្រែចម្ការខ្នាតតូច និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

# ៤. បញ្ហាច្បាប់

## ក. កាតព្វកិច្ចរបស់កម្ពុជានៅក្រោមបទដ្ឋានអន្តរជាតិ និងថ្នាក់តំបន់

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន/ការយល់ព្រមចំពោះសន្ធិសញ្ញាអន្តរជាតិសំខាន់ៗជាច្រើនបំផុត ដែលទាក់ទងនឹងការបោះឆ្នោត ក្នុងនោះរួមមានអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ (ICCPR) អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងជាតិសាសន៍ (CERD) និងអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំង ស្ត្រី

(CEDAW) ។ បញ្ញត្តិដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិទាំងនេះ គឺជាកាតព្វកិច្ចដែលកម្ពុជាត្រូវអនុវត្តតាម ហេតុដូច្នេះហើយ កម្ពុជាមានកាតព្វកិច្ចត្រូវខិតខំប្រឹងប្រែងដើម្បីគោរពតាមសន្ធិសញ្ញាអន្តរជាតិទាំងនេះ ។

សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានបទដ្ឋានទាក់ទងនឹងការបោះឆ្នោតជាសកលចំនួន ៦ : ការបោះឆ្នោតត្រូវតែធ្វើឡើងទៀងតាមពេលកំណត់ ការបោះឆ្នោតត្រូវតែពិតប្រាកដឥតក្លែងបន្លំ ត្រូវតែមានសិទ្ធិសម្រាប់ការបោះឆ្នោតជាសកល ត្រូវមានសិទ្ធិសម្រាប់ការចូលរួមបោះឆ្នោតស្មើភាពគ្នា ការបោះឆ្នោតត្រូវតែឈរលើឆន្ទៈសេរីរបស់អ្នកបោះឆ្នោត និងត្រូវតែមានសិទ្ធិសម្រាប់ការបោះឆ្នោតដោយសម្ងាត់ ។ មាត្រា ២៥ នៃ ICCPR លើកឡើងជាថ្មីម្តងទៀត និងពង្រីកបទដ្ឋានទាំងនោះ ដោយផ្តល់ដល់ពលរដ្ឋនីមួយៗនូវសិទ្ធិក្នុងការបោះឆ្នោត និងសិទ្ធិក្នុងការឈរឈ្មោះអោយគេបោះឆ្នោត ។ មាត្រា ២៥ នេះ ត្រូវបានបកស្រាយជាលម្អិតដោយសេចក្តីអត្ថាធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។

## ខ. ក្របខ័ណ្ឌច្បាប់ជាតិ

ច្បាប់ជាតិដ៏សំខាន់ដែលគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាឆ្នាំ២០០៨ គឺច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (**ច.ប.ត.រ**) ។ ច្បាប់ផ្សេងទៀតដែលក៏មានឥទ្ធិពលលើដំណើរការនៃការបោះឆ្នោតផងដែរនោះ រួមមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីបាតុកម្ម ច្បាប់ស្តីពីសញ្ជាតិ និងក្រមព្រហ្មទណ្ឌឆ្នាំ១៩៩២ ។ លើសពីនេះទៀត ក៏នៅមានបទប្បញ្ញត្តិ និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (**គ.ជ.ប**) និងសេចក្តីណែនាំរបស់ **គ.ជ.ប** សេចក្តីណែនាំរួមដែលចេញដោយក្រសួងមហាផ្ទៃ និង **គ.ជ.ប** បទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ប** ព្រមទាំងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ អ្នកសង្កេតការណ៍ មន្ត្រីរៀបចំការបោះឆ្នោត និងសម្រាប់សមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងនគរបាល ។

ច្បាប់ដែលពាក់ព័ន្ធ ជាទូទៅបានផ្តល់នូវក្របខ័ណ្ឌមួយដែលអាចអោយគេបំពេញការងារបាន ហើយជារួម គឺមានលក្ខណៈស្របតាមបទដ្ឋានអន្តរជាតិ និងបង្កើតនូវស្ថាប័ននានាដែលចាំបាច់សម្រាប់ការរៀបចំការបោះឆ្នោត ។ ក្រមសីលធម៌ត្រួតពិនិត្យសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកដែលពាក់ព័ន្ធក្នុងលក្ខណៈមួយដែលគួរជាទីពេញចិត្តជាទូទៅ ។ បញ្ហានៅកម្ពុជា គឺពេលខ្លះ ការអនុវត្តបទប្បញ្ញត្តិច្បាប់មិនបានគ្រប់ជ្រុងជ្រោយ និងកង្វះឯករាជ្យភាពដែលមានជាក់ស្តែង ឬដែលគេគិតថាមានរបស់ស្ថាប័ននានា ។

លក្ខខណ្ឌច្បាប់សម្រាប់ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ធ្វើអោយមានការព្រួយបារម្ភមួយចំនួន ។ យោងតាម **ច.ប.ត.រ** បេក្ខជនត្រូវតែជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច មានអាយុយ៉ាងតិច ២៥ឆ្នាំ ជាពលរដ្ឋខ្មែរតាំងពីកំណើត មានលំនៅនៅក្នុងប្រទេសកម្ពុជា និងត្រូវបានតែងតាំងដោយគណបក្សនយោបាយមួយ ។ **ច.ប.ត.រ** មិនអនុញ្ញាតអោយបេក្ខជនឯករាជ្យឈរឈ្មោះនៅក្នុងការបោះឆ្នោតឡើយ ហើយច្បាប់នេះផ្តល់លទ្ធភាពក្នុងការឈរឈ្មោះជាបេក្ខជនដល់ពលរដ្ឋដែលកើតនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ដោយមិនផ្តល់លទ្ធភាពដល់

ពលរដ្ឋដែលចូលសញ្ជាតិឡើយ ។ ក្នុងចំណុចនេះ **ច.ប.ត.រ** មិនអនុលោមទាំងស្រុងតាមបទដ្ឋានអន្តរជាតិ និងវិធីអនុវត្តន៍ដែលល្អបំផុតឡើយ[២១] ។

បទប្បញ្ញត្តិនៃច្បាប់បោះឆ្នោត ហាមប្រាមចំពោះការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋនៅក្នុងការធ្វើយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។ ទោះបីជាមានបញ្ញត្តិទាំងនេះក្តី គណៈកម្មការជាតិរៀបចំការបោះឆ្នោតនៅតែមានការរារែកយ៉ាងខ្លាំងក្នុងការប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីដាក់ទណ្ឌកម្មតាមជំពូកទី១១ នៃ **ច.ប.ត.រ** ចំពោះករណីនៃការប្រើប្រាស់យានជំនិះដែលមានពាក់ស្លាកលេខរដ្ឋ នគរបាល ឬកងកម្លាំងប្រដាប់អាវុធ នៅក្នុងសកម្មភាពធ្វើយុទ្ធនាការឃោសនារកសំឡេងឆ្នោត[២២] ។

មានវិធានតិចតួចប៉ុណ្ណោះ ដែលគ្រប់គ្រងលើការចំណាយរបស់គណបក្ស ដែលបណ្តាលអោយមានប្រព័ន្ធនៃការចំណាយសម្រាប់យុទ្ធនាការឃោសនារកសំឡេងឆ្នោត ដែលគ្មានតម្លាភាពយ៉ាងខ្លាំង ។ ពុំមានការដាក់កំហិតទៅលើវិភាគទានទីមួយៗ ឬវិភាគទានសរុប និងពុំមានការកំណត់ចំពោះការចំណាយសរុបសម្រាប់យុទ្ធនាការឃោសនារកសំឡេងឆ្នោតឡើយ[២៣] ។ **ច.ប.ត.រ** មាន ខ ចែងមួយ ដែលតម្រូវអោយគណបក្ស និងបេក្ខជនត្រូវមានសៀវភៅគណនីមួយ ដោយបង្ហាញអំពីប្រភពនៃប្រាក់ចំណូល និងការចំណាយសម្រាប់យុទ្ធនាការឃោសនារកសំឡេងឆ្នោត (មាត្រា ៨២) ។ រាល់វិភាគទាន និងការចំណាយទាំងអស់ត្រូវតែកត់ត្រាតណពន្ធ និងតណទាននៅក្នុងគណនីធនាគារតែមួយ (មាត្រា ៨៣) ។ គណនីធនាគារនោះ "ប្រសិនបើចាំបាច់" អាចនឹងត្រូវត្រួតពិនិត្យដោយ **គ.ជ.ប** (មាត្រា ១៦, ៨២) ប៉ុន្តែពុំមានទណ្ឌកម្មណាមួយដែលត្រូវបានកំណត់នៅក្នុងជំពូកទី ១១ (ទោសប្បញ្ញត្តិ) របស់ **ច.ប.ត.រ** ក្នុងករណីដែលគណបក្សមួយមិនគោរពតាមលក្ខខណ្ឌតម្រូវទាំងនេះឡើយ ។ នៅក្នុងការបោះឆ្នោតលើកមុនៗ **គ.ជ.ប** មិនដែលបានប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីពិនិត្យបញ្ជីគណនេយ្យរបស់គណបក្សឡើយ ហើយយោងតាមប្រសាសន៍របស់អគ្គលេខាធិការ **គ.ជ.ប** មិនឃើញមានការចាំបាច់ណាមួយដើម្បីត្រួតពិនិត្យសៀវភៅគណនីរបស់គណបក្សនៅក្នុងពេលនេះឡើយ ។

បើទោះបីជាច្បាប់ស្តីពីគណបក្សនយោបាយចែងអំពីលទ្ធភាពរបស់រដ្ឋ ក្នុងការលៃលកថវិកាក្នុងចំនួនស្មើៗគ្នាពីថវិកាជាតិដើម្បីផ្តល់ជាឧបត្ថម្ភធនដល់គណបក្សនយោបាយទាំងអស់ សម្រាប់ទុកប្រើប្រាស់នៅក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោតក្តី រដ្ឋមិនដែលបានផ្តល់ថវិកាបែបនេះម្តងណាឡើយ ។ ការផ្តល់ឧបត្ថម្ភធនបែបនេះ អាចជួយក្នុងការផ្តល់ជាទីលានប្រកួតប្រជែងស្មើភាពគ្នា និងកាត់បន្ថយការរើសអើងប្រឆាំងនឹងគណបក្ស និងបេក្ខជនដែលមិនសូវមានទ្រព្យធន ។

នៅក្នុងការបោះឆ្នោតមុនៗ **គ.ជ.ប** គឺជាយុត្តាធិការថ្នាក់ខ្ពស់បំផុតសម្រាប់ការជំនុំជម្រះលើពាក្យបណ្តឹង និងបណ្តឹងឧទ្ធរណ៍ដែលទាក់ទងនឹងយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។ ប៉ុន្តែ នៅក្នុងឆ្នាំ២០០៦ **ច.ប.ត.រ** ត្រូវបានធ្វើវិសោធនកម្ម

---

[២១] តាមការកំណត់នៃប្រព័ន្ធច្បាប់តុលាការនៅក្នុងករណីជាច្រើន សិទ្ធិក្នុងការឈរឈ្មោះសម្រាប់ការបោះឆ្នោត ក៏រួមបញ្ចូលទាំងការទទួលស្គាល់សិទ្ធិក្នុងការឈរឈ្មោះជាបេក្ខជនឯករាជ្យ ផងដែរ ។ Cf. General Comment 25 (17) : "សិទ្ធិរបស់មនុស្សក្នុងការឈរឈ្មោះបោះឆ្នោត មិនគួរត្រូវបានរឹតត្បិតដោយមិនសមហេតុផលដោយតម្រូវអោយបេក្ខជនត្រូវតែជាសមាជិករបស់គណបក្សនយោបាយឡើយ" ។ General Comment 25 (3) : ការបែងចែករវាងអ្នកដែលទទួលបានសញ្ជាតិពីកំណើត និងអ្នកដែលទទួលបានសញ្ជាតិដោយការសុំចូលសញ្ជាតិ អាចលើកឡើងនូវចំណោទអំពីវិសមិតភាពជាមួយនឹងមាត្រា ២៥ ។

[២២] Cf. បទប្បញ្ញត្តិ និងនីតិវិធី កថាខណ្ឌ ៧.៤.១ និង ៧.៤.២ ព្រមទាំងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងាររបស់គណបក្សនយោបាយក្នុងអំឡុងពេលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ថ្ងៃទី២៧ កក្កដា ២០០៨។

[២៣] បទដ្ឋានអន្តរជាតិ អនុញ្ញាតអោយមានការដាក់កំហិតសមហេតុផលទៅលើការចំណាយសម្រាប់យុទ្ធនាការឃោសនារកសំឡេងឆ្នោត ហើយការដាក់កំហិតទាំងនេះ អាចធ្វើនៅក្នុងករណីដែលចាំបាច់ដើម្បីធានាថា សិទ្ធិជ្រើសរើសដោយសេរីរបស់អ្នកបោះឆ្នោតមិនត្រូវបានធ្វើអោយខូច ឬដំណើរការលទ្ធិប្រជាធិបតេយ្យមិនត្រូវបានធ្វើអោយប៉ះពាល់ដោយសារការចំណាយមិនសមាមាត្រដោយបេក្ខជន ឬគណបក្សណាមួយ (cf. General Comment 25 (19)) ។

ហើយក្រុមប្រឹក្សាធម្មនុញ្ញបានក្លាយជាស្ថាប័នដែលមានយុត្តាធិការខ្ពស់បំផុត ។ ទោះបីជាការធ្វើវិសោធនកម្មនេះអាចត្រូវគេចាត់ទុកថាជាជំហានមួយក្នុងទិសដៅដ៏ត្រឹមត្រូវ ពីព្រោះប្រការនេះផ្តល់អោយមានការពិនិត្យផ្នែកច្បាប់ទៅលើសេចក្តីសម្រេចរបស់ **គ.ជ.ប** ក្តី មជ្ឈដ្ឋានជាច្រើនបានសម្តែងការព្រួយបារម្ភអំពីឯករាជ្យភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

ជាទូទៅ ក្របខ័ណ្ឌច្បាប់នៅមានលក្ខណៈរាយប៉ាយនៅឡើយ ហើយបទដ្ឋានជាច្រើនដែលមានកម្រិត និងប្រភេទខុសៗគ្នា (ក្នុងនោះរួមមានដូចជា បទបញ្ជា សៀវភៅណែនាំ សេចក្តីណែនាំរំលឹក សៀវភៅណែនាំ គោលការណ៍ណែនាំ សេចក្តីសម្រេច និងសេចក្តីណែនាំ ដែលធ្វើឡើងដោយ **គ.ជ.ប** និងក្រសួងពាក់ព័ន្ធ) ជួនកាល បង្កើតអោយមានការភាន់ច្រលំអំពីថាតើវិធានមួយណាធំជាងមួយណា ។ ច្បាប់ពុំបានកំណត់ច្បាស់លាស់អំពីឋានានុក្រមនៃលិខិតបទដ្ឋានទាំងនេះឡើយ ។ កង្វះនៃការបង្រួមបញ្ចូលគ្នានូវក្របខ័ណ្ឌច្បាប់ ធ្វើអោយអ្នកដែលពាក់ព័ន្ធមានការលំបាកក្នុងការស្វែងរក និងយល់ច្បាស់លាស់អំពីវិធានទាំងនេះ ។

ទាក់ទងនឹង **ច.ប.ត.រ** កង្វល់ជាចម្បង គឺថា ច្បាប់នេះនៅតែមានភាពស្រពិចស្រពិលខ្លាំងនៅក្នុងចំណុចជាច្រើន ហើយទុកចន្លោះជាច្រើនអោយមានការបកស្រាយផ្សេងៗគ្នា និងការបំពេញគម្លាតផ្នែកច្បាប់ដោយ **គ.ជ.ប** ខណៈដែលនៅស្របពេលជាមួយគ្នានេះ **គ.ជ.ប** ចែងបទប្បញ្ញត្តិច្រើនហួសលើប្រធានបទផ្សេងទៀត ។ **គ.ជ.ប** ចេញបទប្បញ្ញត្តិ និងនីតិវិធីប្រហែល ៧០០ទំព័រ ។ បទប្បញ្ញត្តិ និងនីតិវិធីទាំងនេះហាក់មានភាពស្មុគស្មាញ ចំណុចមិនស្របគ្នា គុណវិបត្តិ និង ភាពមិនច្បាស់លាស់ ។ ជាពិសេស បញ្ញត្តិស្តីពីដំណើរការនៃការដាក់ពាក្យបណ្តឹង និងបណ្តឹងឧទ្ធរណ៍ មានភាពស្មុគស្មាញក្រៃលែង ។ ការបំបែកនីតិវិធីទាំងមូលនៃបទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០០៣ ទៅជា ៨ នីតិវិធីផ្សេងៗគ្នាសម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០០៨ បាននាំអោយមានចំណុចផ្ទុយគ្នា ចំណុចជាន់គ្នា និងចំណុចខ្វះចន្លោះនៅក្នុងអត្ថបទ ។

បទប្បញ្ញត្តិ និងនីតិវិធីកំណត់អោយមានការផ្សះផ្សានៅក្នុងដំណើរការបណ្តឹង ចំពោះតែ "បទល្មើសស្រាល" ប៉ុណ្ណោះ ប៉ុន្តែមិនបានកំណត់និយមន័យនៃពាក្យនេះអោយបានច្បាស់លាស់ទេ ហើយក៏មិនបានកំណត់អំពីវិធានការដែលនឹងត្រូវអនុវត្តប្រសិនបើករណីមួយមានការជាប់ពាក់ព័ន្ធនឹងការបោះឆ្នោត ប៉ុន្តែមិនមែនជាបទល្មើសស្រាល ។ ដូច្នេះហើយ គ្មានការណែនាំច្បាស់លាស់អំពីថាតើបទល្មើសធ្ងន់ធ្ងរដែលទាក់ទងនឹងការបោះឆ្នោតត្រូវដោះស្រាយដោយរបៀបដូចម្តេចឡើយ ។ ជាងនេះទៅទៀត ប្រការមួយដែលមាននៅក្នុងបទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០០៣ ដែលបានកំណត់ថាគណៈកម្មការរៀបចំការបោះឆ្នោតមានកាតព្វកិច្ចត្រូវធ្វើការបន្តជាមួយតុលាការ ប្រសិនបើករណីមួយត្រូវបានបញ្ជូនទៅដល់តុលាការនោះ ត្រូវបានលុបចេញពីបទប្បញ្ញត្តិ និងនីតិវិធីនាពេលបច្ចុប្បន្ន ។

គ្មានការបែងចែកច្បាស់លាស់រវាងសមត្ថកិច្ចដែលផ្អែកលើ **ច.ប.ត.រ** របស់ **គ.ជ.ប** ក្នុងការដាក់ពិន័យជនល្មើស និងប្រព័ន្ធតុលាការឡើយ ។ ការដែល **គ.ជ.ប** ត្រូវបានផ្តល់នូវសមត្ថកិច្ចដែលសឹងតែដូចតុលាការដែរ ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌទាក់ទងនឹងដំណើរការនៃការបោះឆ្នោត (ដូចជា ការបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ការបង្ករបួសស្នាម ការបំភិតបំភ័យ ។ល។) គឺជាលទ្ធផលនៃការខ្វះការទុកចិត្តជាទូទៅទៅលើប្រព័ន្ធតុលាការកម្ពុជា ។ ប៉ុន្តែ ការកាត់សេចក្តីដែលប្រកាសដោយ **គ.ជ.ប** តាមផ្លូវច្បាប់ គឺមិនរារាំងតុលាការពីការដាក់ទោសទណ្ឌពីបទព្រហ្មទណ្ឌទៅលើជនល្មើសឡើយ ដរាបណាភាគីដើមបណ្តឹងដាក់ពាក្យបណ្តឹងដូចគ្នានេះទៅតុលាការផងដែរ ។

កិច្ចការនិងការទទួលខុសត្រូវជាច្រើនរបស់រដ្ឋបាលរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឧទាហរណ៍ តួនាទីរបស់គណៈ-កម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត (**គឃ/សប**) នៅក្នុងការបូកសរុបលទ្ធផលបោះឆ្នោតពីស្ថានីយបោះឆ្នោតនានា (PS) និងនៅក្នុងដំណើរការដោះស្រាយបណ្តឹងនិងបណ្តឹងឧទ្ធរណ៍ មិនត្រូវបានចែងនៅក្នុង **ច.ប.ត.រ** ឡើយ ប៉ុន្តែគ្រាន់តែត្រូវបានកំណត់ដោយ **គ.ជ.ប** នៅក្នុងបទប្បញ្ញត្តិ និងនីតិវិធីតែប៉ុណ្ណោះ ។

## គ. បណ្តឹងនិងបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផល

**គ.ជ.ប** ប្រើប្រាស់នីតិវិធីច្បាប់ពីរដែលខុសគ្នាទាំងស្រុង សម្រាប់បណ្តឹងដែលទាក់ទងនឹងភាពមិនប្រក្រតីនៅក្នុងថ្ងៃបោះឆ្នោត ។ បណ្តឹងខ្លះ (ដូចជា ការចាត់ទុកដោយមិនត្រឹមត្រូវថាសន្លឹកឆ្នោតជាសន្លឹកឆ្នោតមិនបានការ) ស្ថិតនៅក្រោមនីតិវិធីសម្រាប់បណ្តឹងដែលទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ចំណែកឯបណ្តឹងខ្លះទៀត (ដូចជា ការគំរាមកំហែង ការបំភិតបំភ័យ ។ល។) ត្រូវបានដោះស្រាយដោយយោងទៅតាមជំពូក១១ នៃ **ច.ប.ត.រ** (ទោសប្បញ្ញត្តិ) ដែលក្នុងនោះ **គ.ជ.ប** ប្រើប្រាស់នីតិវិធីសម្រាប់បណ្តឹងដែលទាក់ទងនឹងយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។ នីតិវិធីទាំងពីរនេះមានលក្ខណៈខុសគ្នានៅក្នុងចំណុចជាច្រើន[២៤] ។ ប៉ុន្តែ ជាអកុសល **គ.ជ.ប** មិនបានកំណត់នូវវិធានច្បាស់លាស់អំពីថាតើនីតិវិធីមួយណាដែលត្រូវយកមកអនុវត្ត ហើយក្នុងករណីណានោះទេ ។ លើសពីនេះទៀត ភាពមិនប្រក្រតីដែលទាក់ទងនឹងការប្រព្រឹត្តខុសឆ្គងដោយបុគ្គល ឬគណបក្ស ក៏អាចប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតផងដែរ ដូច្នេះហើយគួរតែត្រូវបានដោះស្រាយទៅតាមនីតិវិធីទាំងពីរនេះ ។ អ្នកពាក់ព័ន្ធភាគច្រើនបំផុតមិនបានដឹងថា នីតិវិធីពីរខុសគ្នានឹងត្រូវគេប្រើជាមូលដ្ឋានឡើយ ដោយសារតែនៅក្នុងគោលការណ៍ណែនាំ និងសៀវភៅបណ្តុះបណ្តាលទាំងអស់ដែលផលិតដោយ **គ.ជ.ប** គឺមានពណ៌នាតែអំពីនីតិវិធីសម្រាប់បណ្តឹង ដែលទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតតែប៉ុណ្ណោះ ។

**គឃ/សប** បានទទួលបណ្តឹងសរុបចំនួន ១៨៤បណ្តឹង ដែលពាក់ព័ន្ធទៅនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផល (ជាអកុសល ស្ថិតិដែលផ្តល់ដោយ **គ.ជ.ប** មិនបានបង្ហាញភាពខុសគ្នាទៅតាមនីតិវិធីដែលប្រើប្រាស់ទេ) ។

---

[២៤]

១) បណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត អាចត្រូវបានធ្វើឡើងដោយភ្នាក់ងារគណបក្ស ចំណែកឯបណ្តឹងពាក់ព័ន្ធនឹងជំពូកទី១១ អាចត្រូវធ្វើឡើងដោយបុគ្គលគ្រប់រូប ។

២) បណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ត្រូវធ្វើឡើងអោយបានមុនម៉ោង ១១:៣០ នៃថ្ងៃបន្ទាប់ពីការបោះឆ្នោត ចំណែកឯបណ្តឹងពាក់ព័ន្ធនឹងជំពូកទី១១ អាចត្រូវបានធ្វើឡើងរហូតដល់រយៈពេលបីថ្ងៃ បន្ទាប់ពីព្រឹត្តិការណ៍នេះ ។

៣) សម្រាប់បណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត **គឃ/សប** នឹងធ្វើការសម្រេចថាតើត្រូវធ្វើការរាប់សន្លឹកឆ្នោតឡើងវិញ ឬមិនរាប់ ចំណែកឯបណ្តឹងពាក់ព័ន្ធនឹងជំពូកទី១១ **គឃ/សប** អាចធ្វើកិច្ចប្រជុំសម្រុះសម្រួលក្រៅផ្លូវការមួយ ។ ប្រសិនបើការសម្រុះសម្រួលនោះបរាជ័យ ហើយករណីនេះត្រូវបានប្តឹងឧទ្ធរណ៍ **គឃ/សប** ជាបឋម ត្រូវព្យាយាមម្តងទៀត ដើម្បីឈានទៅរកការសម្រុះសម្រួល ហើយប្រសិនបើការធ្វើដូច្នេះមិនអាចទៅរួច សវនាការផ្លូវការមួយត្រូវតែធ្វើឡើង ។

៤) បណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត មានគោលបំណងដើម្បីធ្វើការរាប់សន្លឹកឆ្នោត ឬធ្វើការបោះឆ្នោតឡើងវិញ ចំណែកឯបណ្តឹងពាក់ព័ន្ធនឹងជំពូកទី១១វិញ ជាទូទៅសំដៅទៅលើបុគ្គលជាក់លាក់ ដែលនឹងត្រូវដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តខុសឆ្គង (ទណ្ឌកម្មដែលអាចធ្វើឡើងរាប់ចាប់ពីលិខិតព្រមានរហូតដល់ការផាកពិន័យ ឬរហូតដល់ឈ្មោះរបស់អ្នកប្រព្រឹត្តល្មើសត្រូវបានលុបចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ៥ ឆ្នាំ)

៥) សម្រាប់បណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលបោះឆ្នោត សេចក្តីសម្រេចរបស់ **គ.ជ.ប** គឺជាសេចក្តីសម្រេចស្ថាពរ ចំណែកឯបណ្តឹងពាក់ព័ន្ធនឹងជំពូកទី១១ នៃ **ច.ប.ត.រ** បើកផ្លូវអោយមានការប្តឹងឧទ្ធរណ៍ ។

ចំនួនពាក្យបណ្តឹងខ្ពស់បំផុតដែលដាក់ទៅ **គឃ/សប** ត្រូវបានរាយការណ៍ពីខេត្តបាត់ដំបង និងបន្ទាយមានជ័យ (២៤បណ្តឹង ក្នុងខេត្តនីមួយៗ) បន្ទាប់មក គឺខេត្តស្វាយរៀង (២៣បណ្តឹង) ក្រុងប៉ៃលិន (១៦បណ្តឹង) ខេត្តកំពត (១៤បណ្តឹង) ក្រុងភ្នំពេញ (១៣ បណ្តឹង) និងខេត្តតាកែវ (១១បណ្តឹង) ។

មួយភាគធំនៃបណ្តឹងទាំងនេះ (១៥០បណ្តឹង ស្មើនឹង ៨២%នៃបណ្តឹងទាំងអស់) ត្រូវបានប្តឹងដោយគណបក្សសមរង្ស៊ី ។៤៥% នៃបណ្តឹងទាំងនេះ ត្រូវបានច្រានចោលដោយសម្អាងលើគតិច្បាប់ ។

ករណីសរុបចំនួន ១១១ករណីបានទៅដល់ដៃគណៈកម្មការខេត្តក្រុងរៀបចំការបោះឆ្នោត (**គខ/កប**) ក្នុងនោះ ១៨ករណី គឺជាបណ្តឹងដែលដាក់ដោយផ្ទាល់ទៅ **គខ/កប** ដោយសារតែជាបណ្តឹងប្រឆាំងនឹងមន្ត្រី **គឃ/សប** និងបណ្តឹងផ្សេងទៀតពាក់ព័ន្ធនឹងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ **គឃ/សប** ។៤៧% ត្រូវបានច្រានចោលដោយសម្អាងលើគតិច្បាប់ ៣៧%ត្រូវបានច្រានចោលនៅក្រោយការបើកសវនាការ និង ១២% ត្រូវបានច្រានចោលដោយលិខិត ដោយពុំមានការបើកសវនាការ ។ នៅចុងបញ្ចប់ បណ្តឹងចំនួនតែ ៦គត់ក្នុងចំណោមបណ្តឹងទាំង ១១១បណ្តឹង ដែលត្រូវបាន **គខ/កប** ទទួលយក ។ នៅថ្នាក់ **គឃ/សប** និង **គខ/កប** នៅក្នុងខេត្តខ្លះ ១០០%នៃបណ្តឹងដែលបានទទួល ត្រូវបានច្រានចោលដោយសម្អាងលើគតិច្បាប់ ដោយគ្មានការបើកសវនាការ ។

បណ្តឹងចំនួន ៥៥ករណីបានទៅដល់ដៃ **គ.ជ.ប** ដែលក្នុងនោះ ៥២ករណី គឺជាបណ្តឹងឧទ្ធរណ៍ពី **គខ/កប** និង ៣ករណីត្រូវបានប្តឹងដោយផ្ទាល់ទៅ **គ.ជ.ប** ពីព្រោះករណីទាំងនេះជាបណ្តឹងប្រឆាំងនឹងមន្ត្រី **គខ/កប** ។ សវនាការត្រូវបានធ្វើឡើងតែក្នុងករណីចំនួន ៨ប៉ុណ្ណោះ ដោយនៅក្នុងនោះ បណ្តឹងឧទ្ធរណ៍ ៥ករណីត្រូវបានទទួលយក និង ៣ករណីទៀតត្រូវបានច្រានចោល ។ បណ្តឹងឧទ្ធរណ៍ ៤៧ករណី ត្រូវបានឆ្លើយតបតាមរយៈលិខិតដោយគ្មានការបើកសវនាការ ។ ៣៦ករណីក្នុងចំណោមបណ្តឹងឧទ្ធរណ៍ទាំងអស់នេះត្រូវបានច្រានចោល ១ករណីត្រូវបានទទួលយកដោយអន្លើ និង ១០ករណីត្រូវបានទទួលយក ។

នៅក្នុង ១៦ករណី **គ.ជ.ប** បានទទួលស្គាល់នូវការប្រព្រឹត្តខុសឆ្គងរបស់មន្ត្រីរៀបចំការបោះឆ្នោតថ្នាក់មូលដ្ឋាន (ភាគច្រើនបំផុត គឺការចេញទម្រង់ ១០១៨ ក្លែងក្លាយ) ហើយបានបញ្ជូនករណីទាំងនោះទៅក្រសួងមហាផ្ទៃ ដើម្បីចាត់វិធានការវិន័យ ។

ទោះបីជាគ្មានលិខិតបដិសេធណាមួយរបស់ **គ.ជ.ប** ដែលបានប្រាប់ដល់ដើមបណ្តឹងអំពីសិទ្ធិរបស់ពួកគេ ក្នុងការប្តឹងឧទ្ធរណ៍ (ក្នុងករណីជាបណ្តឹងដែលទាក់ទងនឹងជំពូកទី ១១) ទៅក្រុមប្រឹក្សាធម្មនុញ្ញក្តី គណបក្សសមរង្ស៊ី បានដាក់បណ្តឹងឧទ្ធរណ៍ចំនួន ៥ ករណីទៅក្រុមប្រឹក្សាធម្មនុញ្ញ ប៉ុន្តែត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញច្រានចោលទាំងអស់ដោយគ្មានការបើកសវនាការ ។

អ្នកសង្កេតការណ៍របស់ EU EOM បានរាយការណ៍ថា ការអនុវត្តរបស់មន្ត្រីរៀបចំការបោះឆ្នោតថ្នាក់ក្រោមក្នុងការដោះស្រាយបណ្តឹង គឺមានភាពខុសគ្នាជាទូទៅ ដោយបញ្ហាក្នុងប្រភេទដូចគ្នាត្រូវបានដោះស្រាយដោយប្រើនីតិវិធីខុសគ្នាដោយ **គឃ/សប** ផ្សេងៗគ្នា ។ គណៈកម្មការរៀបចំការបោះឆ្នោតខ្លះយកខ្លឹមសារនៃនីតិវិធីពីរផ្សេងគ្នាមកបញ្ចូលគ្នា ហើយខ្លះទៀតយកនីតិវិធីមិនត្រឹមត្រូវមកអនុវត្តនៅក្នុងករណីដែលត្រូវបានពិចារណា ។ នៅក្នុងករណីជាច្រើន **គឃ/សប** បដិសេធមិនទទួលយកពាក្យបណ្តឹងដោយសារមូលហេតុថា បណ្តឹងទាំងនោះត្រូវបានធ្វើឡើងនៅក្រោយម៉ោង ១១:៣០នាទី នៅថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ប៉ុន្តែបើយោងតាមច្បាប់ កាលកំណត់គឺមានរយៈពេល ៣ថ្ងៃ នៅក្រោយព្រឹត្តិការណ៍នោះ ។

ទោះបីជាមានភស្តុតាងជាក់ច្បាស់ថាភាពមិនប្រក្រតីពាក់ព័ន្ធនឹងទម្រង់១០១៨ ពិតជាបានកើតមានមែន ជាពិសេសការចេញទម្រង់ ១០១៨ អោយមនុស្សដែលពុំមានសិទ្ធិបោះឆ្នោតក៏ដោយ ក៏គណៈកម្មការបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់គ្មានឆន្ទៈនឹងដោះស្រាយករណីទាំងនេះឡើយ ។ ភាគច្រើនបំផុតនៃបណ្តឹងដែលពាក់ព័ន្ធនឹងការចេញទម្រង់ ១០១៨ ក្លែងក្លាយត្រូវបានច្រានចោល ដោយផ្អែកលើហេតុផលថា មិនមែនជាសមត្ថកិច្ចរបស់រដ្ឋបាលបោះឆ្នោត ហើយមានតែនៅក្នុងដំណើរការដោះស្រាយបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ ដែល **គ.ជ.ប** បានទទួលយកករណីជាច្រើន ហើយបានកាត់សេចក្តីថា មន្ត្រីមូលដ្ឋានពិតជាបានប្រព្រឹត្តខុសឆ្គងមែន ប៉ុន្តែបានបញ្ជូនករណីទាំងនោះទៅក្រសួងមហាផ្ទៃដើម្បីចាត់វិធានការវិន័យ ។

បញ្ហាមួយចំនួនផ្សេងទៀតត្រូវបានរកឃើញ និងរាយការណ៍ដោយអ្នកសង្កេតការណ៍ EU ។ ក្នុងចំណោមបញ្ហាទាំងនោះ រួមមាន កាលកំណត់ត្រឹមវេលាម៉ោង ១១:៣០នាទី សម្រាប់ការដាក់បណ្តឹងពាក់ព័ន្ធនឹងដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត មានរយៈពេលខ្លីពេក ដែលមិនអាចអោយភ្នាក់ងារគណបក្សប្រមូលភស្តុតាងដែលត្រូវការចាំបាច់សម្រាប់ការដាក់បណ្តឹង លិខិតអញ្ជើញចូលរួមសវនាការដែលចេញដោយ **គ.ជ.ប** ជូនកាលផ្តល់ការជូនដំណឹងដល់គណបក្សខ្លីពេក ។ ក្នុងករណីខ្លះ ការដាក់ពាក្យបណ្តឹងមិនអាចធ្វើទៅកើតដោយសារ **គឃ/សប** បិទការិយាល័យរបស់ខ្លួននៅមុនម៉ោង ១១:៣០នាទី ក្នុងករណីផ្សេងទៀត បណ្តឹងត្រូវបានច្រានចោលដោយ **គឃ/សប** ដោយសារករណីនោះមិនត្រូវបានលើកឡើងជាមុននៅឯស្ថានីយបោះឆ្នោត ខណៈដែលក្នុងករណីផ្សេងទៀតស្រដៀងគ្នានេះ បណ្តឹងបែបនេះត្រូវបានទទួលយក (បទប្បញ្ញត្តិ និងនីតិវិធីមិនបានផ្តល់ការណែនាំច្បាស់លាស់ស្តីពីចំណោទនេះទេ) ។ ហេតុផលដែលផ្តល់អោយសម្រាប់សេចក្តីសម្រេចរបស់គណៈ-កម្មការរៀបចំការបោះឆ្នោត គឺខ្លីបំផុត ដោយភាគច្រើនគ្រាន់តែថ្លែងថា "ខ្វះភស្តុតាង" ដោយពុំមានការពន្យល់បន្ថែមអំពីមូលហេតុអ្វីបានជាគណៈកម្មការធ្វើការសន្និដ្ឋានបែបនោះ ហើយក៏គ្មានការផ្តល់នូវការវែកញែកខាងផ្លូវច្បាប់ដែរ ។

## ៥. រដ្ឋបាលបោះឆ្នោត

### ក. រចនាសម្ព័ន្ធ និងសមាសភាពរបស់រដ្ឋបាលបោះឆ្នោត

រចនាសម្ព័ន្ធមួយដែលមាន ៤ថ្នាក់ គឺជាអ្នកចាត់ចែងកិច្ចការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅប្រទេសកម្ពុជា ។ រដ្ឋបាលបោះឆ្នោតត្រូវបានដឹកនាំដោយ **គ.ជ.ប** និងគាំទ្រនៅក្នុងការបំពេញការងាររបស់ខ្លួនដោយអគ្គលេខាធិការដ្ឋានមួយ ។ រចនាសម្ព័ន្ធរដ្ឋបាលបោះឆ្នោតថ្នាក់ក្រោម គឺត្រូវបានតែងតាំងតែនៅក្នុងអំឡុងពេលនៃការបោះឆ្នោតប៉ុណ្ណោះ ហើយរួមមានគណៈកម្មការខេត្តរៀបចំការបោះឆ្នោតចំនួន ២០ និងគណៈកម្មការក្រុងរៀបចំការបោះឆ្នោតចំនួន ៤ (**គខ/កប**) និងគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត (**គឃ/សប**) ចំនួន ១.៦២១ ។ **គ.ជ.ប** បង្កើតគណៈកម្មការស្ថានីយបោះឆ្នោតសរុបចំនួន ១៥.២៥៥ (PSCs) ដែលត្រូវការចាំបាច់សម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០០៨ ហើយបានជ្រើសរើស និងបណ្តុះបណ្តាលសមាជិកគណៈកម្មការបោះឆ្នោត និងមន្ត្រីរៀបចំការបោះឆ្នោតដទៃទៀតប្រមាណជាង ១០០.០០០នាក់ ។

**ច.ប.ត.រ** កំណត់ថា **គ.ជ.ប**[២៥] គឺជា "ស្ថាប័នឯករាជ្យ និងអព្យាក្រឹត្យមួយ" និងចែងថា សមាជិក **គ.ជ.ប** និង គណៈកម្មការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ "ត្រូវតែអព្យាក្រឹត្យ និងមិនលម្អៀងនៅក្នុងការបំពេញភារកិច្ចរៀបចំការបោះឆ្នោតរបស់ខ្លួន" ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី **គ.ជ.ប** ប្រឈមមុខនឹងបញ្ហាច្បាប់មួយចំនួនដែលទំនងជាប៉ះពាល់ដល់លទ្ធភាពរបស់ខ្លួនក្នុងការធានានូវការរៀបចំការបោះឆ្នោតដោយឯករាជ្យពេញលេញ : **គ.ជ.ប** ពុំមានឋានៈនៅក្នុងរដ្ឋធម្មនុញ្ញ សមាជិករបស់ខ្លួនពុំមានអាណត្តិកំណត់ ហើយក៏គ្មានការការពារប្រឆាំងនឹងការដកហូតមុខតំណែងរបស់ពួកគេដោយបំពានដែរ ។ សមាជិក **គ.ជ.ប** ត្រូវបានចាត់តាំងដោយក្រសួងមហាផ្ទៃ និងតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់គណៈរដ្ឋមន្ត្រី និងនៅពេលទទួលបានការយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាតពីសំណាក់សមាជិកនៃរដ្ឋសភា ។ ស្ថាប័នទាំងអស់ដែលបានលើកឡើងខាងលើនេះ បច្ចុប្បន្នគ្របដណ្តប់ដោយគណបក្សប្រជាជនកម្ពុជា ។ តាមរយៈការធ្វើវិសោធនកម្មទៅលើ **ច.ប.ត.រ** នាឆ្នាំ២០០៦ សមាជិកភាព **គ.ជ.ប** ត្រូវបានពង្រីកពី ៥រូប ទៅដល់ ៩រូប ។ ជាក់ស្តែង ការពង្រីកនេះមានន័យថា គណបក្សសមរង្ស៊ី ដែលជាបក្សប្រឆាំង ត្រូវបានអនុញ្ញាតអោយចាត់តាំងមនុស្ស២រូប (ទោះបីជាបើយោងតាមច្បាប់ សមាជិក **គ.ជ.ប** ទាំងអស់ ត្រូវតែឯករាជ្យ និងត្រូវតែបោះបង់ទំនាក់ទំនងរបស់ខ្លួនជាមួយគណបក្សនយោបាយក៏ដោយ) ។ ទោះជាយ៉ាងនេះក្តី ដោយសារតែសេចក្តីសម្រេចនៅក្នុង **គ.ជ.ប** ត្រូវធ្វើឡើងដោយសំឡេងភាគច្រើនធម្មតា សមាជិកដែលចាត់តាំងដោយគណបក្សប្រឆាំងអាចត្រូវគេជំទាស់បានជានិច្ច ។ ពួកគេមិនអាចសូម្បីតែលើកជាសំណើ ពីព្រោះបទបញ្ជាផ្ទៃក្នុងទាមទារអោយមានសមាជិកគណៈកម្មាធិការយ៉ាងតិច ៣រូប ទើបអាចលើកជាសំណើបាន ។

មានកង្វះជំនឿទុកចិត្តទៅលើអព្យាក្រឹត្យភាព និងភាពមិនលម្អៀងរបស់ **គ.ជ.ប** នៅក្នុងចំណោមអ្នកដែលពាក់ព័ន្ធនឹងការបោះឆ្នោត ។ ដៃគូសន្ទនាមួយចំនួនធំ ដែលភាគច្រើនមកពីគណបក្សប្រឆាំង និងអង្គការសង្គមស៊ីវិល បានសម្តែងក្តីបារម្ភចំពោះអព្យាក្រឹត្យភាព និងភាពមិនលម្អៀងរបស់រដ្ឋបាលរៀបចំបោះឆ្នោត ។ ពួកគេបានរិះគន់ថា ភាគច្រើននៃសមាជិករបស់ **គ.ជ.ប** គឺមានទំនាក់ទំនងជាមួយគណបក្សកាន់អំណាច និងថា រាល់សេចក្តីសម្រេចទាំងអស់របស់ **គ.ជ.ប** ផ្អែកទៅលើមតិភាគច្រើនជាជាងការមូលមតិ (កុងសង់ស៊ុស) ។ **គ.ជ.ប** ទទួលខុសត្រូវចំពោះការជ្រើសរើស និងការតែងតាំងមន្ត្រីបោះឆ្នោតថ្នាក់ក្រោម ។ គណបក្សប្រឆាំង[២៦] បានអះអាងថា ការជ្រើសរើសសមាជិក **គខ/កប**[២៧], **គឃ/សប** និងស្ថានីយបោះឆ្នោត គ្មានភាពអព្យាក្រឹត និងភាពមិនលម្អៀងឡើយ និងថា បេក្ខជនដែលត្រូវបានជ្រើសរើសស្ទើរតែទាំងអស់ គឺសុទ្ធតែជាសមាជិកគណបក្សប្រជាជនកម្ពុជា ។ សមាជិកភាគច្រើនបំផុតនៃរដ្ឋបាលរៀបចំការបោះឆ្នោតមិនចង់ឆ្លើយសំណួរអំពីសមាជិកភាពគណបក្សនយោបាយរបស់ពួកគេទេ[២៨] ។ សមាជិក **គឃ/សប**[២៩] ទាំងឡាយដែលបានសារភាពប្រាប់អំពី

---

[២៥] មាត្រា ១២ នៃ LEMNA ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតែឯករាជ្យនិងអព្យាក្រឹតនៅក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។ សមាជិករបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិករបស់គណៈកម្មការបោះឆ្នោតនៅគ្រប់លំដាប់ថ្នាក់ ត្រូវតែអព្យាក្រឹតនិងមិនមានភាពលម្អៀងនៅក្នុងការអនុវត្តកាតព្វកិច្ចរៀបចំការបោះឆ្នោតរបស់ខ្លួន ។

[២៦] យោងតាមគណបក្សប្រឆាំង សមាជិករបស់ពួកគេមួយចំនួនតូចតែប៉ុណ្ណោះអាចជាប់ការសម្ភាសដើម្បីចូលបម្រើការងារនៅក្នុងស្ថានីយបោះឆ្នោត ។

[២៧] សមាជិក **គខ/កប** ជាច្រើន ខ្លួនពួកគេផ្ទាល់ ឬសមាជិកគ្រួសាររបស់ពួកគេ កាន់មុខតំណែងជាន់ខ្ពស់នៅក្នុងរដ្ឋបាលខេត្ត-ក្រុង ហើយពួកគេមានទំនាក់ទំនងដោយផ្ទាល់ ឬប្រយោលជាមួយគណបក្សកាន់អំណាច ។

[២៨] សមាជិក **គខ/កប** និង **គឃ/សប** ត្រូវតែលាលែងចេញពីសមាជិកភាពគណបក្សនយោបាយក្នុងអំឡុងរយៈពេលនៃការបោះឆ្នោត (រយៈពេលនៃកិច្ចសន្យាសម្រាប់សមាជិក **គខ/កប** គឺ ៤ខែ ចំណែកឯសមាជិក **គឃ/សប** គឺ ២ខែ) ។

សមាជិកភាពរបស់ពួកគេនៅក្នុងគណបក្សនយោបាយដល់ក្រុមអ្នកសង្កេតការណ៍ EU[៣០] គឺជាសមាជិករបស់គណបក្សកាន់អំណាច ។

នៅក្នុង **ច.ប.ត.រ**[៣១] មាន ខ មួយ ដែលអនុញ្ញាតអោយមានការកែប្រែចំនួនអាសនៈ និងការបែងចែកអាសនៈនៃខេត្ត/ក្រុងនីមួយៗ ប៉ុន្តែពុំមានការកែប្រែណាមួយត្រូវបានធ្វើឡើងឡើយ ទោះបីជាចំនួនប្រជាពលរដ្ឋមានការកើនឡើងនៅមុនការបោះឆ្នោតជាតិឆ្នាំ២០០៨ក៏ដោយ ។ នៅក្នុងឆ្នាំ២០០៦ គណៈកម្មាធិការទទួលបន្ទុកលើការកំណត់អាសនៈរដ្ឋសភាមិនបានផ្តល់អនុសាសន៍អោយមានការបង្កើនចំនួនអាសនៈឡើយ ដោយសារតែកត្តាសង្គម និងសេដ្ឋកិច្ច[៣២] ។ ប៉ុន្តែ នៅស្របពេលដែលគណៈកម្មាធិការនេះមិនបានស្នើអោយមានការកែប្រែនូវចំនួនអាសនៈដែលបែងចែកសម្រាប់មួយខេត្តៗ ទោះបីជាបើយោងតាមស្ថិតិដែលផ្តល់ដោយវិទ្យាស្ថានជាតិស្ថិតិក្តីនោះ ចំនួនពលរដ្ឋក្នុងមួយខេត្តៗតម្រូវអោយមានការកែប្រែ ពីព្រោះវាមានការប្រែប្រួលខុសគ្នាច្រើននៅក្នុងចំណោមមណ្ឌលបោះឆ្នោតនានា នូវទំហំប្រជាពលរដ្ឋក្នុងមួយអាសនៈ ។ ក្នុងករណីខ្លះការប្រែប្រួលបែបនេះមិនស្របទៅនឹងគោលការណ៍នៃការមានសិទ្ធិបោះឆ្នោតស្មើគ្នា ដូចមានចែងនៅក្នុងមាត្រា ២១ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សនោះឡើយ ។

## ខ. ការរៀបចំការបោះឆ្នោត

**គ.ជ.ប** បានបង្ហាញអោយឃើញអំពីសមត្ថភាពរបស់ខ្លួនក្នុងការរៀបចំការបោះឆ្នោតដែលមានលក្ខណៈបច្ចេកទេសល្អ ។ ការធ្វើផែនការ និងការអនុវត្តនូវការជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិករដ្ឋបាលបោះឆ្នោត និងសកម្មភាពរៀបចំការបោះឆ្នោតសំខាន់ៗផ្សេងទៀតមានលក្ខណៈទាន់ពេលវេលា និងធ្វើឡើងបានយ៉ាងល្អ។ **គ.ជ.ប** បានបំពេញតាមកាលបរិច្ឆេទកំណត់សំខាន់ៗទាំងអស់ ពាក់ព័ន្ធនឹងការជ្រើសរើស ព្រមទាំងការបណ្តុះបណ្តាលបុគ្គលិករៀបចំការបោះឆ្នោត និងការផ្តល់សម្ភារៈសម្រាប់ការបោះឆ្នោត ។ ការរៀបចំស្ថានីយបោះឆ្នោត និងការបោះឆ្នោតត្រូវបានវាយតម្លៃជាវិជ្ជមានដោយ EU EOM ។

ប្រសិទ្ធភាពការងារ និងភាពប្រកបដោយវិជ្ជាជីវៈរបស់ **គខ/កប** ត្រូវបានវាយតម្លៃដោយអ្នកសង្កេតការណ៍ EU EOM ពីល្អទៅល្អណាស់ ។ មន្ត្រី **គខ/កប** មួយភាគធំបានបង្ហាញអោយឃើញនូវកម្រិតចំណេះដឹង និងការយល់ដឹងល្អប្រសើរអំពីច្បាប់ និងនីតិវិធីស្តីពីការបោះឆ្នោត ។ ការបំពេញការងាររបស់ **គឃ/សប** ភាគច្រើន ត្រូវបានវាយតម្លៃជាវិជ្ជមាន ប៉ុន្តែក្នុងកម្រិតមួយតិចជាង បើប្រៀបធៀបជាមួយ **គខ/កប** ។ **គឃ/សប** ក្នុងចំនួនដ៏ច្រើនគួរអោយកត់សម្គាល់ មានទីតាំង

---

[២៩] ក្នុងចំណោម **គឃ/សប** ចំនួន ១១ ដែលត្រូវបានសាកសួរអំពីសមាជិកភាពក្នុងគណបក្សនយោបាយរបស់ពួកគេ ក្នុង ៩ករណី សមាជិកភាគច្រើនបានសារភាពថាពួកគេជាសមាជិកគណបក្សប្រជាជនកម្ពុជា ក្នុងមួយករណី ពួកគេបានអះអាងថាគ្មានសមាជិកភាពនៅក្នុងគណបក្សណាមួយទេ ហើយនៅក្នុងមួយករណីទៀត ពួកគេបដិសេធមិនព្រមឆ្លើយសំណួរឡើយ ។ កិច្ចសាកសួរនេះត្រូវបានធ្វើឡើងដោយអ្នកសង្កេតការណ៍ EU ជាមួយនឹងប្រធាន និង/ឬសមាជិក **គឃ/សប** នៅក្នុងខេត្តកំពង់ឆ្នាំង ។ របកគំឃើញប្រហាក់ប្រហែលគ្នានេះ ត្រូវបានរាយការណ៍ដោយអ្នកសង្កេតការណ៍រយៈពេលវែងរបស់ EU នៅក្នុងខេត្តបាត់ដំបង និងខេត្តស្វាយរៀង ។

[៣០] អភិបាលខេត្តស្វាយរៀង ដែលជាប្រធានគណបក្សប្រជាជនកម្ពុជាប្រចាំខេត្តផងដែរនោះ បានផ្តល់ការពន្យល់ដល់ក្រុមអ្នកសង្កេតការណ៍ EU EOM ។ នៅពេលដែលសួរថា ហេតុអ្វីបានជាបុគ្គលិក **គឃ/សប** និងស្ថានីយបោះឆ្នោតជាង ៩០% នៅក្នុងខេត្តនេះ សុទ្ធតែមកពីគណបក្សប្រជាជនកម្ពុជា ដូចដែលគណបក្សប្រឆាំងបានអះអាង លោកអភិបាលខេត្តបានឆ្លើយថា "សមាជិកគណបក្សរបស់លោកមានកម្រិតវប្បធម៌ខ្ពស់ និងថា វាជារឿងធម្មតាទេ ដែលពួកគេត្រូវបានជ្រើសរើសអោយធ្វើជាសមាជិកបុគ្គលិក **គឃ/សប** និង ស្ថានីយបោះឆ្នោត ពីព្រោះភាគច្រើននៃពួកគេគឺជាគ្រូបង្រៀន" ។

[៣១] **ច.ប.ត.រ** មាត្រា ៧ ។

[៣២] អនុលោមតាម **ច.ប.ត.រ** គណៈកម្មាធិការមានសិទ្ធិក្នុងការគិតពិចារណាទៅលើកត្តាប្រជាសាស្ត្រ ភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ច ។

ស្ថិតនៅតាមតំបន់ជនបទដែលមានស្តង់ដារហេដ្ឋារចនាសម្ព័ន្ធកម្រិតទាប ហើយការបំពេញការងាររបស់ពួកគេត្រូវបានកត់សម្គាល់ដោយកង្វះធនធានហិរញ្ញវត្ថុ និងឧបករណ៍គ្រប់គ្រាន់ ។

មុខងាររដ្ឋបាលជាច្រើនដែលទាក់ទងនឹងដំណើរការបោះឆ្នោតមិនត្រូវបានបំពេញដោយ **គ.ជ.ប** ទេ ។ ច្បាប់តម្រូវអោយ **គ.ជ.ប** ធ្វើប្រតិភូកម្មអំណាចលើការងារចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតទៅអោយក្រុមប្រឹក្សាឃុំសង្កាត់[៣៣] ។ មន្ត្រីក្រុមប្រឹក្សាឃុំសង្កាត់ចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ហើយឃុំសង្កាត់មានភារកិច្ចទទួលខុសត្រូវក្នុងការចេញបែបបទបញ្ជាក់អត្តសញ្ញាណ ឬទម្រង់ ១០១៨ ដល់អ្នកបោះឆ្នោត ។ ករណីជាច្រើនអំពីអាកប្បកិរិយាមិនប្រកបដោយលក្ខណៈវិជ្ជាជីវៈរបស់មន្ត្រីឃុំសង្កាត់ត្រូវបានកត់សម្គាល់ និងរាយការណ៍ដល់អ្នកសង្កេតការណ៍ EU ។ បើគិតពិចារណាដល់ក្តីបារម្ភដែលបានលើកឡើងនៅក្នុងការបោះឆ្នោតលើកមុនៗ វាមិនសមស្របទេដែល **គ.ជ.ប** នៅបន្តអនុញ្ញាតអោយមេភូមិចូលរួមនៅក្នុងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដល់អ្នកបោះឆ្នោតនោះ ដោយសារតែមេភូមិខ្វះនូវភាពមិនលម្អៀង : មេភូមិជាច្រើនបានចូលរួមនៅក្នុងសកម្មភាពឃោសនារកសំឡេងឆ្នោតរបស់គណបក្សកាន់អំណាច ។

ការធ្វើផែនការ និងការអនុវត្តសកម្មភាពរៀបចំការបោះឆ្នោតទាំងអស់មានលក្ខណៈទាន់ពេលវេលា និងត្រូវបានធ្វើឡើងបានយ៉ាងល្អ ។ បុគ្គលិករៀបចំការបោះឆ្នោតភាគច្រើន គឺជាគ្រូបង្រៀន និងជាបុគ្គលិករដ្ឋបាលមូលដ្ឋាន ដែលមានបទពិសោធន៍នៅក្នុងការបោះឆ្នោតលើកមុនៗ ។ នៅក្នុងឃុំមួយចំនួនធំ ចំនួនបេក្ខជនសុំចូលបម្រើការងារស្មើនឹងចំនួនបុគ្គលិករៀបចំការបោះឆ្នោតដែលត្រូវការ ។ នៅក្នុងករណីទាំងនេះ បេក្ខជនទាំងអស់ត្រូវបានជ្រើសរើស ដោយមិនគិតអំពីលក្ខណៈ-សម្បត្តិ ។ ចំនួននៃការដាក់ពាក្យសុំចូលបម្រើការងារទាប អាចបណ្តាលមកពីកត្តាជាច្រើន ដូចជា ប្រាក់បៀវត្សរ៍ទាបសម្រាប់ការបណ្តុះបណ្តាល និងការងារពួកគេត្រូវធ្វើ កង្វះធនធានមនុស្សនៅក្នុងតំបន់ជនបទមួយចំនួន និងការខ្លាចមិនហ៊ានទទួលខុសត្រូវ ។

**គ.ជ.ប** បានចាប់ផ្តើមជ្រើសរើសសមាជិកគណៈកម្មការស្ថានីយបោះឆ្នោត PSC/BCC[៣៤] ពីថ្ងៃទី០១ ខែកក្កដា ។ អ្នកសង្កេតការណ៍ EU បានវាយតម្លៃការបណ្តុះបណ្តាលរបស់ **គ.ជ.ប** ដែលផ្តល់អោយដល់បុគ្គលិករៀបចំការបោះឆ្នោតទាំងអស់ស្តីពីដំណើរការនៃការបោះឆ្នោត (ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត) ថាធ្វើឡើងបានយ៉ាងល្អ ។ នៅក្នុងដំណាក់កាលទី១ គ្រូបង្គោលរបស់ **គ.ជ.ប** ចំនួន ២៤រូប ត្រូវបានបណ្តុះបណ្តាលនៅចុងខែមិថុនា ។ ដំណាក់កាលទី២ រួមមានការបណ្តុះបណ្តាលជាដំណាក់ៗចំនួន ៣ថ្នាក់ សម្រាប់សមាជិក **គខ/កប, គឃ/សប** និង PSCs ។

## គ. ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

[៣៣] មាត្រា ៥៣ (ថ្មី) នៃ **ច.ប.ត.រ** គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនទៅអោយក្រុមប្រឹក្សាឃុំសង្កាត់ដើម្បីបំពេញមុខងារជំនួសខ្លួន នៅក្នុងការពិនិត្យមើលឡើងវិញនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោតទៅក្នុងបញ្ជីអ្នកបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំសង្កាត់ នីមួយៗ ។

[៣៤] សមាជិកគណៈកម្មការស្ថានីយបោះឆ្នោត ក្លាយទៅជាសមាជិកគណៈកម្មការរាប់សន្លឹកឆ្នោតនៅពេលដែលការបោះឆ្នោតប្រព្រឹត្តទៅចប់សព្វគ្រប់ ។ ការរាប់សន្លឹកឆ្នោតត្រូវបានធ្វើឡើងនៅឯស្ថានីយបោះឆ្នោត មិនមែននៅការិយាល័យគណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតដូចកាលនៅក្នុងការបោះឆ្នោតជាតិលើកមុនឡើយ ។

ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច បានប្រព្រឹត្តទៅនៅចន្លោះពីថ្ងៃទី០៥ និងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ ។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (VIN) ប្រាប់អ្នកបោះឆ្នោតអំពីកាលបរិច្ឆេទនៃការបោះឆ្នោត ស្ថានីយបោះឆ្នោតដែលពួកគេបានចុះឈ្មោះដើម្បីទៅបោះឆ្នោត និងលេខរៀងនៅលើបញ្ជីបោះឆ្នោតរបស់ពួកគេ ។ យោងតាមស្ថិតិរបស់ **គ.ជ.ប**[៣៥] ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតចំនួន ៨៥% នៃប័ណ្ណព័ត៌មានអ្នកបោះឆ្នោតទាំងអស់ត្រូវបានចែក ហើយប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដែលនៅសេសសល់មិនទាន់ចែក ត្រូវបានទុកនៅការិយាល័យ **គឃ/សប** សម្រាប់អោយអ្នកបោះឆ្នោតទៅយក ។ នៅក្នុងបរិបទនៃលទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកបោះឆ្នោតលើកទី២ ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) ដែលបានវាយតម្លៃភាពត្រឹមត្រូវ[៣៦] របស់បញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ ថាបាន ៨៤,១% ជាអត្រាមួយដែលហាក់ដូចជាខ្ពស់បន្តិច ។ ទោះបីជាមានការវាយតម្លៃដូច្នេះ ដៃគូសន្ទនារបស់ EOM បានត្អូញត្អែរអំពីការមិនចែកប័ណ្ណព័ត៌មានដល់អ្នកគាំទ្ររបស់ពួកគេ និងអាកប្បកិរិយាប្រកាន់បក្សពួកនិយមរបស់មេភូមិដែលចូលរួមក្នុងដំណើរការនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។ បញ្ហាគឺថា អ្នកបោះឆ្នោតក្នុងចំនួនច្រើនគួរអោយកត់សម្គាល់ ជាពិសេសអ្នកបោះឆ្នោតនៅតាមតំបន់ជនបទមិនបានដឹងថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះមិនអាចយកទៅប្រើប្រាស់ជាឯកសារសម្គាល់អត្តសញ្ញាណដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោតបាននោះទេ ហើយពួកគេបានជឿថា ប្រសិនបើគ្មានប័ណ្ណនេះទេ ពួកគេនឹងមិនអាចបោះឆ្នោតបានឡើយ[៣៧] ។

## ឃ. លិខិតបញ្ជាក់អត្តសញ្ញាណ (ទម្រង់ ១០១៨)

លិខិតបញ្ជាក់អត្តសញ្ញាណ ឬហៅថាទម្រង់១០១៨ គឺជាឯកសារមួយក្នុងចំណោមឯកសារចំនួន ១១ ដែលមានចែងនៅក្នុង **ច.ប.ត.រ**[៣៨] ដែលអ្នកបោះឆ្នោតអាចប្រើប្រាស់ដើម្បីសម្គាល់ខ្លួននៅក្នុងស្ថានីយបោះឆ្នោត ។ លិខិតនេះត្រូវបានចេញអោយដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច ប៉ុន្តែគ្មានឯកសារសម្គាល់ខ្លួនដែលមានសុពលភាពផ្សេងក្រៅពីនេះ ។ ដើម្បីទទួលបានទម្រង់១០១៨ អ្នកបោះឆ្នោតត្រូវអមដោយអ្នកបោះឆ្នោត២នាក់រស់នៅក្នុងឃុំ-សង្កាត់ជាមួយគ្នា ដែលអាចបញ្ជាក់អត្តសញ្ញាណ អាយុ ឬទីលំនៅរបស់អ្នកស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណ ។ លើសពីនេះទៅទៀត គេត្រូវផ្តល់រូបថតពីរសន្លឹកដែលត្រូវបិទ និងប្រថាប់ត្រាភ្ជាប់នឹងទម្រង់ ១០១៨ ។ យោងតាមច្បាប់ ទម្រង់ ១០១៨ អាចចេញដោយស្មៀនឃុំសង្កាត់រហូតដល់ថ្ងៃទី២៦ ខែកក្កដា មួយថ្ងៃនៅមុនថ្ងៃបោះឆ្នោត ។ អ្នកបោះឆ្នោតក៏ត្រូវបានអនុញ្ញាតអោយប្រើទម្រង់ ១០១៨ ដែលចេញអោយកាលពីក្នុងអំឡុងនៃការបោះឆ្នោតលើកមុនបាន ផងដែរ ។

---

[៣៥] តួលេខនៃការចែក ខុសគ្នាច្រើនគួរអោយកត់សម្គាល់រវាងខេត្តមួយទៅខេត្តមួយ ដោយមានចាប់ពី ៦០% នៅក្នុងទីក្រុងភ្នំពេញ រហូតដល់ ៩៥% នៅក្នុងខេត្តស្វាយរៀង ។ ការចែកទទួលបានភាគរយខ្ពស់នៅតាមខេត្តជនបទ ។

[៣៦] ចំនួនអ្នកបោះឆ្នោតដែលត្រូវបានបញ្ជាក់ថាបានចុះឈ្មោះរួច មាន ៨៤,១% ក្នុងចំណោមឈ្មោះទាំងអស់នៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ សូមមើល NDI's VRA II លទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់ឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ។

[៣៧] ពលរដ្ឋ ៤៩% មិនបានដឹងថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតមិនអាចយកទៅប្រើប្រាស់ជាឯកសារសម្គាល់អត្តសញ្ញាណដើម្បីបោះឆ្នោតបាននោះទេ (របាយការណ៍ពិនិត្យផ្ទៀងផ្ទាត់ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតដំណាក់កាលទី២ របស់ NDI ថ្ងៃទី១៣ មិថុនា) ។ តួលេខនេះអាចនឹងមានការថយចុះ ដោយសារតែព័ត៌មានចុះផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មានរបស់ **គ.ជ.ប** ។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនីមួយៗ មានសរសេរថា អ្នកបោះឆ្នោតមិនត្រូវបានតម្រូវអោយកាន់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដើម្បីបោះឆ្នោតទេ [*ប័ណ្ណនេះមិនអាចប្រើជំនួសឯកសារបញ្ជាក់អត្តសញ្ញាណសាមីខ្លួនបានឡើយ*] ។

[៣៨] **ច.ប.ត.រ :** មាត្រា ៥៤ (ថ្មី) ចំណុច ខ (កថាខណ្ឌទី៣) ចំណុច ឃ (កថាខណ្ឌទី២) ចំណុច ង (កថាខណ្ឌទី២) មាត្រា ៥២ (ថ្មី)

កម្មវិធីថ្នាក់ជាតិមួយដែលគាំទ្រមូលនិធិដោយ UNDP បានផ្តល់លទ្ធភាពដល់ការចេញអត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋខ្មែរភាគច្រើន[៣៩] ។ ដូច្នេះហើយ តម្រូវការដើម្បីចេញទម្រង់ ១០១៨ មិនគួរមានកម្រិតខ្ពស់ដូចក្នុងអំឡុងពេលនៃការបោះឆ្នោតលើកមុនៗឡើយ ។

ទោះបីជាមានការរិះគន់ចំពោះការចេញទម្រង់ ១០១៨ ក្នុងអំឡុងពេលនៃការបោះឆ្នោតលើកមុនក្តី **គ.ជ.ប** និងអាជ្ញាធរពាក់ព័ន្ធមិនបានផ្តួចផ្តើមគំនិត និងបង្កើតវិធានការការពារនៅមុនការបោះឆ្នោតឆ្នាំ២០០៨នេះឡើយ ។ ដោយសារតែមិនមានវិធានការការពារគ្រប់គ្រាន់ (ដូចជា លេខរៀង ការរក្សាកំណត់ត្រានៃទម្រង់ដែលបានប្រើប្រាស់ ជាដើម) ចំពោះការចេញទម្រង់ ១០១៨ ដំណើរការនេះបើកចំហអោយមានការក្លែងបន្លំ ។ កង្វះនូវការកត់ត្រាអំពីការប្រើប្រាស់ទម្រង់ ១០១៨ ធ្វើអោយគណបក្សនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងទៀត មិនអាចដឹងពីទីកន្លែងដែលអាចនឹងកើតមានបញ្ហានេះបានឡើយ ដែលកង្វះនេះបន្ថែមទម្ងន់ទៅលើពាក្យបណ្តឹងរបស់ពួកគេ ។ ហើយគណៈកម្មការរៀបចំការបោះឆ្នោតពុំមានមូលដ្ឋានការពិតណាមួយដើម្បីធ្វើការសម្រេចលើបណ្តឹងទាំងនោះឡើយ ។

គណបក្សនយោបាយប្រឆាំងបានរាយការណ៍អំពីការប្រើប្រាស់ដ៏ច្រើននូវទម្រង់ ១០១៨ ដោយអ្នកបោះឆ្នោត នៅក្នុងថ្ងៃបោះឆ្នោត ។ យោងតាមសេចក្តីណែនាំរំឭកដែលចេញដោយ **គ.ជ.ប, គឃ/សប** ត្រូវតែសហការជាមួយក្រុមប្រឹក្សាឃុំសង្កាត់ដើម្បីរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយដែលមានចុះចំនួនត្រឹមត្រូវនៃមនុស្សដែលត្រូវបានចេញទម្រង់ ១០១៨ អោយ ។ របាយការណ៍នេះ ត្រូវបញ្ជូនទៅ **គ.ជ.ប** ហើយអ្នកពាក់ព័ន្ធទាំងអស់ នឹងត្រូវជូនដំណឹងអំពីខ្លឹមសារនៃរបាយការណ៍នេះ ។ **គ.ជ.ប** បានផ្តល់អោយអ្នកសង្កេតការណ៍ EU នូវទម្រង់បែបបទមួយដែលមានចុះចំនួនសរុបនៃទម្រង់ ១០១៨ ដែលចេញអោយអ្នកបោះឆ្នោតនៅក្នុងខេត្តនីមួយៗ ដែលមានចំនួនសរុប ៣២៤.៨១៩ ប៉ុន្តែ មិនអាចនិយាយបានថាតើទិន្នន័យនេះប្រមូលបានមកដោយរបៀបណា ឬធ្វើការបែងចែកខ្ទង់លម្អិតឡើយ ។

ករណីជាច្រើននៃការចេញទម្រង់១០១៨ មិនប្រក្រតី និងករណីជាច្រើនដែលអ្នកបោះឆ្នោតប្រើប្រាស់ទម្រង់១០១៨ ក្លែងក្លាយដើម្បីបោះឆ្នោត ត្រូវបានរាយការណ៍ដល់អ្នកសង្កេតការណ៍ EU នៅក្រោយការបោះឆ្នោត ។ គណបក្សប្រឆាំងក៏បានត្អូញត្អែរផងដែរអំពីការចេញទម្រង់ ១០១៨ អោយអ្នកគាំទ្រគណបក្សកាន់អំណាច ។

អ្នកសង្កេតការណ៍ EU បានឃើញភស្តុតាងនៃទម្រង់ ១០១៨ ចំនួន ១០០ច្បាប់ ដែលចេញអោយមនុស្សដែលមានឈ្មោះខុសពីនៅលើអត្តសញ្ញាណប័ណ្ណរបស់ពួកគេ ។ ទម្រង់ទាំងនេះត្រូវបានចេញនៅក្នុងតំបន់ខុសៗគ្នានៅក្នុងប្រទេស ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយមនុស្សដែលពាក់ព័ន្ធ ភាគច្រើនបំផុតនៃពួកគេបានគូសបញ្ជាក់ប្រាប់ថា ទម្រង់នេះត្រូវបានចេញអោយក្នុងអំឡុងពេលរសៀលនៃថ្ងៃបោះឆ្នោត ដើម្បីពួកគេអាចបោះឆ្នោតជំនួសអ្នកបោះឆ្នោតផ្សេងទៀតដែលមិនបានបង្ហាញខ្លួន ។ ពួកគេខ្លះនិយាយថា ពួកគេត្រូវបានចេញទម្រង់នេះអោយនៅល្ងាចថ្ងៃ២៦ កក្កដា ហើយត្រូវបានប្រាប់អោយទៅបោះឆ្នោតនៅពេលព្រឹកព្រលឹម ។ ពួកគេទាំងអស់បានបញ្ជាក់ថា ពួកគេត្រូវបានប្រាប់អោយបោះឆ្នោតជូន គណបក្សប្រជាជនកម្ពុជា ដោយមនុស្សដែលចេញទម្រង់ ១០១៨នោះអោយ ។ អ្នកសង្កេតការណ៍ EU ជឿជាក់ថា ការចេញទម្រង់ ១០១៨ ក្លែងក្លាយ គឺជាបាតុភាព ដែលមានរាលដាល ប៉ុន្តែទោះជាយ៉ាងនេះក្តី ពុំមានតួលេខជាក់លាក់ណាមួយត្រូវបានកំណត់ឡើយ ។

[៣៩] ចំនួនប៉ាន់ស្មានសរុបនៃប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោត គឺ ៨.៥៨៥.៦៧០ ហើយគិតមកទល់នឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ ក្រសួងមហាផ្ទៃចេញអត្តសញ្ញាណប័ណ្ណអោយប្រជាពលរដ្ឋបានចំនួន ៧.៧០៣.០៦៥ ។ ប្រភព : ក្រសួងមហាផ្ទៃ ។

### ង. តម្លាភាព

ជាទូទៅ កម្រិតនៃតម្លាភាពនៅក្នុងការរៀបចំការបោះឆ្នោត ត្រូវបានវាយតម្លៃជាវិជ្ជមានដោយ EU EOM ។ ដើម្បីកែលម្អការទំនាក់ទំនងព័ត៌មាន **គ.ជ.ប** បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាទៀងទាត់ជាមួយនឹងតំណាងគណបក្សនយោបាយ និងសង្គមស៊ីវិល ។ កិច្ចប្រជុំជាទៀងទាត់ស្រដៀងគ្នានេះ ក៏ត្រូវបានធ្វើឡើងផងដែរនៅថ្នាក់ខេត្ត និងថ្នាក់ឃុំ ហើយកិច្ចប្រជុំទាំងនោះត្រូវបានវាយតម្លៃជាវិជ្ជមានដោយអ្នកដែលពាក់ព័ន្ធនឹងការបោះឆ្នោត ។ កំណត់ហេតុនៃកិច្ចប្រជុំទាំងនេះ មានជាបើកចំហ និងត្រូវបានផ្តល់ជូនគណបក្ស ឬអង្គការមិនមែនរដ្ឋាភិបាលណាមួយទៅតាមការស្នើសុំ ។

អ្នកតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងស្រុកក្នុងចំនួនដ៏ខ្ពស់ ត្រូវបានផ្តល់សិទ្ធិអោយធ្វើការសង្កេតការណ៍ការបោះឆ្នោតដោយគ្មានការលំបាក ឬឧបសគ្គណាមួយដែលត្រូវបានគេរាយការណ៍អោយដឹងឡើយ ។ គណបក្សនយោបាយចំនួន ៦[៤០] បានផ្ញើបញ្ជីឈ្មោះអ្នកតំណាងគណបក្សរបស់ខ្លួនទៅអោយ **គខ/កប** និង **គឃ/សប** ។ ជាសរុប **គ.ជ.ប** បានផ្តល់ការទទួលស្គាល់ដល់ភ្នាក់ងារតំណាងគណបក្សនយោបាយចំនួនជាង ១១៧.០០០នាក់[៤១] ហើយគណបក្សនយោបាយអាចបញ្ជូនឈ្មោះដែលខ្លួនចាត់តាំងរហូតដល់ថ្ងៃទី២៦ ខែកក្កដា ។ ទាំងភ្នាក់ងារតំណាងគណបក្សនយោបាយ និងទាំងអ្នកសង្កេតការណ៍មានសិទ្ធិចេញចូលការិយាល័យគណៈកម្មការបោះឆ្នោតថ្នាក់ក្រោម នៅក្នុងថ្ងៃបោះឆ្នោត និងនៅក្រោយថ្ងៃបោះឆ្នោត ។ ការព្រួយបារម្ភនៅតែមានអំពីកិច្ចប្រជុំរបស់ **គ.ជ.ប** ដែលមិនត្រូវបានបើកអោយអ្នកសង្កេតការណ៍ចូលរួម ហើយកំណត់ហេតុនៃកិច្ចប្រជុំទាំងនោះដែលមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ ក្នុងវិធានការវិជ្ជមានមួយដើម្បីធានានូវតម្លាភាព **គ.ជ.ប** បានផ្សព្វផ្សាយលទ្ធផលសម្រាប់ស្ថានីយបោះឆ្នោតនីមួយៗនៅលើគេហទំព័រវែបសាយត៍របស់ខ្លួន ។ ព័ត៌មានដែលផ្តល់នៅលើគេហទំព័រវែបសាយត៍របស់ **គ.ជ.ប** មានការកែលម្អគួរអោយកត់សម្គាល់ ។

## ៦. ការចុះឈ្មោះអ្នកបោះឆ្នោត

### ក. សិទ្ធិក្នុងការបោះឆ្នោត

ពលរដ្ឋខ្មែរគ្រប់រូបដែលមានអាយុ ១៨ឆ្នាំ ឬលើសពី ១៨ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត ដែលបានចុះបញ្ជីនៅក្នុងឃុំសង្កាត់ដែលខ្លួននឹងបោះឆ្នោត និងដែលមិនកំពុងជាប់ពន្ធនាគារ ឬស្ថិតនៅក្រោមអាណាព្យាបាល មានសិទ្ធិបោះឆ្នោត ។ បញ្ជីឈ្មោះអ្នកបោះឆ្នោតអចិន្ត្រៃយ៍មួយត្រូវបានបង្កើតឡើងនៅក្រោយការបោះឆ្នោតឃុំសង្កាត់នាឆ្នាំ២០០២ ។ ការរក្សាបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ គឺជាភារកិច្ចទទួលខុសត្រូវរបស់ **គ.ជ.ប** ។

---

[៤០] គណបក្សនយោបាយចំនួន៦ បានចាត់តាំងភ្នាក់ងារតំណាងរបស់ខ្លួនធ្វើជាអ្នកសង្កេតការណ៍ ៖ គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សនរោត្តមរណឫទ្ធិ គណបក្សសិទ្ធិមនុស្ស គណបក្សសមរង្ស៊ី និងគណបក្សហង្សដាវ៉ាចលនាប្រជាធិបតេយ្យ ។

[៤១] តួលេខនេះគិតទាំងតំណាងគណបក្សពេញសិទ្ធិ និងតំណាងគណបក្សបម្រុង ពីព្រោះគណបក្សនីមួយៗដែលបានចុះបញ្ជីសម្រាប់ការបោះឆ្នោតអាចចាត់តាំងភ្នាក់ងារពីររូប ប៉ុន្តែភ្នាក់ងារតែមួយរូបប៉ុណ្ណោះអាចមានវត្តមាននៅក្នុងស្ថានីយបោះឆ្នោត ។

## ខ. នីតិវិធីនៃការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត

ប្រៀបធៀបទៅនឹងការបោះឆ្នោតមុនៗ ចំនួនអ្នកចេញទៅបោះឆ្នោតដែលមានកម្រិតទាបគួរអោយកត់សម្គាល់ នៅក្នុងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០០៧ បាននាំអោយអ្នកពាក់ព័ន្ធចោទសំណួរទៅលើគុណភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ ភាពចម្រូងចម្រាសរវាងគណបក្សនយោបាយ និង **គ.ជ.ប** មិនបាននាំទៅរកសេចក្តីសម្រេចដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់តាមលក្ខណៈវិទ្យាសាស្ត្រ ឬការវាយតម្លៃផ្ទៃក្នុងផ្សេងទៀត ទៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយអាជ្ញាធររៀបចំការបោះឆ្នោតឡើយ ។ ដោយជឿថា បញ្ជីឈ្មោះអ្នកបោះឆ្នោតពិតជាមានឈ្មោះអ្នកបោះឆ្នោតជាច្រើនដែលមិនមានសុពលភាព **គ.ជ.ប** បានសម្រេចចិត្តធ្វើបច្ចុប្បន្នភាព និងសម្អាតបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយលុបចោលនូវឈ្មោះដែលចុះច្រើនដង មនុស្សដែលបានចុះឈ្មោះសាជាថ្មីនៅក្នុងឃុំផ្សេង និងអ្នកបោះឆ្នោតដែលបានស្លាប់ តាមរយៈការរៀបចំជា "បញ្ជីលុបឈ្មោះ" បណ្តោះអាសន្នមួយ ដែលគេស្គាល់ថា ជាទម្រង់ ១០២៥ ។

បញ្ជីលុបឈ្មោះត្រូវបានធ្វើឡើងនៅក្នុងខែសីហា ឆ្នាំ២០០៧ នៅមុនពេលការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំបានកើតឡើងនៅចន្លោះពីថ្ងៃទី១៥ ខែកញ្ញា រហូតដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៧ ។ ក្នុងអំឡុងពេលនៃការធ្វើបច្ចុប្បន្នភាព បញ្ជីលុបឈ្មោះ និងបញ្ជីឈ្មោះអ្នកបោះឆ្នោតបឋមត្រូវបានបិទនៅទូទាំងប្រទេស ដោយអនុញ្ញាតអោយពលរដ្ឋស្នើសុំការកែតម្រូវ ប្រសិនបើ ចាំបាច់ ។ **គ.ជ.ប** បញ្ជាក់សុពលភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ ។ យោងតាម **គ.ជ.ប** អ្នកបោះឆ្នោតថ្មីចំនួន ៩១១.៨៨១នាក់ ត្រូវបានចុះឈ្មោះ ទិន្នន័យនៃអ្នកបោះឆ្នោតចំនួន ៣៦២.៦៣៦នាក់ ត្រូវបានកែតម្រូវ អ្នកបោះឆ្នោតចំនួន ៧៩.៦៨៨នាក់ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីលុបឈ្មោះ និងឈ្មោះចំនួន ៥៨៧.១៦០ ត្រូវបានលុបចោល ។ ចំនួនអ្នកបោះឆ្នោតសរុបនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយសម្រាប់ការបោះឆ្នោតឆ្នាំ២០០៨ គឺ ៨.១២៥.៥២៩នាក់ ដែលកើនពី ៧.៧៩៩.៣៧១នាក់សម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០០៧ ។

ចំនួនដ៏ខ្ពស់នៃឈ្មោះដែលត្រូវបានលុបចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតបានក្លាយជាបញ្ហាចម្រូងចម្រាស ដោយសារតែគណបក្សនយោបាយប្រឆាំង និងអង្គការសង្គមស៊ីវិល បានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងអំពីការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយបង្អស់ ជាពិសេសចំពោះចំនួនខ្ពស់នៃការលុបឈ្មោះ ដែលមានចំនួនខ្ពស់គួរអោយកត់សម្គាល់ បើប្រៀបធៀបទៅនឹងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឆ្នាំ២០០៦[៤២] ។ ដៃគូសន្ទនាជាមួយ EU EOM ជាច្រើនបានរិះគន់ដំណើរការនៃការចងក្រងបញ្ជីលុបឈ្មោះ ដោយថ្លែងថា ដំណើរការដែលបានកំណត់ដោយបញ្ញត្តិច្បាប់មិនត្រូវបានអនុវត្តតាមឡើយ នៅក្នុងការកំណត់នូវឈ្មោះដែលត្រូវលុប ហេតុដូច្នេះហើយបើកចំហលទ្ធភាពអោយមានការលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយមិនត្រឹមត្រូវ ។ គណបក្សនយោបាយប្រឆាំងបានអះអាងថា ចំនួនដ៏ខ្ពស់នៃឈ្មោះដែលត្រូវបានលុបចេញពីបញ្ជី ភាគច្រើនគឺជាអ្នកគាំទ្រគណបក្សប្រឆាំង ។

ជាវិធានការពិនិត្យគុណភាព ទម្លាប់នៃការអនុវត្តជាអន្តរជាតិ គឺនៅក្រោយពេលនៃការកែប្រែធំដុំទៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវមានការផ្ទៀងផ្ទាត់ដើម្បីពិនិត្យមើលកម្រិតនៃកំហុស ។ ក្នុងករណីនៅប្រទេសកម្ពុជា វិធានការបែប

[៤២] ក្នុងអំឡុងពេលនៃការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ២០០៦ ឈ្មោះសរុបចំនួន ១៦០.២៦០ ត្រូវបានលុបចោល ។

នេះតែមួយគត់ គឺការពិនិត្យផ្ទៀងផ្ទាត់ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត (VRA)[៤៣] ពីរដំណាក់កាល ដែលត្រូវបានធ្វើឡើងដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដោយមានកិច្ចគាំទ្រពីអង្គការ UNDP និងម្ចាស់ជំនួយអន្តរជាតិ ។ លទ្ធផលចុងក្រោយនៃការពិនិត្យផ្ទៀងផ្ទាត់នេះត្រូវបានពន្យារពេល ហើយត្រូវបានបង្ហាញនៅក្នុងខែមិថុនា ឆ្នាំ២០០៨ ដែលកៀកនឹងថ្ងៃបោះឆ្នោតទៅហើយ ។ លទ្ធផលនោះ បានបង្ហាញថា បញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ រួមមានពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតចំនួន ៨៧,៩% ។ លទ្ធផលនេះស្ទើរតែស្មើគ្នានឹងលទ្ធផលនៃ VRA លើកទីមួយរបស់ NDI ធ្វើឡើងនៅមុនការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំលើកមុន ។ ការពិនិត្យផ្ទៀងផ្ទាត់នេះក៏បានរកឃើញផងដែរថា ចំនួននៃទិន្នន័យដែលបានការ ឬមានសុពលភាព បានកើនពី ៧៧,៣% ទៅដល់ ៨៤,១% ។ ទិន្នន័យដែលនៅសេសសល់រួមមាន ៧,៦%នៃអ្នកបោះឆ្នោតដែលអាចនឹងបានផ្លាស់ទីលំនៅ, ៧,៦% ជាទិន្នន័យគ្មានសុពលភាព និង ០,៧% ជាអ្នកបោះឆ្នោតដែលបានស្លាប់ ។ លទ្ធផលនៃការផ្ទៀងផ្ទាត់ឈ្មោះនៅលើបញ្ជីឈ្មោះដែលត្រូវលុប ដែលគេស្គាល់ថាជាទម្រង់១០២៥ បង្ហាញថា ៩,៨%នៃអ្នកដែលមានសិទ្ធិបោះឆ្នោតត្រូវបានដកចេញពីបញ្ជីលុបឈ្មោះនោះនៅក្នុងពេលនៃការធ្វើបច្ចុប្បន្នភាពចុងក្រោយបំផុតនេះ ដែលតំណាងអោយចំនួនអ្នកបោះឆ្នោតសរុប៥៧.៤០១នាក់ ឬស្មើនឹង ០,៧% នៃបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០០៨ ។

នៅក្រោយរបកគំហើញនេះ NDI និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួម[៤៤] បានផ្តល់អនុសាសន៍ដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយលើកឡើងថា "វាគឺជាការទទួលខុសត្រូវរបស់ **គ.ជ.ប** ដែលត្រូវការពារសិទ្ធិក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោតគ្រប់រូប" និងបានស្នើអោយ **គ.ជ.ប** ចាត់វិធានការចាំបាច់នានាដែលអាចធ្វើទៅបាន ដើម្បីដាក់បញ្ចូលឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានលុបទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០០៨វិញ ។

ឆ្លើយតបទៅនឹងការពិនិត្យផ្ទៀងផ្ទាត់របស់ NDI, **គ.ជ.ប** បានធ្វើការវាយតម្លៃផ្ទាល់ខ្លួន ទៅលើលទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់របស់ NDI និងបានរិះគន់ NDI និងដៃគូរបស់ខ្លួនចំពោះការខកខានមិនបានផ្តល់លទ្ធផល និងអនុសាសន៍ទាំងនេះដល់ **គ.ជ.ប** អោយបានទាន់ពេលវេលាតាមការព្រមព្រៀងនៅចុងខែមេសា ឆ្នាំ២០០៨ និងចំពោះការមិនប្រើប្រាស់ទិន្នន័យដែលត្រឹមត្រូវ[៤៥] ។ យោងតាម **គ.ជ.ប** ចំនួនពិតប្រាកដនៃអ្នកបោះឆ្នោតដែលត្រូវបានលុបឈ្មោះចេញដោយការភាន់-ច្រលំនៅក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់របស់ NDI គួរមានត្រឹមតែ ៤៩.៣៨០នាក់ ឬ ៨,៤% (០,៦% នៃចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច) ។ **គ.ជ.ប** ក៏បានធ្វើការស៊ើបអង្កេតទៅលើឈ្មោះដែលត្រូវបានកំណត់នៅក្នុងរបាយការណ៍ពិនិត្យផ្ទៀង

---

[៤៣] ការពិនិត្យផ្ទៀងផ្ទាត់ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតលើកទី១ របស់ NDI ត្រូវបានធ្វើឡើងនៅមុនពេលនៃការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំតែបន្តិចប៉ុណ្ណោះ គឺនៅក្នុងខែកញ្ញា ឆ្នាំ២០០៧ សម្រាប់បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានប្រើប្រាស់នៅក្នុងការបោះឆ្នោតឆ្នាំ២០០៧ ។ ការពិនិត្យផ្ទៀងផ្ទាត់នោះបានរកឃើញថា បញ្ជីឈ្មោះមានលក្ខណៈពេញលេញ ដោយមានពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតចំនួន ៨៨,៨%ត្រូវបានចុះឈ្មោះ និងមានភាពត្រឹមត្រូវ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី បញ្ជីឈ្មោះនេះមិនសូវមានបច្ចុប្បន្នភាពទេ ដោយមានទិន្នន័យតែ ៧៧,៣%ប៉ុណ្ណោះនៅក្នុងបញ្ជីនេះដែលមានសុពលភាព ។ ខណៈដែលតួលេខចុងក្រោយនេះបានគាំទ្រដល់ការប៉ាន់ស្មានរបស់ **គ.ជ.ប** ថា ទិន្នន័យប្រមាណ ៦៥០.០០០ គួរត្រូវបានលុបចោល អ្នកសរសេររបាយការណ៍រកឃើញនេះក៏បានព្រមានផងដែរថា "ការរកឃើញនៃ VRA បង្កើតនូវការព្រួយបារម្ភថា អ្នកបោះឆ្នោតដែលផ្លាស់លំនៅបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍មួយចំនួនក្នុងចំណោមអ្នកបោះឆ្នោតដែលផ្លាស់លំនៅបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ចំនួន ១០,៥% អាចនឹងត្រូវមានឈ្មោះនៅក្នុងបញ្ជីលុបឈ្មោះរបស់ **គ.ជ.ប**" ។

[៤៤] សកម្មជនរបស់ **ខុមហ្វ្រែល និចហ្វិច** ដោយមានជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ បានចូលរួមនៅក្នុងដំណើរការ NDI VRA ។

[៤៥] យោងតាម **គ.ជ.ប** ចំនួនឈ្មោះនៅលើបញ្ជីលុបឈ្មោះ (ទម្រង់ ១០២៥) មានតែ ៥០៣.៤៧០នាក់ប៉ុណ្ណោះ ចំណែកឯឈ្មោះដែលលុបចេញចំនួន ៨២.២៥៣នាក់ ដែលនៅសល់ គឺស្ថិតនៅក្នុងទម្រង់ ១០១៦ និង ១០១៧ ដែលត្រូវបានចុះដោយផ្ទាល់ដោយអ្នកបោះឆ្នោត ។

ផ្ទាត់របស់ NDI ថាត្រូវបានលុបចេញពីបញ្ជីដោយមិនត្រឹមត្រូវនោះផងដែរ ។ **គ.ជ.ប** មិនបានផ្តល់នូវតួលេខ ឬការវាយតម្លៃផ្ទៃក្នុងណាមួយទៅលើដំណើរការនៃការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតឡើយ ហើយគ្រាន់តែបាន"ទទួលស្គាល់ជាផ្លូវការថា អាចមានអ្នកបោះឆ្នោតមួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយមិនត្រឹមត្រូវ និងដោយអចេតនា"[៤៦] ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ **គ.ជ.ប** បានបដិសេធមិនអនុវត្តតាមអនុសាសន៍របស់ NDI និងអ្នកសង្កេតការណ៍ក្នុងស្រុកទេ ដោយផ្តល់ហេតុផលថា ដោយសារកង្វះពេលវេលា បញ្ហាផ្លូវច្បាប់[៤៧] និងបញ្ហាប្រតិបត្តិការ គេមិនអាចប្រើប្រាស់បញ្ជីឈ្មោះអ្នកបោះឆ្នោតបន្ថែមបានឡើយ ។ ដើម្បីបញ្ចូលឈ្មោះដែលលុបចេញទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតវិញ **គ.ជ.ប** នឹងត្រូវធ្វើការស៊ើបអង្កេតករណីទាំងអស់ម្តងមួយៗ និងបញ្ចូលឈ្មោះនីមួយៗនោះទៅក្នុងបញ្ជីវិញ ដោយផ្អែកលើឯកសារច្បាប់ត្រឹមត្រូវ ធ្វើ/បោះពុម្ពបញ្ជីឈ្មោះអ្នកបោះឆ្នោតបន្ថែមសម្រាប់ស្ថានីយបោះឆ្នោតចំនួន ១៥.២៥៥ស្ថានីយ ចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតថ្មី ចេញនីតិវិធី និងសេចក្តីណែនាំបន្ថែមថ្មីដល់បុគ្គលិករៀបចំការបោះឆ្នោត និងរៀបចំការបណ្តុះបណ្តាលថ្មី ដើម្បីជៀសវាងនូវការភាន់ច្រលំ និងកំហុសឆ្គង[៤៨] ។

VRA របស់ NDI ក៏បានវាយតម្លៃផងដែរទៅលើអត្រាកំហុសនៅក្នុងការបញ្ចូលទិន្នន័យ[៤៩] របស់អ្នកបោះឆ្នោតនីមួយៗ ។ ទិន្នន័យស្តីពីភាពត្រឹមត្រូវនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត បង្ហាញថា ៨៧,៩% មានឈ្មោះត្រូវគ្នា, ៩០% មានអាសយដ្ឋានត្រូវគ្នា, ៧៩%មានថ្ងៃខែឆ្នាំកំណើតត្រូវគ្នា និង ៩៦,៥% មានភេទត្រូវគ្នា ។ ចំពោះបញ្ហានេះ **គ.ជ.ប** បានសម្រេចផ្តល់ការប៉ះប៉ូវចំពោះភាពខ្វះចន្លោះនៅក្នុងការបញ្ចូលទិន្នន័យដើម្បីធានាថា គ្មានអ្នកបោះឆ្នោតណាមួយនឹងត្រូវបានបដិសេធមិនអោយបោះឆ្នោតដោយសារតែភាពខុសគ្នានៃទិន្នន័យរបស់អ្នកបោះឆ្នោតទាំង៤ចំណុចនេះឡើយ ។ **គ.ជ.ប** បានចេញសេចក្តីណែនាំមួយស្តីពីរបៀបសម្រេចចិត្តស្តីពីលក្ខខណ្ឌតម្រូវសម្រាប់ការបោះឆ្នោត ក្នុងករណីដែលទិន្នន័យមួយ ពីរ ឬបី ក្នុងចំណោមទិន្នន័យទាំង៤ចំណុចនេះ មានភាពមិនត្រូវគ្នា ។

ទោះបីជាមានការរិះគន់ដ៏ខ្លាំងក្លាអំពីភាពមិនប្រក្រតី និងភាពខ្វះចន្លោះ នៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតពីសំណាក់មន្ត្រីតំណាងជាន់ខ្ពស់នៃគណបក្សប្រឆាំងក្តី អ្នកសង្កេតការណ៍ EU មិនបានរកឃើញភស្តុតាងដែលបញ្ជាក់អំពីការលុបឈ្មោះអ្នកគាំទ្រគណបក្សប្រឆាំងជាលក្ខណៈប្រព័ន្ធឡើយ ។ ប៉ុន្តែ នៅក្នុងស្ថានីយបោះឆ្នោតចំនួន ១៩% នៅក្នុងចំណោមស្ថានីយបោះឆ្នោតទាំងអស់ដែលអ្នកសង្កេតការណ៍ EU EOM បានចុះទៅពិនិត្យនៅក្នុងអំឡុងថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតបានត្អូញត្អែរអំពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ហើយអ្នកសង្កេតការណ៍ក្នុងស្រុកបានថ្លែងនៅក្នុងរបាយការណ៍របស់ពួកគេថា ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនត្រឹមត្រូវ គឺជាបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗនៃដំណើរការរៀបចំការបោះឆ្នោតជាតិឆ្នាំ២០០៨នេះ ។

---

[៤៦] សូមមើល : លិខិតឆ្លើយតបរបស់ **គ.ជ.ប** ចំពោះ VRA របស់ NDI នៅលើគេហទំព័រវែបសាយត៍របស់ **គ.ជ.ប** ។

[៤៧] ក្នុងករណីមួយ **គ.ជ.ប** បានបញ្ចូលឈ្មោះអ្នកបោះឆ្នោតចំនួន ១.១៣៨នាក់ នៅសង្កាត់ស្ទឹងមានជ័យ ក្រុងភ្នំពេញ ទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតវិញ នៅក្រោយកាលបរិច្ឆេទកំណត់តាមផ្លូវច្បាប់ ដើម្បីគោរពសិទ្ធិក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោតទាំងនេះ ។ **គ.ជ.ប** បានស្តីបន្ទោសមន្ត្រីសង្កាត់ចំពោះការធ្វើអោយមានកំហុសនៅក្នុងអំឡុងពេលចុះឈ្មោះ ។

[៤៨] សូមមើល : លិខិតឆ្លើយតបរបស់ **គ.ជ.ប** ចំពោះ VRA របស់ NDI នៅលើគេហទំព័រវែបសាយត៍របស់ **គ.ជ.ប** ។

[៤៩] មានទិន្នន័យចំនួន ៤ ស្តីអំពីអ្នកបោះឆ្នោតនីមួយៗនៅក្នុងបញ្ជី (គឺ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត និង ភេទ) ។

នៅក្នុងអំឡុងដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការចុះឈ្មោះអ្នកបោះឆ្នោត បណ្តឹងចំនួន ៧ ត្រូវបានធ្វើឡើងនៅឃុំសង្កាត់ ។ នៅថ្នាក់ **គ.ជ.ប** បណ្តឹងសរុបចំនួន ៥២បណ្តឹង ត្រូវបានទទួល ដែលបណ្តឹងទាំងអស់នេះ ត្រូវបានប្តឹងដោយគណបក្សសមរង្ស៊ី ដោយស្នើសុំអោយដាក់បញ្ចូលឈ្មោះរាប់ពាន់នាក់ទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតវិញ ឬលុបចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត : បណ្តឹងចំនួន ៣១ ក្នុងចំណោមបណ្តឹងទាំងអស់នេះត្រូវបានច្រានចោល និងបណ្តឹងចំនួន ២១ទៀត ត្រូវបានទទួលយក ។

ក្នុងអំឡុងដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតបឋម បណ្តឹងសរុបចំនួន ៧៥៩ ត្រូវបានធ្វើឡើង នៅតាមឃុំសង្កាត់ ក្នុងនោះបណ្តឹងចំនួន ៦៩៧ ត្រូវបានទទួលយក និង ៦២ ត្រូវបានច្រានចោល ។

**គ.ជ.ប** បានទទួលបណ្តឹងឧទ្ធរណ៍ចំនួន ៦ ដែលប្តឹងសុំអោយលុបឈ្មោះមួយចំនួនចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ **គ.ជ.ប** បានទទួលយកបណ្តឹងឧទ្ធរណ៍ចំនួន ៣ ច្រានចោល ១បណ្តឹង និងច្រានចោលដោយអន្លើចំនួន ២បណ្តឹង (មានន័យថា **គ.ជ.ប** ទទួលយល់ព្រមលុបតែឈ្មោះមួយចំនួនប៉ុណ្ណោះក្នុងចំណោមឈ្មោះទាំងអស់ដែលមានរាយនៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍នោះ) ។ បណ្តឹងឧទ្ធរណ៍ចំនួន ៣ ត្រូវបានប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងនោះមានបណ្តឹងមួយដែលត្រូវបានដកចេញវិញ នៅក្រោយពេលដាក់រួច ។ ចំពោះករណីពីរផ្សេងទៀត ក្រុមប្រឹក្សាធម្មនុញ្ញបានបើកសវនាការនៅថ្ងៃទី២១ និង២២ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដែលក្នុងនោះក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចតម្កល់សេចក្តីសម្រេចរបស់ **គ.ជ.ប** ដោយហេតុផលថា ភាគីដើមបណ្តឹងមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់[៥០] ។

ដោយសារតែពុំមានតួលេខពាក់ព័ន្ធណាមួយដែលត្រូវបានផ្តល់ដោយ **គ.ជ.ប** និងដោយពិចារណាទៅលើលទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់ការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់ NDI និងការពិតដែលថា មានអ្នកបោះឆ្នោត ៧៩.៦៨៨នាក់ ដែលត្រូវតែដកឈ្មោះចេញពីបញ្ជីលុបឈ្មោះដើម្បីបោះឆ្នោតបាននោះ EU EOM សន្និដ្ឋានថា មានអ្នកបោះឆ្នោតក្នុងចំនួនមួយគួរអោយកត់សម្គាល់ ដែលត្រូវបានគេបំបាត់សិទ្ធិក្នុងការចូលរួមការបោះឆ្នោតឆ្នាំ២០០៨ ដោយការភាន់ច្រលំ ឬ ដោយកំហុសឆ្គង ។

## ៧. ការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត

បេក្ខជនត្រូវតែជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច មានអាយុ ២៥ឆ្នាំ ជាពលរដ្ឋខ្មែរតាំងពីកំណើត មានទីលំនៅនៅក្នុងប្រទេសកម្ពុជា និងត្រូវបានតែងតាំងដោយគណបក្សនយោបាយមួយ ។ អ្នកបោះឆ្នោតប្រភេទខ្លះ ក្នុងនោះរួមមានមន្ត្រីរាជការ បុគ្គលិកនគរបាល និងយោធា ព្រះសង្ឃ មន្ត្រីរៀបចំការបោះឆ្នោត និងសមាជិកនៃតុលាការថ្នាក់ខ្ពស់ជាច្រើន មិន

[៥០] នៅសង្កាត់គីឡូម៉ែត្រលេខ ៦ ក្រុងភ្នំពេញ អ្នកបោះឆ្នោតចំនួន ៣.២៨២នាក់ត្រូវបានលុបឈ្មោះចេញពីក្នុងចំណោមអ្នកបោះឆ្នោតដែលបានចុះបញ្ជីឈ្មោះរួចចំនួន ១០.៦៨៨នាក់ ។ អនុប្រធានក្រុមប្រឹក្សាសង្កាត់នេះ (មកពីគណបក្សសមរង្ស៊ី) បានអះអាងថា ការលុបនេះផ្អែកទៅលើការវាយតម្លៃដែលមានភាពលម្អៀងរបស់មេភូមិ ។ សមាជិកក្រុមប្រឹក្សាសង្កាត់មកពីគណបក្សសមរង្ស៊ីបានដាក់ពាក្យបណ្តឹងទៅ **គ.ជ.ប** ប្រឆាំងជំទាស់នឹងការលុបឈ្មោះមនុស្សចំនួន ២.០០០នាក់ ក្នុងចំណោមមនុស្សដែលត្រូវបានលុបឈ្មោះទាំងនេះ ។ **គ.ជ.ប** បានសម្រេចផ្តល់ការយល់ព្រមដល់ការលុបឈ្មោះនេះ ហើយបន្ទាប់មក សមាជិកក្រុមប្រឹក្សាសង្កាត់បានប្តឹងឧទ្ធរណ៍ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញបានតម្កល់សេចក្តីសម្រេចរបស់ **គ.ជ.ប** បើទោះបីជាមានវត្តមានអ្នកភូមិ ៥០នាក់ ដែលចូលរួមក្នុងសវនាការដើម្បីបញ្ជាក់អំពីភាពមានសិទ្ធិស្របច្បាប់ ក្នុងការចុះឈ្មោះក៏ដោយ ។

អាចធ្វើជាបេក្ខជនឈរឈ្មោះបោះឆ្នោតបានឡើយ ។ ប្រសិនបើពួកគេមានបំណងចង់ឈរឈ្មោះនៅក្នុងការបោះឆ្នោត ពួកគេត្រូវតែលាលែងពីមុខតំណែងរបស់ពួកគេក្នុងរយៈពេលយ៉ាងតិចបំផុត ៧ថ្ងៃ នៅមុនការចាប់ផ្តើមនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។

គណបក្សនយោបាយដាក់បញ្ជីបេក្ខជនដាច់ដោយឡែកពីគ្នា សម្រាប់មណ្ឌលបោះឆ្នោតនីមួយៗក្នុងចំណោមមណ្ឌលបោះឆ្នោតទាំង២៤ខេត្តក្រុង ។ ចំនួនបេក្ខជននៅលើបញ្ជីបេក្ខជននីមួយៗត្រូវតែស្មើគ្នានឹងចំនួនអាសនៈដែលត្រូវបានបែងចែកសម្រាប់មណ្ឌលបោះឆ្នោតនោះ ។ គណបក្សនយោបាយ ពុំត្រូវបានតម្រូវអោយត្រូវតែឈរឈ្មោះនៅគ្រប់មណ្ឌលបោះឆ្នោតទាំងអស់នោះទេ ប៉ុន្តែចំនួនបេក្ខជនសរុបដែលបានចុះបញ្ជីត្រូវតែមានចំនួនយ៉ាងតិចបំផុត ១ភាគ៣ នៃចំនួនអាសនៈសរុបនៅក្នុងរដ្ឋសភា (គឺ ៤១) ។ បន្ថែមពីលើនេះ គណបក្សត្រូវតែចុះបញ្ជីឈ្មោះបេក្ខជន"បម្រុង" ដែលត្រូវមានចំនួនស្មើគ្នានឹងចំនួនបេក្ខជន "ពេញសិទ្ធិ" ប៉ុន្តែយ៉ាងតិចបំផុត ៣រូប នៅក្នុងមណ្ឌលបោះឆ្នោតដែលមានអាសនៈតែ១ ។ ដើម្បីអាចចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅ **គ.ជ.ប** បាន គណបក្សនយោបាយត្រូវតែចុះបញ្ជីនៅក្រសួងមហាផ្ទៃ។ គណបក្សនយោបាយសរុបចំនួន ៤៥ ត្រូវបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ។

គណបក្សនយោបាយចំនួន ១២ បានចុះបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ដំណើរការនៃការចុះបញ្ជីបានប្រព្រឹត្តទៅពីថ្ងៃទី២៨ ខែមេសា ដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ។ ប្រៀបធៀបទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ ដែលមានគណបក្សចំនួន ២៣ បានចូលរួម សម្រាប់ការបោះឆ្នោតលើកនេះមានគណបក្សតែ ១១គត់ដែលបានចុះឈ្មោះចូលរួមប្រកួតប្រជែង ។ គណបក្សសង្គមខ្មែរនិយម (UPCP) ត្រូវបានបដិសេធដោយ **គ.ជ.ប** ដោយមូលហេតុថា បេក្ខជនជាច្រើនដែលគណបក្សនេះបានដាក់ពង្រាយ ពុំមានឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការទេ[៥១] ។

គណបក្សតូចៗចំនួន ៣ទៀត[៥២] ពុំអាចចុះបញ្ជីឈ្មោះគ្រប់ចំនួនសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗឡើយ ។ នៅក្នុងចំណោមចំនួនបេក្ខជនសរុប ២១៣នាក់ដែលត្រូវបានបដិសេធនៅទូទាំងបញ្ជីគណបក្សនយោបាយទាំងមូល មានបេក្ខជនជាង ២០០នាក់[៥៣] ត្រូវបានបដិសេធដោយសារតែ **គ.ជ.ប** រកឈ្មោះពួកគេមិនឃើញនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ ។ ការបាត់បង់នូវបេក្ខជនតែមួយរូបដោយសារការច្រានចោលពីបញ្ជីគណបក្ស នឹងធ្វើអោយខូចសុពលភាពដល់បញ្ជីបេក្ខជនឈរឈ្មោះទាំងមូល សម្រាប់មណ្ឌលបោះឆ្នោតដែលពាក់ព័ន្ធនោះ ។ មានតែគណបក្សដែលអាចដាក់ជំនួសបេក្ខជនដែលត្រូវគេបដិសេធចោលតែប៉ុណ្ណោះ ដែលបានទទួលជោគជ័យក្នុងការចុះបញ្ជីឈ្មោះបេក្ខជនពេញលេញ ។

---

[៥១] **គ.ជ.ប** បដិសេធការចុះបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សសង្គមខ្មែរនិយម (UPCP) ដោយមូលហេតុថា បេក្ខជនជាច្រើននៃគណបក្សនេះមិនបានបំពេញតាមលក្ខខណ្ឌដែលតម្រូវអោយមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ បេក្ខជនដែលនៅសល់នៅក្នុងបញ្ជី មានតែ ៣៨នាក់ប៉ុណ្ណោះ តិចជាងចំនួនអប្បបរមា ៤១នាក់ដែលតម្រូវដោយ **ច.ប.ត.រ** ។ បណ្តឹងឧទ្ធរណ៍របស់គណបក្សនេះប្រឆាំងនឹងសេចក្តីសម្រេចរបស់ **គ.ជ.ប** ត្រូវបានច្រានចោលដោយក្រុមប្រឹក្សាធម្មនុញ្ញ នៅក្រោយសវនាការជាសាធារណៈ នាថ្ងៃទី២៦ ខែឧសភា ។

[៥២] គណបក្សសង្គមយុត្តិធម៌ បានចុះបញ្ជីបេក្ខជនពេញសិទ្ធិ ៤៦រូប នៅក្នុងមណ្ឌលបោះឆ្នោតចំនួន ៨, គណបក្សខ្មែរឈប់ក្រ ចុះបញ្ជីបេក្ខជនពេញសិទ្ធិ ៦០រូប នៅក្នុងមណ្ឌលបោះឆ្នោតចំនួន ៨ និងគណបក្សខ្មែរសាធារណរដ្ឋ ចុះបញ្ជីបេក្ខជនពេញសិទ្ធិនៅក្នុងមណ្ឌលបោះឆ្នោតចំនួន ១០ ។

[៥៣] ភាគច្រើននៃបេក្ខជនឈរឈ្មោះទាំងនោះបង្ហាញប័ណ្ណដែលចេញអោយដោយក្រុមប្រឹក្សាឃុំសង្កាត់ ដែលបញ្ជាក់អំពីស្ថានភាពចុះបញ្ជីឈ្មោះរបស់ពួកគេ ។

គណបក្សសង្គមខ្មែរនិយម (UPCP) និងគណបក្សនយោបាយ៣ផ្សេងទៀត ដែលបញ្ជីបេក្ខជនមិនត្រូវបានចុះឈ្មោះអោយដោយ **គ.ជ.ប** បានត្អូញត្អែរអំពីសេចក្តីណែនាំដែលធ្វើអោយមានការយល់ច្រលំ និងចំណាត់ការមិនស្មើភាពគ្នាដោយ **គ.ជ.ប** ទៅលើគណបក្សតូចៗ ។ គណបក្សនយោបាយត្រូវបានបង្គាប់អោយផ្តល់នូវប័ណ្ណដែលចេញអោយដោយក្រុមប្រឹក្សាឃុំសង្កាត់ ដើម្បីបញ្ជាក់អំពីការចុះឈ្មោះបេក្ខជននៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ ។ ក្នុងករណីមួយចំនួន គណបក្សនយោបាយបានត្អូញត្អែរថា ប័ណ្ណនេះមិនត្រូវបានផ្តល់អោយដល់អនាគតបេក្ខជនរបស់ខ្លួន ហើយឈ្មោះរបស់ពួកគេត្រូវបានច្រានចោល នៅក្រោយពេលដែល **គ.ជ.ប** បានធ្វើការពិនិត្យផ្ទៀងផ្ទាត់រកឈ្មោះរបស់ពួកគេនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ ។ ការវាយតម្លៃរបស់អ្នកសង្កេតការណ៍ EU បានរកឃើញថា បញ្ហានេះមិនប៉ះពាល់ធំដុំទៅលើសិទ្ធិរបស់គណបក្សនយោបាយដើម្បីចូលរួមក្នុងការបោះឆ្នោតឡើយ ។

គណបក្សនយោបាយធំៗគឺ គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តមរណឫទ្ធិ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សប្រជាធិបតេយ្យខ្មែរ និងគណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ បានដាក់បេក្ខជនឈរឈ្មោះនៅគ្រប់ ខេត្តក្រុងទាំងអស់សម្រាប់អាសនៈរដ្ឋសភាចំនួន ១២៣ ។

បញ្ជីបេក្ខជនមានចំនួនបេក្ខជនឈរឈ្មោះជាតំណាងរាស្ត្រសរុបចំនួន ១.១៦២រូប (២.៤៧៨រូបជាបេក្ខជនបម្រុង) ដែលក្នុងនោះ ១៧២រូប (១៤,៨%) គឺជាស្ត្រី ។

## ៨. យុទ្ធនាការឃោសនារកសំឡេងឆ្នោត និងបរិយាកាសនៅមុនការបោះឆ្នោត

### ក. សាវតារស្តីពីបរិយាកាសនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោត

លក្ខណៈនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោត ឆ្លុះបញ្ចាំងអោយឃើញអំពីបរិបទជាក់លាក់ ដែលយុទ្ធនាការទាំងនោះកើតឡើង ។ នៅក្នុងករណីប្រទេសកម្ពុជា EU EOMs មុនៗ បានរកឃើញនូវឧប្បត្តិហេតុដែលទាក់ទងនឹងរឿងនយោបាយកម្រិតខ្ពស់ក្នុងអំឡុងពេលនៃការឃោសនារកសំឡេងឆ្នោត ហើយ EU EOM លើកនេះ បានកត់សម្គាល់នូវរបាយការណ៍ដែលចេញដោយអង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិចាប់តាំងពីដើមឆ្នាំ២០០៨មក ដោយចាត់ប្រភេទនៃឧប្បត្តិហេតុហិង្សាមួយចំនួនថាជាប់ទាក់ទងនឹងការបោះឆ្នោត និងដោយទាញចំណាប់អារម្មណ៍ទៅលើការចុះចូលរបស់អ្នកនយោបាយគណបក្សប្រឆាំងមួយចំនួនជាមួយនឹងគណបក្សប្រជាជនកម្ពុជា[៥៤] ។ ខណៈដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ពេញលេញនូវសិទ្ធិ សេរីភាពជាមូលដ្ឋាន អ្នកជំនាញការផ្នែកសិទ្ធិមនុស្សជាតិ និងអន្តរជាតិយល់ស្របគ្នាថា ការគោរពចំពោះសិទ្ធិអស់ទាំងនេះ គឺជាទូទៅមិនមានឡើយ : ជាធម្មតាមានការរំលោភសិទ្ធិមនុស្សជាញឹកញាប់ និងធ្ងន់ធ្ងរ ក្នុងនោះរួមមានការបំភិតបំភ័យ ការបង្វែរទៅជារឿងព្រហ្មទណ្ឌនូវបទល្មើសនានាដែលគួរតែដោះស្រាយជាបទល្មើសរដ្ឋប្បវេណី និងការប្រើប្រាស់កម្លាំងច្រើនហួសហេតុ ។ ស្ថានភាពបែបនេះកាន់តែធ្ងន់ធ្ងរដោយសារតែវប្បធម៌នៃការមិនដាក់ទោសពៃរ៍ចំពោះជនល្មើស រួមជាមួយនឹងការអនុវត្តច្បាប់ទន់ខ្សោយ និងប្រព័ន្ធតុលាការដែលមានភាពលម្អៀង ។ ជាការគួរអោយព្រួយបារម្ភ គឺថា

[៥៤] សូមអានសេចក្តីថ្លែងការណ៍ព័ត៌មានរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៨ និងសេចក្តីថ្លែងការណ៍រួមដោយ **ខុមហ្វ្រែល និចហ្វិច** និង CHRAC ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ សម្រាប់ឧទាហរណ៍នៃរបាយការណ៍ទាំងនេះ ។

ករណីព្រហ្មទណ្ឌធ្ងន់ធ្ងរជាច្រើននៅតែបន្តត្រូវបានគេដោះស្រាយតាមរយៈការសម្រុះសម្រួល ដូច្នេះហើយជនល្មើសមិនត្រូវបានផ្តន្ទាទោសក្នុងលក្ខណៈមួយដែលសមស្របទៅនឹងភាពធ្ងន់ធ្ងរនៃអំពើឧក្រិដ្ឋរបស់ពួកគេឡើយ ។ ជាមួយគ្នានេះដែរ ក៏មានការយល់ស្របជាទូទៅថា ឧប្បត្តិហេតុហិង្សាជាច្រើនមានចរិតលក្ខណៈជារឿងនយោបាយ ។

គិតមកទល់នឹងពេលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ នេះ ប្រទេសកម្ពុជាមានការយឺតយ៉ាវអស់រយៈពេល ៦ឆ្នាំហើយ ក្នុងការដាក់ជូនរបាយការណ៍របស់ខ្លួនទៅគណៈកម្មាធិការសិទ្ធិមនុស្ស ស្តីពីអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ (ICCPR)[៥៥] ។ ការបង្កើតគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា កំពុងស្ថិតក្នុងកិច្ចពិភាក្សា ប៉ុន្តែដោយសារកង្វះឆន្ទៈនៅថ្នាក់នយោបាយជាន់ខ្ពស់ចំពោះកំណែទម្រង់ប្រព័ន្ធតុលាការ[៥៦] ដៃគូសន្ទនាជាច្រើនមានមន្ទិលថា ការផ្តួចផ្តើមគំនិតបែបនេះ នឹងគ្មានន័យអ្វីទេនៅក្នុងបរិការណ៍បច្ចុប្បន្ននេះ ។

ឧបសគ្គធំៗដែលរារាំងដល់ការសម្រេចគោលដៅរដ្ឋធម្មនុញ្ញស្តីពីនយោបាយពហុបក្សតាមរយៈការបោះឆ្នោត នៅតែមាននៅឡើយ ។ បន្ថែមពីលើកត្តាដែលបានរៀបរាប់ខាងលើនេះ ការខ្វះចន្លោះនៅក្នុងតម្លាភាព និងគណនេយ្យភាព ព្រមទាំងលក្ខខណ្ឌកំហិតដែលកំណត់លើសង្គមស៊ីវិល និងគណបក្សនយោបាយ ដើម្បីធ្វើប្រតិបត្តិការនៅក្រៅក្របខ័ណ្ឌនៃរយៈពេលធ្វើយុទ្ធនាការឃោសនារកសំឡេងឆ្នោត--កម្លាំងដែលចាំបាច់នៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស-- រារាំងរចនាសម្ព័ន្ធទាំងនេះ មិនអោយវិវឌ្ឍន៍ និងចូលរួមចំណែកដល់ការបង្កើតទីលានប្រកួតប្រជែងស្មើភាពគ្នា ។

ចុងបញ្ចប់ អ្នកសង្កេតការណ៍ EU EOM ត្រូវបានប្រាប់ និងបង្ហាញអំពីឧទាហរណ៍នៃរបៀបរបបដែលឃុំ ឬភូមិដែលដឹកនាំដោយបុគ្គលដែលមានសម្ព័ន្ធភាពជាមួយគណបក្សប្រឆាំង មិនបានទទួលកម្រិតដូចគ្នានៃការវិនិយោគរបស់រដ្ឋាភិបាល និងលក្ខណៈដែលមនុស្សដែលត្រូវគេសន្និដ្ឋានថាមានការជាប់ទាក់ទងនឹងគណបក្សប្រឆាំងទាំងនេះ ត្រូវបានគេបំភិតបំភ័យ និងគំរាមកំហែងជាប់ជាប្រចាំ ។

## ខ. ទិដ្ឋភាពទូទៅនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោត

យុទ្ធនាការឃោសនារកសំឡេងឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ បានចាប់ផ្តើមនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៨ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការធ្វើយុទ្ធនាការឃោសនារកសំឡេងឆ្នោតបានចាប់ផ្តើមជាច្រើនខែមុននេះទៅទៀត ដោយមេដឹកនាំជាន់ខ្ពស់របស់គណបក្សកាន់អំណាចគឺគណបក្សប្រជាជនកម្ពុជា ប្រើប្រាស់ពិធីសម្ពោធអោយប្រើប្រាស់សាលារៀន មន្ទីរពេទ្យ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត[៥៧] ជាវេទិកាឃោសនា

---

[៥៥] ប្រទេសកម្ពុជាគួរតែបញ្ជូនរបាយការណ៍ទៅអោយគណៈកម្មាធិការសិទ្ធិមនុស្ស នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០២ និងរបាយការណ៍លើកទី២ ក៏ត្រូវបញ្ជូនទៅដែរ ពីព្រោះភាគីរដ្ឋត្រូវបានតម្រូវអោយបញ្ជូនរបាយការណ៍ទាំងនេះនៅរៀងរាល់ ៤ឆ្នាំម្តង ។ សម្រាប់សេចក្តីលម្អិត : http://www.unhchr.ch/tbs/doc.nsf/NewhvVAllSPRByCountry?OpenView&Start=1&Count=250&Expand=29.2#29.2

[៥៦] ស្ថានភាពនីតិរដ្ឋ និងចំណុចខ្វះចន្លោះនៅក្នុងប្រព័ន្ធតុលាការត្រូវបានបរិយាយយ៉ាងក្បោះក្បាយនៅក្នុងរបាយការណ៍ចុងក្រោយបង្អស់របស់តំណាងពិសេសនៃអគ្គ-លេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (A/HRC/7/42) របាយការណ៍ក្រសួងការបរទេសអាមេរិក ស្តីពីការអនុវត្តសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០០៧ ព្រមទាំងរបាយការណ៍ "សិទ្ធិមនុស្សនៅកម្ពុជា : ស្ថានភាពក្លែងក្លាយនៃយុត្តិធម៌" ដែលចេញដោយអង្គការសិទ្ធិមនុស្សកម្ពុជា **លីកាដូ** ។ ជាងនេះទៅទៀត ការស្ទង់មតិអំពីអំពើពុករលួយនៅកម្ពុជាឆ្នាំ១៩៩៧ របស់អង្គការតម្លាភាពអន្តរជាតិ បានរកឃើញថា មានអំពើពុករលួយខ្លាំងក្លាបំផុតនៅក្នុងប្រព័ន្ធតុលាការថ្នាក់ទាប ។

[៥៧] នៅក្នុងករណីជាច្រើន កិច្ចអន្តរាគមន៍ទាំងនេះត្រូវបានផ្តល់ហិរញ្ញវត្ថុដោយម្ចាស់ជំនួយអន្តរជាតិ ។

រកសំឡេងឆ្នោត ។ ប្រធានគណបក្សសមរង្ស៊ី ក៏បានធ្វើដំណើរ ដែលមានលក្ខណៈជាការចុះឃោសនាទៅកាន់ខេត្តក្រុងនានា នៅមុនពេលបន្តិចនៃរយៈពេលឃោសនាជាផ្លូវការនេះផងដែរ ។ នៅតាមមណ្ឌលបោះឆ្នោតនានានៅទូទាំងប្រទេស អ្នកសង្កេតការណ៍របស់ EU EOM បានទទួលរបាយការណ៍អាចជឿទុកចិត្តបាន ជាច្រើនស្តីអំពីការចែកលុយ និងអំណោយដ៏រាលដាល នៅមុនការចាប់ផ្តើមនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោតជាផ្លូវការ ។ សកម្មភាពបែបនេះ ក៏ត្រូវបានកត់សម្គាល់ដោយអ្នកសង្កេតការណ៍ក្នុងស្រុកនៅក្នុងរបាយការណ៍របស់ពួកគេផងដែរ ។

គណបក្សនយោបាយទាំង ១១ បានរៀបចំសកម្មភាពឃោសនារកសំឡេងឆ្នោតទាំងអស់គ្នា ប៉ុន្តែបរិយាកាសនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោតនៅក្នុងក្រុង និងទីរួមខេត្តធំៗត្រូវបានគ្របដណ្តប់ដោយគណបក្សធំៗចំនួន៥ ។ ការប្រកួតប្រជែងមិនមានភាពខ្លាំងក្លាទេនៅតាមតំបន់ជនបទ ដោយមានតែគណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ីប៉ុណ្ណោះ ដែលមានវត្តមានច្រើនជាងគណបក្សដទៃទៀត ។ អ្នកសង្កេតការណ៍ EU បានរាយការណ៍អំពីបរិយាកាសឃោសនារកសំឡេងឆ្នោតដែលមានលក្ខណៈប្រជែងគ្នាខ្លាំងក្លា និងតឹងតែងនៅក្នុងមណ្ឌលបោះឆ្នោតជាទីប្រជុំជនដែលមានអាសនៈច្រើន ។

យុទ្ធនាការឃោសនារកសំឡេងឆ្នោតជាផ្លូវការ ត្រូវបានអ្នកសង្កេតការណ៍ទាំងអស់យល់ឃើញជាទូទៅថា មានសន្តិភាព និងលក្ខណៈបើកចំហជាងនៅក្នុងការបោះឆ្នោតលើកមុនៗ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ចំណាប់អារម្មណ៍ទូទៅរបស់អ្នកសង្កេតការណ៍ EU គឺថា គណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់តំណែងគ្រប់គ្រងអំណាចរបស់ខ្លួនដើម្បីគ្របដណ្តប់ទៅលើយុទ្ធនាការឃោសនារកសំឡេងឆ្នោត ហើយអ្នកសង្កេតការណ៍បានឃើញ និងបានទទួលរបាយការណ៍ជាបន្តបន្ទាប់ ថាសេរីភាពនៃការសម្តែងមតិ សេរីភាពនៃការប្រមូលផ្តុំ និងសេរីភាពនៃការចូលរួមនៅក្នុងព្រឹត្តិការណ៍ជាច្រើន ត្រូវបានរារាំងដោយបុគ្គលនៅថ្នាក់មូលដ្ឋានដែលមានទំនាក់ទំនងជាមួយគណបក្សប្រជាជនកម្ពុជា ។ ឧប្បត្តិហេតុបែបនេះត្រូវបានសង្កេតឃើញដោយផ្ទាល់នៅក្នុងខេត្តកំពង់ចាម នៅថ្ងៃទី១៦ ខែកក្កដា ដែលនៅទីនោះ យុទ្ធនាការឃោសនារបស់គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច បានបង្កជាសំឡេងលាន់ឮលុបទៅលើព្រឹត្តិការណ៍ឃោសនារបស់គណបក្សសមរង្ស៊ី[៥៨] និងនៅថ្ងៃទី២២ ខែកក្កដា នៅក្នុងទីក្រុងភ្នំពេញ ដែលនៅទីនោះឧបករណ៍បំពងសំឡេងរបស់គណបក្សប្រជាជនកម្ពុជា បានលាន់ឮលុបទៅលើយុទ្ធនាការឃោសនារបស់គណបក្សនរោត្តមរណឫទ្ធិ នៅមុខស្ថានីយទូរទស្សន៍**ស៊ីធីអិន** ។ យុទ្ធនាការទាំងពីរនេះត្រូវបានអនុញ្ញាតដោយ **គជ/សប** ដែលក្រោយមក **គជ/សប** បានប្រតិកម្មតបទៅនឹងបណ្តឹងរបស់គណបក្សនរោត្តមរណឫទ្ធិ តាមរយៈការសន្ទនាតាមទូរស័ព្ទ ដោយស្នើអោយគណបក្សនរោត្តមរណឫទ្ធិចាកចេញពីទីកន្លែងនោះដោយសារមូលហេតុថា ស្ថានការណ៍ "អាចនឹងគ្រប់គ្រងលែងបាន" ប៉ុន្តែមិនព្រមស្នើសុំអ្នកគាំទ្ររបស់គណបក្សប្រជាជនកម្ពុជា អោយគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយឡើយ ។ នៅក្នុងខេត្តតាកែវ និងខេត្តកោះកុង សកម្មជនគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី ត្រូវបានមេភូមិ (នៅក្នុងខេត្តកោះកុង មេភូមិត្រូវបានចូលរួមដោយអ្នកគាំទ្ររបស់គណបក្សប្រជាជនកម្ពុជា មន្ត្រីឃុំ និងនគរបាល) ទៅរកដល់ផ្ទះ នៅក្រោយពេលរៀបចំកិច្ចប្រជុំរបស់គណបក្សនៅផ្ទះ/ទីស្នាក់ការគណបក្សរបស់ពួកគេ ។ ខណៈដែល "ការខកចិត្ត" ត្រូវបានសម្តែងឡើងនៅក្នុងករណីនៅខេត្តតាកែវ ឧប្បត្តិហេតុនៅខេត្តកោះកុង កើតមានសកម្មភាពហិង្សា និងវិធានការគំរាមកំហែងដើម្បីរឹបអូសយកម៉ាស៊ីនថតរូបដែលមានផ្ទុកនូវភស្តុតាងសំខាន់ៗអំពីឧប្បត្តិហេតុនោះ

[៥៨] តំណាងក្រុមប្រឹក្សាឃុំរបស់គណបក្សប្រជាជនកម្ពុជា ថែមទាំងបានថ្លែងតាមឧគ្ឃោសនសព្ទថា អ្នកភូមិមិនគួរជឿការឃោសនារបស់គណបក្សសមរង្ស៊ីឡើយ ហើយគួរតែធ្វើជាមិត្ត មិនមែនជាសត្រូវរបស់ថ្នាក់ដឹកនាំបច្ចុប្បន្នទេ ។

ហើយនៅក្នុងករណីទាំងពីរនេះ សកម្មជនបានរាយការណ៍ថា មានការប្រើពាក្យសម្តីអសុរោះ និងថា ពួកគេមានអារម្មណ៍ត្រូវបានគំរាមកំហែង[៥៩] ។

ឧប្បត្តិហេតុនៃការយាយីរំខានស្រដៀងៗគ្នានេះ ត្រូវបានអ្នកសង្កេតការណ៍ EU បានសង្កេតឃើញដោយផ្ទាល់ នៅក្នុងខេត្តបាត់ដំបង និងខេត្តស្ទឹងត្រែង ហើយរបាយការណ៍ដែលគួរអោយជឿជាក់ត្រូវបានទទួលពីអ្នកសង្កេតការណ៍នៅតាមមណ្ឌលបោះឆ្នោតផ្សេងទៀត ។ ករណីបំភិតបំភ័យដែលរាលដាលបំផុតដែលទាក់ទងនឹងការគំរាមកំហែង និងការបញ្ជាទៅលើពលរដ្ឋដែលបានអនុញ្ញាតអោយគណបក្សប្រឆាំងលើកស្លាកគណបក្ស បដា ប័ណ្ណប្រកាស និងសម្ភារៈឃោសនាផ្សេងៗទៀតនៅលើផ្ទះសម្បែងរបស់ពួកគេ។ ឧប្បត្តិហេតុទាំងនេះ និងកង្វះវិធានការបុរេសកម្ម[៦០] ពីសំណាក់អាជ្ញាធររៀបចំការបោះឆ្នោតដើម្បីទប់ស្កាត់ការកើតឡើងដដែលនៃឧប្បត្តិហេតុទាំងនេះ គឺជាការរំលោភបំពានទៅលើបទដ្ឋានអន្តរជាតិ ដែលមានចែងនៅក្នុងមាត្រា ២១ របស់ ICCPR ដែលធានាថា--សិទ្ធិបោះឆ្នោតជាសកល : *គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីអត្ថាធិប្បាយលេខ២៥ កថាខណ្ឌទី ២៥ ថ្លែងថា : "ការប្រើប្រាស់ពេញលេញនូវសិទ្ធិដែលការពារដោយមាត្រា ២៥ នៃ ICCPR ទាមទារនូវសេរីភាពក្នុងការធ្វើកិច្ចពិភាក្សាដេញដោលអំពីកិច្ចការសាធារណៈ ធ្វើបាតុកម្មដោយសន្តិវិធី និងរៀបចំកិច្ចប្រជុំ រិះគន់ និងជំទាស់ បោះពុម្ពផ្សាយឯកសារ ឬសម្ភារៈនយោបាយ ឃោសនានៅក្នុងការបោះឆ្នោត និងផ្សព្វផ្សាយគំនិតនយោបាយ"* ។ លើសពីនេះទៅទៀត *មាត្រា ២៥ របស់ ICCPR ធានានូវការសម្តែងឆន្ទៈដោយសេរី* ។ *គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីអត្ថាធិប្បាយលេខ ២៥ កថាខណ្ឌទី ១៩ និង ២៥ : "បុគ្គលដែលមានសិទ្ធិបោះឆ្នោតត្រូវតែមានសេរីភាពក្នុងការគាំទ្រ ឬប្រឆាំងជំទាស់រដ្ឋាភិបាល ដោយគ្មានការទទួលរងឥទ្ធិពល ឬការបំភិតបំភ័យក្នុងប្រភេទណាមួយ ដែលអាចធ្វើអោយខូច ឬរារាំងដល់ការសម្តែងឆន្ទៈរបស់អ្នកបោះឆ្នោត ។ អ្នកបោះឆ្នោត គួរតែបញ្ចេញមតិដោយឯករាជ្យ ដោយគ្មានអំពើហិង្សា ឬការគំរាមកំហែងប្រើហិង្សា ការបង្ខិតបង្ខំ ការលួងលោមបញ្ចុះបញ្ចូល ឬការជ្រៀតជ្រែកដោយល្បិចកលនៃប្រភេទណាមួយឡើយ"* ។ ដោយពិចារណាទៅលើរបាយការណ៍នៃការយាយីរំខានទៅលើអ្នកគាំទ្ររបស់គណបក្សប្រឆាំង ដែលបានកើតឡើងនៅមុនរយៈពេលនៃការឃោសនាសម្រាប់ការបោះឆ្នោតឆ្នាំ២០០៨ អ្នកសង្កេតការណ៍ EU សោកស្តាយចំពោះការដែល **គ.ជ.ប** ក្នុងនាមជាស្ថាប័នរដ្ឋមួយ មិនបានចាត់វិធានការសកម្មមុនដើម្បីធានានូវការការពារសម្រាប់បរិយាកាសឃោសនារកសំឡេងឆ្នោតដោយសេរី ។

ការចែកលុយកាក់ និងអំណោយត្រូវបានរាយការណ៍ជាទូទៅនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដោយក្រុមអ្នកសង្កេតការណ៍ក្នុងស្រុក ដៃគូសន្ទនាក្នុងស្រុកនៅទូទាំងប្រទេស និងដោយអ្នកសង្កេតការណ៍ EU ។ ខណៈដែលទង្វើបែបនេះត្រូវបានអនុវត្តដោយគណបក្សនយោបាយភាគច្រើនបំផុត មានភស្តុតាងបញ្ជាក់ថា គណបក្សប្រជាជនកម្ពុជា បានអនុវត្តទង្វើបែបនេះក្នុងកម្រិតមួយខ្ពស់ជាងគណបក្សដទៃផ្សេងទៀត ។ អ្នកសង្កេតការណ៍ EU ក៏បានទទួលផងដែរនូវរបាយការណ៍ដែលថា

---

[៥៩] នៅក្នុងករណីខេត្តកោះកុង **គឃ/សប** បានព្យាយាមយ៉ាងសកម្មដើម្បីរារាំងការដាក់ពាក្យបណ្តឹងផ្លូវការ ប៉ុន្តែមិនបានជោគជ័យ ហើយនៅក្រោយការច្រានចោលនូវពាក្យបណ្តឹងនោះនៅថ្នាក់គណៈកម្មការក្រុងរៀបចំការបោះឆ្នោត (ដោយសារកង្វះភស្តុតាង) ពាក្យបណ្តឹងនោះត្រូវបានប្តឹងបន្តទៅ **គ.ជ.ប** ។ ការសង្កេតការណ៍របស់ EU បញ្ជាក់ថា ការព្យាយាមរារាំងបែបនេះកើតមានរាលដាល និងជាបន្តបន្ទាប់នៅក្នុងរយៈពេលឃោសនាទាំងមូល ។

[៦០] ការនេះគួរតែបានធ្វើឡើងតាមរយៈការចេញសេចក្តីថ្លែងការណ៍ព័ត៌មាន ឬសារដែលផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ។

អ្នកបោះឆ្នោតត្រូវបានព្រមានអំពីផលវិបាកអវិជ្ជមាន ប្រសិនបើពួកគេមិនបោះឆ្នោតអោយគណបក្សកាន់អំណាច[៦១] ។ ជាមួយគ្នានេះ ក៏មានការបង្ហាញអោយឃើញផងដែរអំពីការប៉ុនប៉ងព្យាយាមរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីលើកទឹកចិត្តអោយអ្នកបោះឆ្នោតដែលមានទំនោរប្រឆាំងកុំទៅបោះឆ្នោត និងការប៉ុនប៉ងព្យាយាមដើម្បីទិញទឹកចិត្តភ្នាក់ងារគណបក្សនយោបាយតាមរយៈការផ្តល់ប្រាក់រង្វាន់អោយច្រើនជាង ។ នៅមុនថ្ងៃបោះឆ្នោត ពាក្យចចាមអារ៉ាមអំពី "រាត្រីឆ្កែព្រុស"[៦២] ត្រូវបានផ្សព្វផ្សាយ ។ អ្នកសង្កេតការណ៍ EU បានទទួលរបាយការណ៍អំពីការទិញសន្លឹកឆ្នោតចំនួន ៣០ ករណីពីមណ្ឌលបោះឆ្នោតចំនួន ១០ ។ ទោះបីជារបាយការណ៍អំពីការទិញសន្លឹកឆ្នោតជាច្រើនពិបាកនឹងធ្វើការបញ្ជាក់ថាពិតឬមិនពិតនោះក៏ដោយ របាយការណ៍ជាបន្តបន្ទាប់អំពីសកម្មភាពបែបនេះ ធ្វើអោយមានការព្រួយបារម្ភកាន់តែច្រើនឡើងអំពីការគោរពសេរីភាពជាមូលដ្ឋាននៃសិទ្ធិក្នុងការចូលរួម នៅក្នុងប្រទេសកម្ពុជា ។ ការទិញសន្លឹកឆ្នោតត្រូវបានហាមឃាត់ដោយ **ច.ប.ត.រ** ហើយក៏ត្រូវបានបញ្ជាក់ជាថ្មីទៀតនៅក្នុងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយ ក្នុងអំឡុងពេលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ប្រធានបទសំខាន់ៗនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោត គឺទាក់ទងនឹងការបន្តស្ថិរភាព ការរីកចម្រើនលូតលាស់ផ្នែកសេដ្ឋកិច្ច អតិផរណា និងការលើកកម្ពស់ជីវភាពរស់នៅនៅជនបទ ព្រមទាំងបញ្ហារសើបមួយចំនួន ដូចជា ការចាប់យកដីធ្លី បញ្ហាព្រំដែន អំពើពុករលួយ និងអន្តោប្រវេសន៍ខុសច្បាប់ ជាដើម ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ចាប់ពីថ្ងៃទី១៥ ខែកក្កដាមក ពលរដ្ឋខ្មែរ ជាច្រើនបានបង្វែរការយកចិត្តទុកដាក់ចេញពីការបោះឆ្នោតទៅផ្តោតលើជម្លោះរវាងប្រទេសកម្ពុជា និងប្រទេសថៃ ជុំវិញតំបន់ប្រាសាទព្រះវិហារវិញ ។

អ្នកសង្កេតការណ៍ EU បានវាយតម្លៃទៅលើការប្រើពាក្យសម្តីនៅក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោតថា ជាទូទៅមានលក្ខណៈវិជ្ជមាន ប៉ុន្តែទោះជាយ៉ាងនេះក្តី ការប្រើប្រាស់ពាក្យសម្តីប្រឆាំងនឹងជនជាតិវៀតណាមដោយគណបក្សប្រឆាំងខ្លះត្រូវបានកត់សម្គាល់ នៅពេលនិយាយអំពីបញ្ហាអន្តោប្រវេសន៍ខុសច្បាប់ ជម្លោះព្រំដែន និងការចាប់យកដីធ្លី ។ លើសពីនេះទៅទៀត អ្នកសង្កេតការណ៍ EU បានរាយការណ៍ជាបន្តបន្ទាប់ថា គណបក្សប្រជាជនកម្ពុជា បានលើកឡើងដោយផ្ទាល់អំពីទំនាក់ទំនងរវាងកម្លាំងប្រឆាំងឡើងកាន់អំណាច និងប្រទេសវិលទៅរកជម្លោះ ដែលនៅក្នុងបរិយាកាសនៅក្រោយជម្លោះ ការលើកឡើងបែបនេះត្រូវបានគេគិតថា ជាការចោទប្រកាន់ធ្ងន់ធ្ងរ និងអាចត្រូវបានចាត់ទុកថាជាយុទ្ធសាស្ត្រឃោសនាបែបបំភិតបំភ័យផង និងបង្ខិតបង្ខំផង ដែលរំលោភទៅលើក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ។

## គ. ការប្រើប្រាស់ធនធានរបស់រដ្ឋ

[៦១] ការគំរាមកំហែងបែបនេះត្រូវបានបញ្ជាក់ថាពិតជាកើតមានមែននៅក្នុងខេត្តកណ្តាល ដែលនៅទីនោះអ្នកភូមិម្នាក់ត្រូវបានគេដកហូតម៉ាស៊ីនបូមទឹកភ្លាមៗនៅក្រោយថ្ងៃបោះឆ្នោត នៅពេលដែលការរាប់សន្លឹកឆ្នោតចេញពីទីតាំងនោះត្រូវបានដឹង ។

[៦២] យោងតាមប្រភពក្នុងស្រុក "រាត្រីឆ្កែព្រុស" ជាទង្វើដែលមាននៅក្នុងការបោះឆ្នោតមុនៗ ដែលក្នុងនោះគណបក្សនយោបាយមួយចំនួនបានដើរតាមផ្ទះប្រជាជននៅពាក់កណ្តាលអធ្រាត្រ ឬនៅប៉ុន្មានយប់នៅមុនថ្ងៃបោះឆ្នោត (នៅក្រៅម៉ោងឃោសនាស្របច្បាប់) ដើម្បីបញ្ចុះបញ្ចូល/ទិញទឹកចិត្តប្រជាជនអោយបោះឆ្នោតអោយគណបក្សរបស់ពួកគេ ធ្វើអោយឆ្កែក្នុងភូមិ/តាមផ្ទះព្រុស ។

នៅក្នុងអំឡុងរយៈពេលនៃយុទ្ធនាការឃោសនាជាផ្លូវការ គណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់ធនធានរដ្ឋជាច្រើនប្រភេទ ក្នុងនោះរាប់បញ្ចូលទាំងទ្រព្យសម្បត្តិ និងយានជំនិះរបស់រដ្ឋ ព្រមទាំងបុគ្គលិករដ្ឋ ។ អ្នកសង្កេតការណ៍ EU ក៏បានសង្កេតឃើញផងដែរថា ទីស្នាក់ការរបស់អាជ្ញាធរមូលដ្ឋាន និងទីស្នាក់ការរបស់គណបក្សប្រជាជនកម្ពុជា ជារឿយៗត្រូវបានដាក់នៅជិតគ្នា ហើយក្នុងករណីមួយចំនួនតូច ថែមទាំងស្ថិតនៅក្នុងបរិវេណជាមួយគ្នាទៀតផង ដែលធ្វើអោយគេពិបាកនឹងញែកគណបក្សនយោបាយអោយដាច់ចេញពីស្ថាប័នរដ្ឋ ។ ក្នុងអំឡុងរយៈពេលនៃយុទ្ធនាការឃោសនាជាផ្លូវការ បុគ្គលិកនៃទីស្នាក់ការទាំងពីរនេះ ត្រូវបានសង្កេតឃើញជាច្រើនលើកច្រើនសាចេញចូលទៅមកជាប់ជាប្រចាំនៅក្នុងទីស្នាក់ការទាំងពីរនេះនៅក្នុងអំឡុងម៉ោងធ្វើការ ។

ជាមួយគ្នានេះ ក៏មានការបង្ហាញអោយឃើញផងដែរថា **គឃ/សប** និង **គខ/កប** នៅទូទាំងប្រទេសបានរំលោភបំពានបញ្ញត្តិស្តីពីសន្តិសុខ និងរដ្ឋបាល ឧទាហរណ៍ដោយទាមទារការជូនដំណឹងជាមុន ឬសិទ្ធិនៅក្នុងការផ្តល់ការអនុញ្ញាតដល់សកម្មភាពឃោសនាដើម្បីបន្ទច់បង្អាក់គណបក្សប្រឆាំងមិនអោយរៀបចំព្រឹត្តិការណ៍ដែលពួកគេបានគ្រោងទុករួចរាល់ ។ ការរឹតត្បិតបែបដូច្នេះមិនត្រូវបានអនុវត្តចំពោះគណបក្សប្រជាជនកម្ពុជាឡើយ ។ ជាក់ស្តែង ដូចជានៅក្នុងខេត្តរតនគិរី **គខ/កប** ថែមទាំងបានប្រគល់ភារកិច្ចនេះទៅអោយនគរបាល និងយោធា នៅពេលដែលគណបក្សប្រឆាំងតវ៉ាជំទាស់នឹងទង្វើដូច្នេះ ។ នគរបាលមិនបានចាត់វិធានការប្រឆាំងនឹងរថយន្តគ្មានស្លាកលេខមួយចំនួនធំដែលប្រើប្រាស់នៅក្នុងសកម្មភាពឃោសនារបស់គណបក្សប្រជាជនកម្ពុជា និងមួយចំនួនតិចជាងនេះរបស់គណបក្សហ៊្វុនស៊ិនប៉ិចឡើយ ។ របាយការណ៍ជាច្រើនបានគូសបញ្ជាក់ថា រថយន្តដែលគ្មានស្លាកលេខទាំងនេះគឺជារថយន្តរដ្ឋ ហើយអ្នកសង្កេតការណ៍ EU ប្រចាំនៅខេត្តកំពង់ចាមត្រូវបានបេក្ខជនគណបក្សប្រជាជនកម្ពុជាមួយរូបប្រាប់ថា "មន្ត្រីរាជការដែលជាសមាជិកគណបក្សប្រជាជនកម្ពុជាមិនត្រូវបានហាមឃាត់ក្នុងការប្រើប្រាស់រថយន្តរដ្ឋសម្រាប់សកម្មភាពឃោសនារកសំឡេងឆ្នោតឡើយ" ។ បេក្ខជនដដែលនោះក៏បានប្រាប់អោយដឹងបន្ថែមទៀតអំពីការដកស្លាកលេខរថយន្តរដ្ឋចេញ នៅពេលដែលរថយន្តទាំងនេះត្រូវបានយកទៅប្រើប្រាស់សម្រាប់គោលបំណងឯកជន ។ ទោះបីកម្មសិទ្ធិករជានរណាក៏ដោយ ទង្វើបែបនេះគឺជាការផ្ទុយនឹងច្បាប់របស់កម្ពុជា ហើយមិនគួរត្រូវបានធ្វើមិនដឹងមិនឮនោះឡើយ ។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងកិច្ចសន្ទនាជាមួយប្រធានអ្នកសង្កេតការណ៍ EU មន្ត្រីតំណាងគណបក្សប្រជាជនកម្ពុជា បានប្រាប់ថា ពួកគេមិនបានយល់ថាជាបញ្ហាអ្វីឡើយ ដែលបុគ្គលិកយោធាជាន់ខ្ពស់ធ្វើជាអ្នកដឹកនាំព្រឹត្តិការណ៍ឃោសនារកសំឡេងឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា នៅក្នុងម៉ោងធ្វើការនោះ ។

ទង្វើអស់ទាំងនេះ គឺជាការរំលោភបំពានលើក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រងការបោះឆ្នោត ក្នុងនោះរាប់បញ្ចូលទាំងក្រមសីលធម៌សម្រាប់សមាជិកកងកម្លាំងប្រដាប់អាវុធ និងនគរបាល និងសម្រាប់គណបក្សនយោបាយ ព្រមទាំងច្បាប់ និងបទបញ្ជាផ្សេងៗដែលទាក់ទងនឹងតួនាទីរបស់មេភូមិ ។ ការអនុវត្តដោយមិនស្មើភាពគ្នានូវវិធាន និងច្បាប់ដែលគ្រប់គ្រងការបោះ-ឆ្នោត បានបង្ហាញអោយឃើញអំពីទំហំនៃបញ្ហាដែលទាក់ទងនឹងប្រព័ន្ធច្បាប់ដែលមានភាពលម្អៀងរបស់ប្រទេសកម្ពុជា ។ ពុំមានបទដ្ឋានអន្តរជាតិណាមួយដែលចែងអំពីការប្រើប្រាស់ធនធានរដ្ឋឡើយ ប៉ុន្តែ គណៈកម្មការក្រុង Venice[៦៣] ចែងជាគំរូ

[៦៣] គណៈកម្មការក្រុង Venice រួមមានសមាជិកជាអ្នកជំនាញការឯករាជ្យដែលមានបទពិសោធន៍ជ្រាលជ្រៅនៅក្នុងការកសាងស្ថាប័នប្រជាធិបតេយ្យ ឬតាមរយៈការចូលរួមចំណែករបស់ពួកគេដល់ការកែលម្អវិទ្យាសាស្ត្រច្បាប់ និងនយោបាយ ។ http://www.venice.coe.int/site/main/Elections_Referendums_E.asp ។

អនុវត្តន៍ប្រសើរបំផុតថា ប្រសិនបើ *"ការប្រើប្រាស់ធនធានរដ្ឋត្រូវបានអនុញ្ញាតនោះ លទ្ធភាពនៃការប្រើប្រាស់ត្រូវតែផ្តល់ដល់អ្នកប្រកួតប្រជែងដោយឈរលើមូលដ្ឋានសមធម៌"* ។

ជាងនេះទៅទៀត លំនាំ និងភាពញឹកញាប់នៃការចុះចូលរបស់មន្ត្រី ឬសមាជិកគណបក្សប្រឆាំងជាមួយគណបក្សប្រជាជនកម្ពុជា គាំទ្រការអះអាងដែលថា គណបក្សប្រជាជនកម្ពុជា បានផ្តល់លុយកាក់ជាច្រើន របស់មានតម្លៃ ដូចជាម៉ូតូ និងតំណែងក្នុងជួររដ្ឋាភិបាល ដើម្បីទាក់ទាញមេដឹកនាំ និងសកម្មជនសំខាន់ៗរបស់គណបក្សប្រឆាំង ។ ភាគច្រើនបំផុតនៃករណីចុះចូលទាំងនេះបានកើតឡើងនៅក្នុងខែកុម្ភៈ ឧសភា និងមិថុនា ប៉ុន្តែ អ្នកសង្កេតការណ៍ EU មានលទ្ធភាពអាចតាមដានករណីខ្លះៗដែលកើតឡើងក្នុងអំឡុងពេលនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោត ដែលទំនងជាបង្ហាញអំពីកម្រិតនៃប្រាក់រង្វាន់ អំណោយ ការបំភិតបំភ័យ និងការគំរាមកំហែងដែលពិបាកនឹងប្រឆាំង ។ ជាងនេះទៅទៀត នៅចំពេលដែលមានរបាយការណ៍ស្តីពីចំនួនកើនឡើងនូវការតែងតាំងទីប្រឹក្សាជាន់ខ្ពស់ទៅជាតំណែងប្រតិបត្តិថ្នាក់ខ្ពស់ អ្នកសង្កេតការណ៍ EU បានធ្វើការវិភាគទៅលើការតែងតាំងបែបនេះពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៨ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨[៦៤] ។ ក្នុងចំណោមការតែងតាំងសរុបចំនួន ៥៣៨[៦៥] អ្នកសង្កេតការណ៍ EU អាចកំណត់នូវឈ្មោះយ៉ាងតិចបំផុតចំនួន ២៨នៃអ្នកចុះចូលដែលបានទទួលតំណែងខ្ពស់បែបនេះ ។ អ្នកសង្កេតការណ៍ EU ក៏បានទទួលផងដែរនូវរបាយការណ៍ដែលថា នៅក្នុងខេត្តមួយចំនួន រដ្ឋមន្ត្រីដែលកំពុងកាន់តំណែងនៅក្នុងរដ្ឋសភានីតិកាលទី៣ មានទីប្រឹក្សាជាច្រើនរូបដែលធ្វើការអោយពួកគេ ។ ដោយសារតែចំនួនសរុបនៃទីប្រឹក្សាទាំងនេះ កិច្ចការ និងកម្រិតបៀវត្សរ៍ ជាក់លាក់សម្រាប់មុខតំណែងទាំងនេះមិនត្រូវបានប្រកាសអោយដឹងជាសាធារណៈនោះ គេមិនអាចធ្វើការកំណត់ទៅតម្លៃនៃការប្រើប្រាស់ដោយបំពានទៅលើធនធានរបស់រដ្ឋបានឡើយ ។

អ្នកសង្កេតការណ៍ EU ក៏បានកត់សម្គាល់ផងដែរនូវអនុក្រឹត្យ[៦៦] លេខ៩៤ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨ ដែលផ្តល់ដល់មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងមន្ត្រីចូលនិវត្តន៍ មន្ត្រីរាជការពិការ និងទាហានពិការដែលជាមន្ត្រីរាជការ និងអតីតយុទ្ធជនទាំងអស់ នូវការដំឡើងប្រាក់បៀវត្សរ៍ប្រចាំខែ ២០.០០០រៀល ដែលត្រូវអនុវត្តចាប់ពីពាក់កណ្តាលឆ្នាំ២០០៨ តទៅ ។ ខណៈដែលទង្វើនេះមិនអាចចាត់ទុកដោយផ្ទាល់ថាជាការប្រើប្រាស់បំពាននូវធនធានរដ្ឋ វាគឺជាគំនិតផ្តួចផ្តើមដ៏ពិសេសដើម្បីធ្វើយុទ្ធនាការឃោសនារកសំឡេងឆ្នោតនៅក្នុងពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ នៅមុនការបោះឆ្នោតជាតិ ។

## ឃ. ការផ្តល់ឱកាសសម្រាប់យុទ្ធនាការឃោសនារកសំឡេងឆ្នោត

[៦៤] ជាការប្រៀបធៀប ទីប្រឹក្សា ១៧៨នាក់ត្រូវបានតែងតាំងក្នុងអំឡុងរយៈពេលដូចគ្នានេះនៅក្នុងឆ្នាំ២០០៧ ។ ព័ត៌មានទាំងអស់ គឺផ្អែកទៅលើព្រះរាជក្រឹត្យដែលចេញផ្សាយនៅក្នុងសៀវភៅរាជកិច្ច ខ្ទបទី៨ លេខពី ១-៥០ ឆ្នាំ២០០៨ (ថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី០២ ខែកក្កដា ២០០៨) និងខ្ទបទី៧ ពីលេខ ១-៤៦ (ថ្ងៃទី០១ ខែមករា-ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧) ។

[៦៥] ដោយចែកត្រួសៗ ការតែងតាំងរួមមាន ទីប្រឹក្សាផ្ទាល់ថ្មីរបស់នាយករដ្ឋមន្ត្រី ១១៦រូប ដែលមួយភាគធំមានឋានៈស្មើរដ្ឋលេខាធិការ រដ្ឋមន្ត្រី ឬទេសរដ្ឋមន្ត្រី និងទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីចំនួន ៣៦រូប ។

[៦៦] អនុក្រឹត្យស្តីពីការផ្តល់ប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងមន្ត្រីចូលនិវត្តន៍ មន្ត្រីរាជការពិការ និងទាហានពិការដែលជាមន្ត្រីរាជការ និងអតីតយុទ្ធជន ។

ទោះបីជាច្បាប់ស្តីពីគណបក្សនយោបាយ មានចែងថា រដ្ឋអាចនឹងបែងចែកថវិកាពីថវិកាជាតិ ជាប្រាក់ឧបត្ថម្ភក្នុងចំនួនស្មើគ្នា សម្រាប់គណបក្សនយោបាយទាំងអស់ ដើម្បីធ្វើសកម្មភាពឃោសនាក៏ដោយ ក៏ការអនុវត្តរបៀបនេះមិនដែលកើតមានឡើងឡើយ ។ អ្នកសង្កេតការណ៍ EU ធ្វើការវាយតម្លៃអំពីលក្ខខណ្ឌដែលតម្រូវអោយគណបក្សនយោបាយតម្កល់ទឹកប្រាក់ចំនួន១៥លានរៀល (US$3,750) នៅរតនាគារជាតិ ដើម្បីឈរឈ្មោះបោះឆ្នោត ថាជាការរារាំងកុំអោយមានការចូលរួមច្រើនដោយគ្មានហេតុផលសម្រាប់គណបក្សតូចៗថ្មី ។ ការតម្កល់ប្រាក់នេះអាចបង្វិលមកវិញ តែក្នុងករណីគណបក្សបានទទួលសំឡេងយ៉ាងហោច ៣ភាគរយនៃសំឡេងឆ្នោតបានការ ឬយ៉ាងហោចបានទទួលអាសនៈមួយនៅរដ្ឋសភាប៉ុណ្ណោះ ។

**ច.ប.ត.រ** តម្រូវអោយគណបក្សនយោបាយនានា និងបេក្ខជនរបស់ខ្លួនមានគណនីធនាគារមួយ ដែលគេអាចត្រួតពិនិត្យប្រភពចំណូល និងចំណាយសម្រាប់យុទ្ធនាការឃោសនារកសំឡេងឆ្នោត ។ អ្នកសង្កេតការណ៍ EU បានទទួលព័ត៌មានថា **គ.ជ.ប** មិនបានប្រើប្រាស់អោយបានច្បាស់លាស់នូវអំណាចដែលបានផ្តល់ជូននៅក្នុង **ច.ប.ត.រ** មាត្រា ៨២ ដើម្បីត្រួតពិនិត្យគណនីទេ ។ ច្បាប់ស្តីពីគណបក្សនយោបាយ តម្រូវអោយគណបក្សនយោបាយនានា ធ្វើបាយការណ៍ប្រចាំឆ្នាំទៅអោយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានភ្ជាប់របាយការណ៍ធនាគារ ព្រមទាំងរបាយការណ៍ទ្រព្យសកម្ម និងបំណុលផងដែរ ។ ការខកខានមិនបានរៀបចំរបាយការណ៍ប្រចាំឆ្នាំ អាចត្រូវពិន័យ ឬបញ្ជាអោយបញ្ឈប់សកម្មភាព ។ អ្វីដែលគួរអោយព្រួយបារម្ភថែមទៀតនោះគឺ គ្មានការកំណត់អំពីកម្រិតនៃការចំណាយលើយុទ្ធនាការបោះឆ្នោត (ក្នុងបេក្ខជនម្នាក់ៗ សម្រាប់មណ្ឌលនីមួយៗ ឬសម្រាប់ចំណាយជារួម) ឬ អំពីកម្រិតវិភាគទានជាប្រាក់ ឬ ជាវត្ថុ ពីសំណាក់បុគ្គលម្នាក់ៗឡើយ ។ ការនេះនាំអោយមានកង្វះខាតក្នុងការផ្តន្ទាទោសចំពោះគណនេយ្យមិនត្រឹមត្រូវ ។ កង្វះខាតគោលការណ៍ច្បាប់ប្រកបដោយប្រសិទ្ធភាព និងលម្អិត ដើម្បីគ្រប់គ្រងលើការផ្គត់ផ្គង់ថវិការបស់គណបក្សនយោបាយ នាំអោយខ្វះតម្លាភាព និងជម្រុញអោយមានការសង្ស័យ ។

មានគណបក្សនយោបាយមួយចំនួនបានអោយអ្នកសង្កេតការណ៍ EU ដឹងថា ពួកគេពឹងផ្អែកលើអំណោយឯកជនច្រើនជាងវិភាគទានសមាជិកភាពផ្ទៃក្នុង ។ ទោះបីជាធ្វើដូច្នេះអាចជាមធ្យោបាយផ្គត់ផ្គង់ហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពក៏ដោយ ក៏ការផ្គត់ផ្គង់ហិរញ្ញវត្ថុគណបក្សតាមសមាជិកភាព មានគុណសម្បត្តិក្នុងការត្រួតពិនិត្យមើល និងថ្លឹងអំណាច ដែលចាំបាច់ ព្រមទាំងពង្រឹងរចនាសម្ព័ន្ធផ្ទៃក្នុងគណបក្សទៀតផង ។ នៅតាមគណបក្សដែលមានវិភាគទានផ្ទៃក្នុងសម្រាប់ធ្វើយុទ្ធនាការឃោសនារកសំឡេងឆ្នោត ក្នុងចំណោមបេក្ខជននានា ការបែងចែកថវិកានេះហាក់ដូចជាធ្វើតាមបណ្តាញគាំទ្រជាជាងតាមអាទិភាពទាំងមូលក្នុងបក្ស ។ បេក្ខជនមួយចំនួនបានអោយអ្នកសង្កេតការណ៍ EU ដឹងថា បេក្ខជនត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះការផ្គត់ផ្គង់ថវិកាសម្រាប់យុទ្ធនាការឃោសនារបស់ខ្លួន ។ ដូចជានៅក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោតកន្លងមក មានពាក្យចចាមអារាម និងការអះអាងថា មានគណបក្សមួយចំនួនយកថវិការដ្ឋាភិបាល និងដកបៀវត្សរ៍មន្ត្រីរាជការស៊ីវិល មុនពេល និងនៅអំឡុងពេលយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។ ទោះជាយ៉ាងណាក៏ដោយ ទាំងរដ្ឋាភិបាល ទាំង **គ.ជ.ប** ពុំបានព្យាយាមកំណត់ថា ពាក្យចរាមអារាមនោះពិតជាត្រឹមត្រូវ ឬក៏បដិសេធចោលឡើយ ។

គណបក្សនយោបាយតូចៗ និងថ្មី មួយចំនួនបានថ្លែងថា អតិផរណា និងជាពិសេសប្រេងសាំងឡើងថ្លៃ ប៉ះពាល់យ៉ាងខ្លាំងដល់ថវិកាយុទ្ធនាការឃោសនារបស់ខ្លួន និងព្រមទាំងរារាំងពួកគេមិនអោយអនុវត្តសកម្មភាពដែលបានគ្រោងទុកមួយចំនួនទៀតផង ។

## ង. ការអប់រំអ្នកបោះឆ្នោត

ទោះបីជាអ្នកសង្កេតការណ៍ EU បានវាយតម្លៃជាវិជ្ជមានចំពោះការយល់ដឹងរបស់អ្នកបោះឆ្នោត[៦៧] អំពីនីតិវិធីនៅថ្ងៃបោះឆ្នោតក៏ដោយ ក៏សកម្មភាពអប់រំអ្នកបោះឆ្នោត ដែលរៀបចំឡើងដោយអាជ្ញាធររៀបចំបោះឆ្នោត ត្រូវបានវាយតម្លៃថាមិនគ្រប់គ្រាន់ទេ ពីព្រោះតាមរយៈការសន្ទនារបស់អ្នកសង្កេតការណ៍ជាមួយបុគ្គលនានា នៅតាមកម្រិតផ្សេងៗ បានរកឃើញថា អ្នកបោះឆ្នោតបានទទួលព័ត៌មានមានកម្រិតអំពីដំណើរការចុះឈ្មោះបោះឆ្នោត នីតិវិធីរៀបចំបណ្តឹង និងគុណតម្លៃលទ្ធិប្រជាធិបតេយ្យ ជារួម ។

សកម្មភាពអប់រំអ្នកបោះឆ្នោតរបស់រដ្ឋបាលរៀបចំបោះឆ្នោត ត្រូវបានវាយតម្លៃដោយអ្នកសង្កេតការណ៍ EU ថាមិនគ្រប់គ្រាន់ ។ ទោះបីមានអង្គការមិនមែនរដ្ឋាភិបាលនៅតាមមូលដ្ឋានមួយចំនួនបានធ្វើសកម្មភាពអប់រំអ្នកបោះឆ្នោតខ្លះៗក៏ដោយ ក៏គណបក្សនយោបាយ ជាអ្នកសកម្មបំផុតក្នុងការងារនេះ ដោយបានផ្តល់ព័ត៌មានអំពីរបៀបគូសសន្លឹកឆ្នោត "អោយបានត្រឹមត្រូវ" ។ ក្នុងករណីជាច្រើន មេភូមិដែលពាក់ព័ន្ធនឹងគណបក្សប្រជាជនកម្ពុជា ជាអ្នកផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតដោយលម្អៀង នៅអំឡុងពេលចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។

ក្នុងប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យក្មេងខ្ចី ដូចយ៉ាងកម្ពុជា មិនទាន់ដល់ពេលដែលត្រូវកាត់បន្ថយគំនិតផ្តួចផ្តើមអប់រំប្រជាពលរដ្ឋឡើយ រួមទាំងការអប់រំអ្នកបោះឆ្នោតផងដែរ ។ ហេតុដូច្នេះហើយ អ្នកសង្កេតការណ៍ EU មានជំនឿថា តួអង្គមួយចំនួន ដូចជា **គ.ជ.ប** ផ្នែកអប់រំ និងអង្គការសង្គមស៊ីវិលជាដើម គួរពិចារណាឡើងវិញអំពីតួនាទីរបស់ខ្លួន ។ ការងារដ៏សំខាន់ជាពិសេសមួយនោះ គឺ ការពិនិត្យឡើងវិញនូវមធ្យោបាយដែលបានប្រើដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីស្ថានីយបោះឆ្នោត ដែលពួកគេត្រូវទៅបោះឆ្នោត ពីព្រោះការចែកប័ណ្ណព័ត៌មានបោះឆ្នោតមិនមែនជាមធ្យោបាយគ្រប់គ្រាន់ទេ ។

## ច. បណ្តឹង និងបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងការបោះឆ្នោត

យោងតាម **គ.ជ.ប, គឃ/សប** បានទទួលបណ្តឹងសរុបចំនួន ២៤៤ បណ្តឹង ទាក់ទងនឹងការចោទប្រកាន់ពីការរំលោភច្បាប់បោះឆ្នោត ព្រមទាំងបទប្បញ្ញត្តិ និងនីតិវិធីរបស់ **គ.ជ.ប** នៅអំឡុងពេលយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។ ក្នុងចំណោមបណ្តឹងទាំងនេះ មានបណ្តឹងចំនួន ១៤៥ ធ្វើឡើងដោយគណបក្សសមរង្ស៊ី, ៥៣ ដោយគណបក្សប្រជាជនកម្ពុជា, ១៦ ដោយគណបក្សនរោត្តមរណឫទ្ធិ, ១៣ ដោយគណបក្សហ្វ៊ុនស៊ិនប៉ិច, និងបណ្តឹងផ្សេងទៀតធ្វើឡើងដោយគណបក្សតូចៗ

[៦៧] ការវាយតម្លៃជារួមរបស់ EU EOM អំពីការយល់ដឹងរបស់អ្នកបោះឆ្នោតអំពីនីតិវិធីបោះឆ្នោត គឺ : ល្អណាស់ : ៤៥.៧ ភាគរយ ល្អ : ៤៤.២ ភាគរយ មធ្យម : ៨.៧ ភាគរយ អន់ : ១.២ ភាគរយ និង អន់ណាស់ : ០.២ភាគរយ ។

ឬប្រជាពលរដ្ឋធម្មតា ។ ក្នុងចំណោមបណ្តឹងទាំងនេះ មានបណ្តឹងចំនួន ៤០ ត្រូវបានច្រានចោលដោយសម្អាងលើគតិច្បាប់ ៧២ករណី ត្រូវដោះស្រាយដោយការសម្រុះសម្រួល, ក្នុងការសម្រុះសម្រួល ១២៨ករណីមិនអាចសម្រេចបាននៅថ្នាក់ **គឃ/សប** ទេ ហើយ ៤ករណីទៀត ត្រូវដកទៅវិញ ។ បើគិតតាមរបាយការណ៍តំបន់ បណ្តឹងភាគច្រើនធ្វើឡើងនៅខេត្តបាត់ដំបង (៤៣) បន្ទាប់មកស្វាយរៀង (២៨) កំពង់ចាម (២៧) ភ្នំពេញ (១៧) ពោធិ៍សាត់ (១៧) ព្រៃវែង (១៦) កំពត (១៣) និង តាកែវ (១៣) ។

បណ្តឹងភាគច្រើនបំផុតរបស់គណបក្សប្រឆាំង គឺទាក់ទងនឹងការបំផ្លាញសម្ភារៈឯកសារឃោសនា ការរំខានដល់ការឃោសនាដោយគណបក្សដទៃ ការគំរាមកំហែង និងការបំភិតបំភ័យ ការទិញសន្លឹកឆ្នោត និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងមន្ត្រីរាជការស៊ីវិលក្នុងយុទ្ធនាការឃោសនារកសំឡេងឆ្នោត ។ បណ្តឹងញឹកញាប់ភាគច្រើនបំផុតរបស់គណបក្សប្រជាជនកម្ពុជា ទាក់ទងនឹងបទបរិហាកេរ្តិ៍ ។ ជាមួយគ្នានេះ មានបណ្តឹងចំនួន១០ ទាក់ទងនឹងការចោទប្រកាន់ពីការរំលោភបទប្បញ្ញត្តិ និងនីតិវិធីដោយពីសំណាក់មន្ត្រី **គឃ/សប** ដែលធ្វើឡើងដោយផ្ទាល់ដាក់ជូនទៅ **គខ/កប** ដែលពាក់ព័ន្ធ ។

បណ្តឹងចំនួន១៣៣ បានទៅដល់គណៈកម្មការខេត្ត/ក្រុងរៀបចំការបោះឆ្នោត (**គខ/កប**) ។ ក្នុងចំណោមនេះ មានបណ្តឹងចំនួន២២ ត្រូវបានច្រានចោលដោយសម្អាងលើគតិច្បាប់ និង៣៣ករណីទៀតបានសម្រេចកិច្ចព្រមព្រៀងសម្រុះសម្រួល ។ មានបណ្តឹងចំនួន ៧១ករណី ដែលមានការបើកសវនាការផ្លូវការមួយ ដែលជាលទ្ធផល មានបណ្តឹងចំនួន៣២ករណី ត្រូវបានទទួលយក និង ៣៩ករណី ត្រូវបានច្រានចោល ។ គិតទូទាំងប្រទេស **គខ/កប** បានប្រកាសការផ្តន្ទាទោសចំនួន២៥ករណី ដែលនៅក្នុងនោះ៤ករណី បានទទួលលិខិតព្រមាន ក្នុង១២ករណី ជនល្មើសត្រូវព្យួរសិទ្ធិបោះឆ្នោត និង៩ករណី ត្រូវផាកពិន័យ មានចំនួនទឹកប្រាក់ពី ៥លាន ទៅ១០លានរៀល ( (US$1,250 ទៅ US$2,500) ។

មានបណ្តឹងឧទ្ធរណ៍ចំនួន ៤៩ករណី បានទៅដល់ **គ.ជ.ប** ហើយ **គ.ជ.ប** បានកាត់សេចក្តីក្នុងចំនួន១៤ករណី ។ ករណីដែលមានលក្ខណៈរសើបផ្នែកនយោបាយ និងមានទំនាស់ផ្លូវច្បាប់នោះ គឺករណីដែលលោក **សម រង្ស៊ី** ហៅមេដឹកនាំកំពូលទាំងបីរបស់គណបក្សប្រជាជនកម្ពុជាថាជា "ចោរ" ។ លោក **សម រង្ស៊ី** បាននិយាយពាក្យចោទប្រកាន់នេះម្តងហើយម្តងទៀត នៅក្នុងសុន្ទរកថារបស់លោកនៅតាមតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ហើយសុន្ទរកថារបស់លោក ក៏ត្រូវបានអាត់ក្នុងកាសែតវីដេអូ និងចាក់ផ្សាយជាច្រើនលើកនៅអំឡុងពេលឃោសនារកសំឡេងឆ្នោត ។ លោក **សម រង្ស៊ី** ត្រូវពិន័យជាទឹកប្រាក់សរុបចំនួន២៥លានរៀល (US$6,250) ដោយ **គខ/កប** នៅតាមខេត្តផ្សេងៗ ។ ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាអន្តរជាតិរបស់ខ្លួន **គ.ជ.ប** បានសម្រេចបញ្ចូលបណ្តឹងឧទ្ធរណ៍ទាំង១១ ទាក់ទងនឹងករណីនេះ រួចហើយចេញសេចក្តីសម្រេចតែមួយ ដែលនាំអោយមានការពិន័យជាទឹកប្រាក់ចំនួន ១០លានរៀល (US$2,500) ចំពោះលោក **សម រង្ស៊ី** ។

មានបណ្តឹងឧទ្ធរណ៍ចំនួន៩ករណី បានទៅដល់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងនោះមានបណ្តឹងមួយត្រូវបានដកទៅវិញ ចំណែកឯបណ្តឹងដទៃទៀតត្រូវបានច្រានចោល តាមរយៈលិខិត ឬក្រោយពីបានបើកសវនាការ ។

ចំនួនបណ្តឹងដែលបានធ្វើនៅថ្នាក់ **គឃ/សប** ទាបជាងឆ្នាំ២០០៣ យ៉ាងច្រើន (២៤៤ ធៀបនឹង ៥៧៥[៦៨]) ។ នៅឆ្នាំនេះ **គឃ/សប**បានបង្ហាញឆន្ទៈចង់ដាក់ទណ្ឌកម្មចំពោះជនល្មើសច្រើនជាងឆ្នាំ២០០៣ ។ ចំនួនសំណុំរឿងដែលបាន

[៦៨] តួលេខដែលផ្តល់អោយសម្រាប់ឆ្នាំ២០០៣ នេះ គឺជាតួលេខផ្លូវការ ផ្តល់ដោយ **គ.ជ.ប** ។ តួលេខទាំងនេះ ខុសពីតួលេខដែលមាននៅក្នុងរបាយការណ៍ស្ថាពររបស់ EUEOM ឆ្នាំ២០០៣ ។

ទៅដល់ **គ.ជ.ប** មានចំនួន ស្ទើរតែដូចមុន (៤៩ ធៀបនឹង៥១ នៅឆ្នាំ២០០៣) ។ អ្នកសង្កេតការណ៍ EU បានរកឃើញហេតុផលមួយចំនួន ដែលបណ្តាលអោយមានបណ្តឹងតិចជាងកាលពី៥ឆ្នាំមុន : កម្រិតនៃទំនាស់នៅអំឡុងពេលឃោសនារកសំឡេងឆ្នោតនៅឆ្នាំ២០០៨ មានចំនួនទាបជាងឆ្នាំ២០០៣ ។ មានករណីដែល **គឃ/សប** បដិសេធមិនទទួលបណ្តឹង ឬបញ្ចុះបញ្ចូលអោយដើមបណ្តឹងដកពាក្យបណ្តឹង ។ ក្នុងករណីជាច្រើន **គឃ/សប** និង **គខ/កប** បានប្រើការគាបសង្កត់អោយគណបក្សព្រមទទួលយកដំណោះស្រាយផ្សះផ្សា ជាជាងចាប់ផ្តើមនីតិវិធីប្តឹងផ្តល់ផ្លូវការ ដែលជាការខ្វះទំនុកចិត្តយ៉ាងទូលំទូលាយទៅលើរដ្ឋបាលរៀបចំការបោះឆ្នោត ដែលជាទូទៅ ត្រូវគេយល់ឃើញថា មានភាពលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជា ចំណែកឯគណបក្សប្រឆាំងវិញមានការលំបាកក្នុងការស្វែងរកសាក្សី ដែលសុខចិត្តមកបញ្ជាក់នៅក្នុងសវនាការជាពិសេស នៅក្នុងករណីដែលមានលក្ខណៈរសើបផ្នែកនយោបាយ ។ ជាងនេះទៅទៀត អ្នកសង្កេតការណ៍ EU បានរាយការណ៍ថា ឧប្បត្តិហេតុជាច្រើនដែលគេដាក់នៅក្នុងពាក្យបណ្តឹងមានលក្ខណៈតូចតាច ចំណែកឯឧប្បត្តិហេតុធ្ងន់ធ្ងរ ដូចជាការគំរាមកំហែង និងការបំភិតបំភ័យជាដើម ជារឿយៗ មិនត្រូវបានរាយការណ៍ទេ ដោយសារខ្លាចការតបតមកវិញ ។

## ៩. ប្រព័ន្ធផ្សព្វផ្សាយ និងការបោះឆ្នោត

### ក. បរិយាកាសប្រព័ន្ធផ្សព្វផ្សាយ

ជារឿយៗ ប្រទេសកម្ពុជា ត្រូវបានគេចាត់ទុកថា ជាប្រទេសដែលមានស្ថានភាពប្រព័ន្ធផ្សព្វផ្សាយមានលក្ខណៈរស់រវើក និងចម្រុះ នៅក្នុងតំបន់ហ៊ុំព័ទ្ធដោយប្រទេសដែលមានសេរីភាពសារព័ត៌មានតិចតួច ។ កម្ពុជា ជាប់ចំណាត់ថ្នាក់ទី៨៥ ក្នុងចំណោមប្រទេសចំនួន១៦៩ នៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានរបស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (Reporters Sans Frontieres) នាឆ្នាំ២០០៧ ប្រៀបធៀបនឹងប្រទេសថៃ ដែលជាប់ចំណាត់ថ្នាក់ទី១៣៥ ឡាវ ១៦១ វៀតណាម ១៦២ ចិន ១៦៣ និងមីយ៉ានម៉ា ១៦៤ ។ តាមប្រវត្តិសាស្ត្រ កម្ពុជាគ្មានប្រពៃណីមានសេរីភាពសារព័ត៌មានទេតាមរយៈបទពិសោធន៍របស់ខ្លួនក្រោមការគ្រប់គ្រងរបស់អាណានិគមនិយមបារាំងសេស របបផ្តាច់ការខ្មែរក្រហម និងរបបកុម្មុយនីស្តគាំទ្រដោយប្រទេសវៀតណាមដែលបានបន្តវេនពីរបបខ្មែរក្រហម ។ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានគេប្រើជាប្រដាប់បំពងសំឡេងរបស់រដ្ឋាភិបាលបន្តវេន និងជាឧបករណ៍ឃោសនាសុទ្ធសាធ ។

បើនិយាយអំពីសារៈសំខាន់ ទូរទស្សន៍ និងវិទ្យុ ជាបណ្តាញផ្សព្វផ្សាយដែលដណ្តើមគ្នាឈរនៅលំដាប់ទីមួយ ។ ទោះបីជាមានភាពក្រីក្រដ៏រីករាលដាល និងកង្វះអគ្គិសនីក៏ដោយ តាមការសិក្សារបស់មូលនិធិអាស៊ីនៅឆ្នាំ២០០៣ បានរកឃើញថា ចំនួន៥២ភាគរយនៃអ្នកផ្តល់ចម្លើយបានបញ្ជាក់ថា ខ្លួនបានទទួលព័ត៌មាន និងការកំសាន្តតាមរយៈទូរទស្សន៍ និងមាន៣៨ភាគរយនិយាយថា ពួកគេបានស្តាប់វិទ្យុលើសពីបីដងក្នុងមួយសប្តាហ៍ ។ តាមការសិក្សាថ្មីៗនេះមួយក្រោមការផ្តត់ផ្គង់មូលនិធិដោយវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ (International Republican Institute-IRI) នៅខែកុម្ភៈ ឆ្នាំ២០០៧ បានរកឃើញថា ប្រជាជនកម្ពុជាចំនួន៥១ភាគរយប្រើប្រាស់វិទ្យុជាប្រភពព័ត៌មានចម្បងរបស់ខ្លួន និង៣៧ភាគរយប្រើប្រាស់ទូរទស្សន៍ ។ ទូរទស្សន៍ក៏មានវត្តមាននៅតាមតំបន់ក្រីក្រនៃប្រទេសនេះដែរ ជួនកាលត្រូវប្រើម៉ាស៊ីនភ្លើង ហើយអាចមានក្រុមគ្រួសារជាច្រើនមកមើលជុំគ្នានៅពេលព្រលប់ៗ ។ ទូរទស្សន៍ក៏មានប្រជាប្រិយភាពណាស់ដែរនៅតាម

ទីសាធារណៈ ដូចជាហាងកាហ្វេជាដើម ។ វិទ្យុបានមានប្រជាប្រិយភាពចាប់តាំងពីការចែកវិទ្យុឥតគិតថ្លៃជាច្រើន ដោយអង្គការសហប្រជាជាតិ (**អសប**) នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ។

នៅឆ្នាំ២០០៣ មានមនុស្សតែ៩ភាគរយប៉ុណ្ណោះនិយាយថា ខ្លួនអានសារព័ត៌មានជាទៀងទាត់ នេះបណ្តាលមកពីភាពក្រីក្រ និងអនក្ខរភាពជារួម ។ នៅខែកុម្ភៈឆ្នាំ២០០៨ IRI បានប៉ាន់ប្រមាណថា មានប្រជាជនតែ១ភាគរយប៉ុណ្ណោះ ដែលមានលទ្ធភាពអានសារព័ត៌មានជាទៀងទាត់ ។ តួលេខចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិកម្ពុជា នៅឆ្នាំ២០០៤ បានផ្តល់កម្រិតអក្ខរភាព ៧៣,៦ ភាគរយសម្រាប់ប្រទេសកម្ពុជា ប៉ុន្តែ ប្រជាជនជាច្រើនធ្លាប់បានចូលសាលារៀនតែរយៈពេលមួយ ឬពីរឆ្នាំប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ សារព័ត៌មាននៅតែរក្សាឥទ្ធិពលបានមួយកម្រិតដែរ ដោយសារតែវាជាប្រភពព័ត៌មានរបស់ស្ថានីយវិទ្យុនានា ។

ជាទូទៅ វិជ្ជាជីវៈក្នុងរបរសារព័ត៌មាន មានកម្រិតទាបខ្លាំងណាស់ មួយផ្នែកដោយសារកង្វះខាតការអប់រំ និងឱកាសបណ្តុះបណ្តាល ប៉ុន្តែប្រការនេះក៏ដោយសារតែអ្នកសារព័ត៌មានខ្លួនឯងផងដែរដែលបានទទួលប្រាក់កម្រៃមិនសមស្របនោះ ។ អ្នកសារព័ត៌មានមួយចំនួនរកប្រាក់ចំណូលបន្ថែមដោយទាមទារអោយមានការឧបត្ថម្ភអត្ថបទ ដែលគេប្រើប្រាស់ដើម្បីផ្សព្វផ្សាយរឿងរ៉ាវផ្សេងៗ ។ ក្រៅពីនេះ ក៏មានរបាយការណ៍ផងដែរថា អ្នកសារព័ត៌មានមានការពាក់ព័ន្ធនឹងការគំរាមកំហែង ។ នេះជាបរិយាកាសដ៏លំបាកសម្រាប់អាជីពសារព័ត៌មានឯករាជ្យ ទោះបីការគំរាមកំហែង អំពើហឹង្សា និងឃាតកម្មលើបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយមានការធ្លាក់ចុះ បើប្រៀបធៀបនឹងឆ្នាំកន្លងទៅក៏ដោយ ។ ការរិះគន់គ្នាឯង ក្នុងចំណោមអ្នកសារព័ត៌មាន ក៏តែងកើតមានយ៉ាងរាលដាលផងដែរ ។

## *ទូរទស្សន៍*

មានស្ថានីយទូរទស្សន៍ចំនួន៧ នៅកម្ពុជា ក្នុងនោះមាន១ប៉ុស្តិ៍ជារបស់រដ្ឋ និង៦ប៉ុស្តិ៍ទៀតជារបស់ឯកជន ទោះជាយ៉ាងណាក៏ដោយ ស្ថានីយទូរទស្សន៍ទាំង៧នោះ ត្រូវចាត់ទុកថា មានការពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយគណបក្សប្រជាជនកម្ពុជា ដែលកំពុងកាន់អំណាច ។ យោងតាមការស្រាវជ្រាវទីផ្សារ ធ្វើឡើងដោយក្រុមហ៊ុនឥណ្ឌូឆាយណា (Indochina) នៅឆ្នាំ២០០៧ ស្ថានីយទូរទស្សន៍ថ្មីជាងគេនៅក្នុងប្រទេសនេះ គឺបណ្តាញទូរទស្សន៍កម្ពុជា (**ស៊ីធីអិន**) ក៏មានប្រជាប្រិយភាពជាងគេដែរ ។ ទូរទស្សន៍នេះជាកម្មសិទ្ធិរបស់អ្នកជំនួញម្នាក់ ដែលគេមានជំនឿជាទូទៅថាមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សប្រជាជន ។ ស្ថានីយទូរទស្សន៍ប្រកួតប្រជែងឈរក្នុងលំដាប់ទីពីរ គឺទូរទស្សន៍កងយោធពលខេមរភូមិន្ទ (ប៉ុស្តិ៍លេខ៥-ទទខភម) និងទូរទស្សន៍បាយ័ន (ដែលគ្រប់គ្រងដោយកូនស្រីរបស់នាយករដ្ឋមន្ត្រី **ហ៊ុន សែន**) ។ អ្វីដែលគួរអោយចាប់អារម្មណ៍នោះគឺប៉ុស្តិ៍ទូរទស្សន៍ចំនួន២ ដែលពាក់ព័ន្ធជិតស្និទ្ធបំផុតជាមួយគណបក្សប្រជាជនកម្ពុជា ពោលគឺ ទូរទស្សន៍ជាតិកម្ពុជា (**ទ.ទ.ក**) និងទូរទស្សន៍អប្សរា ក៏មានប្រជាប្រិយភាពតិចបំផុតចុងក្រោយគេដែរនៅក្នុងការធ្វើចំណាត់ថ្នាក់នាពេលថ្មីៗនេះ ។

## *វិទ្យុ*

នៅដើមទសវត្សរ៍ ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិ បានចែកវិទ្យុចំនួន ៣៤៦.០០០គ្រឿងដោយឥតគិតថ្លៃ នៅកម្ពុជា ដែលជាដើមចមនៃប្រជាប្រិយភាព និងឥទ្ធិពលរបស់វិទ្យុនៅក្នុងប្រទេសនេះ ។ យោងទៅតាមទិន្នន័យដែលទទួលបាន

នៅខែមិថុនា ឆ្នាំ២០០៧ ក្រសួងព័ត៌មានបានចុះឈ្មោះអោយស្ថានីយវិទ្យុចំនួន ៥៣ ក្នុងនោះមាន ២២ស្ថានីយវិទ្យុនៅភ្នំពេញ ៣១ស្ថានីយនៅក្នុងតំបន់នានា (រាប់បញ្ចូលទាំងស្ថានីយផ្សាយបន្តផងដែរ) ។ លើកលែងតែស្ថានីយវិទ្យុមួយចំនួនតូចប៉ុណ្ណោះ រួមទាំងវិទ្យុជាតិកម្ពុជាផងដែរ ស្ថានីយវិទ្យុភាគច្រើនបំផុតផ្សាយលើរលកអាកាសអេហ្វអឹម (FM) ។

ការរឹតត្បិតរបស់រដ្ឋាភិបាលលើការផ្សព្វផ្សាយរបស់ស្ថានីយទូរទស្សន៍ និងវិទ្យុ បានធានាថា ស្ទើរតែគ្រប់ស្ថានីយទាំងអស់គឺជាស្ថានីយវិទ្យុ និងទូរទស្សន៍ដែលគាំទ្ររដ្ឋាភិបាល ឬមានការប្រយ័ត្នប្រយែងអំពីអ្វីដែលពួកគេផ្សព្វផ្សាយ ។ រដ្ឋាភិបាលជាម្ចាស់កម្មសិទ្ធិដោយផ្ទាល់ ឬមួយភាគលើស្ថានីយវិទ្យុជាច្រើន ហើយស្ថានីយមួយចំនួនទៀតជាកម្មសិទ្ធិរបស់មន្ត្រីរដ្ឋាភិបាល ។ ទោះជាយ៉ាងណាក៏ដោយ ស្ថានីយវិទ្យុអន្តរជាតិ ក៏ទទួលបានប្រជាប្រិយភាពយ៉ាងទូលំទូលាយណាស់ដែរនៅកម្ពុជា ។ តាមការស្ទង់មតិមួយនៅឆ្នាំ២០០៧ ធ្វើឡើងដោយក្រុមហ៊ុន Intermedia អោយវិទ្យុអាស៊ីសេរី (RFA) បង្ហាញអោយឃើញថា អ្នកឆ្លើយសំណួរចំនួន ៥៦ ភាគរយ ដែលរស់នៅក្នុងរង្វង់៨០គីឡូម៉ែត្រនៃក្រុងភ្នំពេញ បានស្តាប់វិទ្យុ RFA និងស្ថានីយវិទ្យុស្រដៀងនេះ (មានដូចជាវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) វិទ្យុបារាំងអន្តរជាតិ (RFI) និងវិទ្យុប៊ីប៊ីស៊ី (BBC) ជាដើម) យ៉ាងទៀងទាត់ ។ វិទ្យុអាស៊ីសេរី RFA និងវិទ្យុសំឡេងសហរដ្ឋអាមេរិក VOA ក៏បានជួលម៉ោងសម្រាប់ការផ្សាយព័ត៌មានរបស់ខ្លួនតាមវិទ្យុឯករាជ្យដូចជាវិទ្យុសម្បុកឃ្មុំ អេហ្វអឹម១០៥ និងវិទ្យុមណ្ឌលព័ត៌មានស្ត្រី កម្ពុជា (អេហ្វអឹម១០២) ជាដើម ។

ជារឿយៗ វិទ្យុសម្បុកឃ្មុំ ជួបប្រទះការលំបាកបណ្តាលមកពីការអនុញ្ញាតអោយគណបក្សប្រឆាំងផ្សព្វផ្សាយនៅក្នុងម៉ោងផ្សាយរបស់ខ្លួន ហើយប្រធានវិទ្យុនេះធ្លាប់ត្រូវបានចាប់ខ្លួនជាច្រើនលើកច្រើនសារ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានរាយការណ៍ថា នៅថ្ងៃទី២១ ខែឧសភា នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានគំរាមកំហែងវិទ្យុសម្បុកឃ្មុំ ដោយសារបានផ្សាយពីគណបក្សប្រឆាំង ដោយបានថ្លែងថា "លោកឯងមានវិទ្យុមួយ យើងមានវិទ្យុ ៣៩ ។ បើលោកឯងជេរខ្ញុំ លោកឯងនឹងបានទទួលផលអាក្រក់ ។ អ្នកដែលធ្លាប់ជេរខ្ញុំ (ពីមុនមក) បានបាត់ខ្លួនពីពិភពលោកនេះអស់ទៅហើយ" ។

### ***សារព័ត៌មាន (កាសែត)***

ប្រជាជនកម្ពុជាប្រមាណជា៨៥ភាគរយរស់នៅតាមតំបន់ជនបទ ជាទីដែលភាពក្រីក្រ និងអនក្ខរភាពមានកម្រិតខ្ពស់ ហើយសារព័ត៌មានកម្រចូលដល់ណាស់ ។ ទោះជាយ៉ាងណាក៏ដោយ សារព័ត៌មានរីកសាយនៅតំបន់ក្រុងច្រើនជាង ។ ក្រសួងព័ត៌មានបានចុះឈ្មោះជាផ្លូវការអោយសារព័ត៌មានជាង ៣០០ បើទោះជាមានតែសារព័ត៌មានមួយចំនួនតូចប៉ុណ្ណោះដែលបង្ហាញវត្តមាននៅតាមតូបលក់កាសែតក៏ដោយ ។ សារព័ត៌មានភាគច្រើនបំផុតបោះពុម្ពផ្សាយមិនទៀងទាត់ទេ ហើយមានលក្ខណៈនយោបាយសុទ្ធសាធ ។

សារព័ត៌មានចំនួនបីដែលលក់ដាច់ជាងគេបំផុត គឺសារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ ***រស្មីកម្ពុជា កោះសន្តិភាព*** និង ***កម្ពុជាថ្មី*** ដែលចេញផ្សាយប្រមាណជា២០.០០០ច្បាប់ (តួលេខចេញផ្សាយមិនអាចជឿទុកចិត្តបានទេ) ។ សារព័ត៌មានដទៃទៀតភាគច្រើនបោះពុម្ពផ្សាយតិចជាងនេះ ប្រមាណ៣-៤.០០០ច្បាប់ ឬតិចជាងនេះ ។

បរិយាកាសប្រព័ន្ធផ្សព្វផ្សាយ ជិតដល់ពេលបោះឆ្នោត ត្រូវធ្វើអោយមានភាពសៅហ្មង ដោយសារការបិទស្ថានីយវិទ្យុអង្គររដ្ឋា ខេត្តក្រចេះ ក្នុងខែឧសភា ការចាប់ និងឃុំខ្លួនជាបណ្តោះអាសន្នពីបទបរិហារកេរ្តិ៍ចំពោះលោក **ដាំ សិទ្ធិ** និពន្ធ-នាយកសារព័ត៌មាន ***មនសិការខ្មែរ*** នៅខែមិថុនា និងឧប្បត្តិហេតុដ៏អាក្រក់បំផុតនៃអំពើឃាតកម្មនៅថ្ងៃទី១១ ខែកក្កដា មកលើរូបលោក **ឃឹម សម្បូណ៌** អ្នកសារព័ត៌មាន ***មនសិការខ្មែរ*** ដែលកូនប្រុសរបស់លោកក៏ត្រូវបាត់បង់ជីវិតផងដែរ នៅក្នុងអំពើបាញ់ប្រហារនេះ ។

ការបិទភ្លាមៗនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំនេះ នូវស្ថានីយវិទ្យុអង្គររដ្ឋាក្នុងខេត្តក្រចេះ នៅពេលដែលវិទ្យុនេះចាប់ផ្តើមផ្សាយកម្មវិធីរបស់គណបក្សប្រឆាំង គឺជាសេចក្តីសម្រេចមួយដែលធ្វើអោយរដ្ឋាភិបាលទទួលរងនូវការរិះគន់ជាថ្មីទាក់ទងនឹងសេរីភាពសារព័ត៌មាន ។ លក្ខខណ្ឌនៅក្នុងអាជ្ញាប័ណ្ណពិតជាមានបញ្ជាក់ថាស្ថានីយវិទ្យុ មិនត្រូវលក់បន្តនូវម៉ោងផ្សាយទៅអោយភាគីទីបី ដោយគ្មានការឯកភាពជាមុនពីសំណាក់រដ្ឋាភិបាលឡើយ ប៉ុន្តែការបិទជាបន្ទាន់នូវស្ថានីយវិទ្យុនេះគឺជាករណីធ្ងន់ធ្ងរហួសហេតុ ។ នេះជាករណីពិសេស ពីព្រោះមានស្ថានីយវិទ្យុតែមួយចំនួនតូចប៉ុណ្ណោះ ដែលអាចផ្សាយដល់ខេត្តក្រចេះ ដូច្នេះហើយពិតជាគ្មានសំឡេងចម្រុះនៅទីនោះឡើយ ។

***មនសិការខ្មែរ*** គឺជាសារព័ត៌មានមួយ ដែលតាមរបាយការណ៍ បោះពុម្ពផ្សាយប្រមាណជា ៤.០០០ច្បាប់ ហើយគាំទ្រគណបក្សសមរង្ស៊ី ។ ចាងហ្វាង និងនិពន្ធនាយកសារព័ត៌មាននេះគឺលោក **ដាំ សិទ្ធិ** ក៏ឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីប្រចាំមណ្ឌលក្រុងភ្នំពេញផងដែរ ។ លោកត្រូវគេចាប់ខ្លួននៅថ្ងៃទី០៨ ខែមិថុនា ពីបទបរិហារកេរ្តិ៍ ។ ការចោទប្រកាន់នេះ ទាក់ទងទៅនឹងការចុះផ្សាយអត្ថបទមួយ ដែលនៅក្នុងនោះ លោក **សម រង្ស៊ី** ត្រូវបានដកស្រង់ប្រសាសន៍ថា បានចោទប្រកាន់រដ្ឋមន្ត្រីក្រសួងការបរទេស **ហោ ណាំហុង** ជាអ្នកទទួលខុសត្រូវចំពោះអំពើឃោរឃៅនៅសម័យខ្មែរក្រហម ។ លោក **ដាំ សិទ្ធិ** ត្រូវចោទប្រកាន់ពីបទរំលោភមាត្រា ៦២ និង៦៣ នៃក្រមព្រហ្មទណ្ឌរបស់អ៊ុនតាក់ ដែលអនុញ្ញាតអោយមានការផ្តន្ទាទោសពីបទផ្សព្វផ្សាយព័ត៌មានមិនពិត បរិហារកេរ្តិ៍ និងបង្ខូចឈ្មោះ ។ នៅថ្ងៃអាទិត្យទី១៥ ខែមិថុនា នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានបញ្ជាអោយដោះលែងលោក **ដាំ សិទ្ធិ** ចេញពីការឃុំខ្លួន ។ លោក **ហោ ណាំហុង** បានដកការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ប្រឆាំងនឹងលោក **ដាំ សិទ្ធិ** ក្រោយពីនិពន្ធនាយករូបនេះបានសុំអភ័យទោសដោយខ្លួនឯងនៅក្នុងលិខិតមួយ ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មាន *រស្មីកម្ពុជា* និង *កោះសន្តិភាព* នៅថ្ងៃទី២៨ ខែមិថុនា ។ នេះជាផ្នែកមួយនៃការសម្រុះសម្រួលដែលបានព្រមព្រៀងគ្នា ដោយមានអន្តរាគមន៍ពីក្លឹបអ្នកសារព័ត៌មានកម្ពុជា (**កអក**) ។

ការរំលោភដ៏ធំបំផុតទៅលើសេរីភាពសារព័ត៌មាននៅអំឡុងពេលយុទ្ធនាការរកសំឡេងឆ្នោត គឺអំពើឃាតកម្មលើរូបអ្នកសារព័ត៌មាន *មនសិការខ្មែរ* ឈ្មោះ **ឃឹម សម្បូណ៌** និងកូនប្រុសរបស់លោក នៅថ្ងៃទី១១ ខែកក្កដា ។ អ្នកទាំងពីរត្រូវខ្មាន់កាំភ្លើងមិនស្គាល់អត្តសញ្ញាណម្នាក់បាញ់សម្លាប់នៅជិតពហុកីឡដ្ឋានជាតិអូឡាំពិក ។ លោក **ឃឹម សម្បូណ៌** ល្បីខាងសរសេរអត្ថបទរិះគន់គណបក្សកាន់អំណាច ដែលជាធម្មតាធ្វើឡើងក្រោមរហស្សនាមសារព័ត៌មាន *មនសិការខ្មែរ* ។ តាមការពិនិត្យឡើងវិញនូវអត្ថបទរបស់លោកសម្រាប់ខែមិថុនា និងខែកក្កដា ឆ្នាំ២០០៨ បង្ហាញអោយឃើញអត្ថបទមួយចុះ ថ្ងៃទី០៤ ខែកក្កដា ដែលធ្វើការពណ៌នាពីកំហឹងរបស់នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ចំពោះការទាមទាររបស់ធនាគារពិភពលោក អោយបង្វែរមូលនិធិដែលបានចំណាយមិនត្រឹមត្រូវទៅលើការកាត់វិសាយទ័ព អត្ថបទចុះថ្ងៃទី២០ ខែមិថុនា ដែលបើកកកាយ

អភិបាលខេត្ត និងកងរាជអាវុធហត្ថពីររូបនៅខេត្តរតនគីរី ចំពោះរឿងអាស្រូវពុករលួយ អត្ថបទចុះថ្ងៃទី១៧ ខែមិថុនា ដែលរាយការណ៍អំពីកូនប្រុសរបស់លោក **អៀង សារី** ជាអតីតមេកងយុវជនខ្មែរក្រហម ដែលបច្ចុប្បន្នជាមន្ត្រីរដ្ឋាភិបាល និងអត្ថបទផ្សេងៗទៀតដែលនិយាយអំពីការលាងលុយកខ្វក់ពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋជន អាជីវករជនជាតិកូរ៉េ និងចិន ព្រមទាំងធនាគារកម្ពុជានានា ផងដែរ ។

មានការអំពាវនាវភ្លាមៗអោយនាំខ្លួនឃាតកសម្លាប់លោក **ឃឹម សម្បូណ៌** ទៅតុលាការ ក្នុងនោះរួមមានទាំងការអំពាវនាវពីសំណាក់រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាអ្នកនាំពាក្យរដ្ឋាភិបាល លោក **ខៀវ កាញារិទ្ធ** ដែលបានចូលរួមពិធីបុណ្យសពរបស់លោក **ឃឹម សម្បូណ៌** ផងដែរ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch-HRW) បានចេញសេចក្តីថ្លែងការណ៍មួយ ហៅឃាតកម្មនោះថាជា "សារមួយមិនអោយប្រឡូកក្នុងនយោបាយ" (**ប្រេដ អាដាម** នាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំតំបន់អាស៊ី) ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានអំពាវនាវអោយរដ្ឋាភិបាលធ្វើការស៊ើបអង្កេតជាបន្ទាន់ ហ្មត់ចត់ និងគួរអោយជឿទុកចិត្តបាន ដោយបញ្ជាក់ថា ឃាតកម្ម និងការប៉ុនប៉ងធ្វើឃាតស្រដៀងៗនេះចំនួន៨ ផ្សេងទៀតទៅលើអ្នកសារព័ត៌មាន តាំងពីឆ្នាំ១៩៩៤ មិនត្រូវបានដោះស្រាយឡើយ ។

ឃាតកម្មនេះ មានសារៈសំខាន់ជាពិសេស ពីព្រោះវាបានធ្វើអោយបាត់បង់ជីវិតអ្នកសារព័ត៌មានម្នាក់ដែលល្បីល្បាញខាងសរសេរអត្ថបទអោយសារព័ត៌មានប្រឆាំង ហើយអំពើនេះបានកើតមានឡើងនៅអំឡុងពេលឃោសនារកសំឡេងឆ្នោតផ្ទាល់តែម្តង ។ ឥទ្ធិពលនៃឃាតកម្មលើអ្នកសារព័ត៌មានរូបនេះ គឺបង្កើនអោយមានការភ័យខ្លាចក្នុងចំណោមសហគមន៍អ្នក-សារព័ត៌មាន និងគណបក្សប្រឆាំង ចំពោះផលវិបាកនៃការរិះគន់រដ្ឋាភិបាល ។

នៅថ្ងៃទី១០ ខែកក្កដា លោក **សុកលះ ទីប៉ោ** អគ្គនាយករងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (**គ.ជ.ប**) ជាអ្នកទទួលខុសត្រូវចំពោះប្រព័ន្ធផ្សព្វផ្សាយ បានអំពាវនាវអោយក្រុមហ៊ុនផ្សព្វផ្សាយចំនួន១៣ ដោយព្រមានពួកគេអោយឈប់រំលោភច្បាប់បោះឆ្នោត ដោយសារការផ្សព្វផ្សាយគ្មានតុល្យភាព ។ ទូរទស្សន៍ និងវិទ្យុអប្សរាអេហ្វអឹម៩៧ ទូរទស្សន៍ប៉ុស្តិ៍លេខ៣ ព្រមទាំងស្ថានីយវិទ្យុអេហ្វអឹម១០៣របស់ទូរទស្សន៍នេះ បណ្តាញទូរទស្សន៍កម្ពុជា **ស៊ីធីអិន** ទូរទស្សន៍បាយ័ន ព្រមទាំងស្ថានីយវិទ្យុចំនួន៥ទៀត (រួមមាន អេហ្វអឹម៨៨, អេហ្វអឹម៩៥ អេហ្វអឹម៩៨ អេហ្វអឹម៩៩) ត្រូវបានចោទប្រកាន់ដោយ **គ.ជ.ប** ថាបានលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជា។ វិទ្យុអាស៊ីសេរី និងវិទ្យុសំឡេងសហរដ្ឋអាមេរិកត្រូវព្រមានអំពីការចំណាយពេលច្រើនពេកទៅលើគណបក្សប្រឆាំង និងរិះគន់គណបក្សប្រជាជនកម្ពុជា ចំណែកវិទ្យុអេហ្វអឹម ៩០ ត្រូវព្រមានអំពីការលម្អៀងទៅរកគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ។

លោក **សុខ ឥសាន្ត** នាយកវិទ្យុអប្សរា បានច្រានចោលការរិះគន់របស់ **គ.ជ.ប** ព្រមទាំងបានថ្លែងថា លោកនឹងមិនផ្លាស់ប្តូរកម្មវិធីរបស់លោកឡើយ ។ ការផ្សាយដំណាលគ្នាតាមស្ថានីយវិទ្យុចំនួន៤០ នៅថ្ងៃទី១៤ ខែកក្កដា លោក **សុខ ឥសាន្ត** ហៅលោក **សម រង្ស៊ី** ថាជា ជនភូតភរ និងបាននិយាយថា បញ្ហាលេងល្បែងរបស់លោក **អេង នៃអៀង** អគ្គលេខាធិការគណបក្ស **សម រង្ស៊ី** នឹងនាំប្រទេសជាតិធ្លាក់ទឹក ហើយបានរៀបរាប់អំពីការងារដ៏អស្ចារ្យរបស់គណបក្សប្រជាជនកម្ពុជា ដែលបានកសាងសាលារៀន ហើយថា គណបក្សប្រជាជនកម្ពុជា គឺជាគណបក្សតែមួយគត់ដែលមានទស្សនៈ-វិស័យច្បាស់លាស់ ។

នៅក្នុងជំនួបប្រជុំមួយជាមួយ EU-EOM លោកអគ្គនាយករង **សុកលៈ ទីប៉ោ** បានលើកដដែលៗអំពីទស្សនៈដូចគ្នានឹងរដ្ឋមន្ត្រីក្រសួងព័ត៌មាន **ខៀវ កាញារីទ្ធ** និងអគ្គលេខាធិការ **គ.ជ.ប** លោក **ទេព នីថា** (បោះពុម្ពផ្សាយនៅក្នុងកាសែត***ឌឹ ប៉ៃមបូឌា ដេលី*** នៅថ្ងៃទី១៥ ខែកក្កដា និងកាសែត*ឌឹ មេគង្គថៃមស៍* នៅថ្ងៃទី១៧ ខែកក្កដា) ថា ប្រព័ន្ធផ្សព្វផ្សាយដែលគាំទ្រគណបក្សប្រជាជនកម្ពុជា ត្រូវទប់ទល់អោយមានតុល្យភាពដោយវិទ្យុ VOA និង RFA គាំទ្រដោយសហរដ្ឋអាមេរិក ដែលរិះគន់គណបក្សប្រជាជនកម្ពុជា ។ ការអត់អោនរបស់រដ្ឋាភិបាលចំពោះការចាក់ផ្សាយឡើងវិញរបស់វិទ្យុទាំងពីរនេះតាមវិទ្យុអេហ្វអឹម១០២ និងវិទ្យុអេហ្វអឹម១០៥ ព្រមទាំងពេលម៉ោងផ្សាយឥតគិតថ្លៃ ផ្តល់ដល់គណបក្សនយោបាយទាំងអស់ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ គឺជាផ្នែកដ៏សំខាន់មួយនៃការបញ្ជាក់អះអាងរបស់គណបក្សកាន់អំណាចថា សេរីភាពសារព័ត៌មាន ពិតជាមាននៅក្នុងប្រទេសកម្ពុជា ។

គំនិតដែលថា ការគ្របដណ្តប់របស់រដ្ឋាភិបាលលើរលកអាកាសផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន មានតុល្យភាពជាមួយវត្តមាននៃរបាយការណ៍ប្រឆាំងនៅតាមស្ថានីយវិទ្យុមួយចំនួនតូចដែលផ្សព្វផ្សាយមិនសូវបានឆ្ងាយ និងដែលធ្វើឡើងដោយគណបក្សប្រឆាំង ពិតជាមិនសមឡើយ ។ ឱកាសសម្រាប់គណបក្សប្រឆាំង ឬសំឡេងរិះគន់ ពិតជាតូចចង្អៀតខ្លាំងណាស់ដើម្បីទប់ទល់នឹងការឃោសនាគាំទ្ររដ្ឋាភិបាល ។

នៅថ្ងៃទី២៦ ខែកក្កដា ក្រសួងព័ត៌មាន ក្នុងនាម **គ.ជ.ប** បានបញ្ជូនមន្ត្រីក្រសួង នគរបាល និងកងរាជអាវុធហត្ថមួយក្រុមទៅកាន់ស្ថានីយវិទ្យុអេហ្វអឹម៩៣.៥ ដើម្បីបិទស្ថានីយវិទ្យុនេះ ។ ស្ថានីយវិទ្យុនេះ បានទទួលការព្រមានជាច្រើនដងនៅថ្ងៃនោះ ចំពោះការផ្សាយកម្មវិធីពន្លឺភ្លើងទៀនរបស់គណបក្សសមរង្ស៊ី ដែលផ្តោតទៅលើឈ្មោះដែលត្រូវលុបពីបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចំពោះកម្មវិធីមួយ ដែលមានផ្សាយការដកស្រង់ជីវប្រវត្តិលោក **សម រង្ស៊ី** នៅពេលល្ងាច ។ ថ្ងៃទី២៦ ខែកក្កដា ជាអំឡុងពេលដែលប្រព័ន្ធផ្សព្វផ្សាយរក្សាភាពស្ងៀមស្ងាត់ តាមច្បាប់របស់ **គ.ជ.ប** ដើម្បីទុកពេលអោយប្រជាជនពិចារណាមុនពេលបោះឆ្នោត ។ នាយកស្ថានីយវិទ្យុនេះ មិនឯកភាពចំពោះការរិះគន់ពីក្រសួងឡើយ ដោយថ្លែងថាគ្មានកម្មវិធីណាមួយ ជាកម្មវិធីឃោសនារកសំឡេងឆ្នោតឡើយ ដូច្នេះលោកក៏សម្រេចចិត្តបន្តការផ្សាយ ។ ក្រសួងព័ត៌មានមានសិទ្ធិបិទកម្មវិធីផ្សាយណាដែលរំលោភបទប្បញ្ញត្តិស្តីពីការបោះឆ្នោត ទោះជាយ៉ាងណាក៏ដោយ ការបិទស្ថានីយវិទ្យុនេះទាំងស្រុងដូច្នេះ គឺជាការបង្ហាញនូវការអនុវត្តច្បាប់គ្មានសមាមាត្រនៅក្នុងពេលឃោសនារកសំឡេងឆ្នោត ដែលនៅអំឡុងពេលនេះជាធម្មតា ប្រព័ន្ធផ្សព្វផ្សាយតែងតែមិនអើពើចំពោះច្បាប់បោះឆ្នោត ស្តីពីភាពមិនលម្អៀង និងលទ្ធភាពទទួលព័ត៌មានដោយគ្មានផលវិបាកផ្លូវការណាមួយទេ ។

## ខ. ក្របខ័ណ្ឌច្បាប់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ និងការបោះឆ្នោត

ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាត្រូវបានកំណត់ដោយលិខិតូបករណ៍នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីរបបសារព័ត៌មាន និងក្រមព្រហ្មទណ្ឌអ៊ុនតាក់ ។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញ ការពារសេរីភាពបញ្ចេញមតិ សារព័ត៌មាន ការបោះពុម្ពផ្សាយ និងការប្រមូលផ្តុំ ។ ជាងនេះទៅទៀត កម្ពុជាជាប្រទេសហត្ថលេខីនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយឆ្នាំ១៩៦៦ ។

ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ មានបទប្បញ្ញត្តិមួយចំនួន សម្រាប់ការពារអ្នកសារព័ត៌មាន រួមទាំងការហាមឃាត់ចំពោះការរឹតត្បិតមុនពេលបោះពុម្ពផ្សាយ និងសិទ្ធិការពារប្រភពព័ត៌មានផងដែរ ។ ច្បាប់នេះក៏មានការហាមប្រាមចំពោះឯកសារមានលក្ខណៈអុជអាលដែលប៉ះពាល់ដល់សន្តិសុខជាតិ ដែលនាំអោយមានទោសយ៉ាងធ្ងន់ធ្ងរគួរសមទៀតផងដែរ (ពិន័យរដ្ឋប្បវេណីរហូតដល់ទៅចំនួន ៣.៧៥០ ដុល្លារអាមេរិក ការរឹបអូស ការផ្អាកការបោះពុម្ពផ្សាយរយៈពេលមួយខែ) ។ ការហាមប្រាមលើការប្រមាថកិត្តិយស និងសេចក្តីថ្លៃថ្នូរ មានសេចក្តីមិនសូវច្បាស់លាស់ទេ មានន័យថា គេអាចប្រើប្រាស់បទប្បញ្ញត្តិនេះបាន ដោយមិនគិតថា ការរិះគន់នោះសមហេតុផល ឬយ៉ាងណានោះទេ ។ នៅឆ្នាំ២០០៦ គេបានចាត់ទុកជាជំហ៊ានដ៏ធំមួយនៅពេលការផ្តន្ទាទោសជាប់ពន្ធនាគារ ត្រូវបានដកចេញពីជម្រើសមួយសម្រាប់ដោះស្រាយបទបរិហារកេរ្តិ៍ ។ ទោះជាយ៉ាងណាក៏ដោយ គេកម្រប្រើប្រាស់មធ្យោបាយច្បាប់រដ្ឋប្បវេណីណាស់ ។

ផ្ទុយទៅវិញ អ្នកមានអំណាចនៅក្នុងសង្គមកម្ពុជា មានទំនោរប្រើប្រាស់ក្រមព្រហ្មទណ្ឌអ៊ុនតាក់ឆ្នាំ១៩៩២ ដើម្បីកែតម្រូវអត្ថបទសារព័ត៌មានដែលគេយល់ឃើញថាមានលក្ខណៈអសុរោះមកលើខ្លួន ។ មាត្រា ៦២ និយាយអំពីអំពើ "ផ្សាយព័ត៌មានមិនពិត" ក្នុងករណីបោះពុម្ពផ្សាយព័ត៌មានខុសដោយ "ចេតនាព្យាបាទ" ដែលនាំអោយមានការផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ទៅរយៈពេលបីឆ្នាំ ។ មាត្រា ៦៣ និយាយអំពីការបោះពុម្ពផ្សាយ ដែលរំខានដល់សន្តិភាព សាធារណៈ ។ លោក **ដាំ សិទ្ធិ** និពន្ធនាយកសារព័ត៌មាន*មនសិការខ្មែរ* និងជាបេក្ខជនតំណាងរាស្ត្រគណបក្សសមរង្ស៊ី ត្រូវចោទប្រកាន់នៅខែមិថុនា ឆ្នាំ២០០៨ ថាបានរំលោភមាត្រាទាំងពីរនេះ ។

គ្មានច្បាប់ស្តីពីការផ្សព្វផ្សាយទេ ហើយបច្ចុប្បន្ននេះ ក្រសួងព័ត៌មានជាអ្នកចេញអាជ្ញាប័ណ្ណ ។ តាមប្រភពគួរអោយជឿទុកចិត្តនានានៅក្នុងប្រព័ន្ធផ្សព្វផ្សាយដែលរណបអោយគណបក្សប្រជាជនកម្ពុជា បាននិយាយជាសាធារណៈ និងចំពោះ EU EOM ថា អាជ្ញាប័ណ្ណ ត្រូវផ្តល់អោយ ផ្អែកតាមការសន្យារបស់ក្រុមហ៊ុនផ្សព្វផ្សាយថានឹងគាំទ្រគោលនយោបាយរដ្ឋាភិបាល ។ ជាមួយគ្នានេះដែរ ត្រូវមានការយល់ព្រមជាមុនពីរដ្ឋាភិបាល ចំពោះការលក់បន្តម៉ោងផ្សាយទៅអោយភាគីទីបី ។ EU EOM ពុំអាចរកឃើញមូលដ្ឋាននេះនៅក្នុងច្បាប់ចំពោះបទប្បញ្ញត្តិទាំងនេះឡើយ ផ្ទុយទៅវិញ ចំណុចនេះនាំអោយមានការសង្ស័យចំពោះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសេរីភាពបញ្ចេញមតិ ។

សិទ្ធិ និងការទទួលខុសត្រូវរបស់ប្រព័ន្ធផ្សព្វផ្សាយ នៅអំឡុងពេលបោះឆ្នោត មានចែងនៅក្នុងជំពូកទី៧ នៃ **ច.ប.ត.រ** ។ ការរៀបចំកម្មវិធីសមធម៌ (ជាទម្រង់ប្រកាសឃោសនា កិច្ចពិភាក្សាតុមូល សុន្ទរកថា និងកម្មវិធីផ្សេងៗ) ត្រូវអនុវត្តតាមឧបករណ៍ផ្សព្វផ្សាយរបស់រដ្ឋ (៧.១៤.៦.៦) ។ ប្រព័ន្ធផ្សព្វផ្សាយឯកជន ត្រូវបានអនុញ្ញាតអោយទទួលផ្សាយប្រកាសឃោសនាទាំងនេះ ជាថ្នូរនឹងការបង់ថ្លៃ ប៉ុន្តែត្រូវធ្វើឡើងក្នុងមូលដ្ឋានឱកាសស្មើគ្នា ។ ប្រសិនបើពួកគេបដិសេធមិនទទួលផ្សព្វផ្សាយអោយគណបក្សនយោបាយ គេត្រូវបដិសេធចំពោះគ្រប់គណបក្សនយោបាយទាំងអស់ (៧.១៤.៥.៣) ។

ការស្ទង់មតិ និងការបោះពុម្ពផ្សាយលទ្ធផលនៃការស្ទង់មតិ ត្រូវបញ្ឈប់ រយៈពេល៥ថ្ងៃ មុនថ្ងៃបោះឆ្នោត រាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតផ្ទាល់ផងដែរ (៧.២.៥) ។ **គ.ជ.ប** បានប្រកាសនៅថ្ងៃទី១៧ ខែមិថុនា អំពីវិធានសម្រាប់ការឃោសនាតាមប្រព័ន្ធផ្សព្វផ្សាយ នៅក្នុងរយៈពេលយុទ្ធនាការឃោសនាររកសំឡេងឆ្នោត ៣០ថ្ងៃ ដូចតទៅនេះ :

- គណបក្សនយោបាយនីមួយៗ ត្រូវបានទទួលរយៈពេល១០នាទី ក្នុងមួយថ្ងៃ ដើម្បីផ្សព្វផ្សាយស្ប៉តតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ។

- កិច្ចពិភាក្សាតុមូលត្រូវផ្សព្វផ្សាយប្រចាំថ្ងៃ ដោយផ្តល់រយៈពេលផ្សាយបន្ថែម១០នាទី ដល់គណបក្សនយោបាយនីមួយៗ ដើម្បីផ្សព្វផ្សាយគណបក្សរបស់ខ្លួន ។
- គណបក្សនយោបាយអាចទិញម៉ោងផ្សាយពីក្រុមហ៊ុនផ្សព្វផ្សាយឯកជន ដើម្បីផ្សព្វផ្សាយស្ប៉តរបស់ខ្លួនឡើងវិញបានរហូតដល់បីដងក្នុងមួយថ្ងៃ ។

តាមគោលការណ៍ណែនាំរបស់ **គ.ជ.ប** ចំពោះប្រព័ន្ធផ្សព្វផ្សាយ ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋមានកាតព្វកិច្ចផ្សាយព័តិមានទាក់ទងនឹងការបោះឆ្នោត និងការអប់រំអ្នកបោះឆ្នោតដោយឥតគិតថ្លៃ តាមការស្នើសុំរបស់ **គ.ជ.ប** ។ ប្រព័ន្ធផ្សព្វផ្សាយឯកជន ត្រូវលើកទឹកចិត្តអោយផ្សព្វផ្សាយព័តិមានបោះឆ្នោតដែរ ប៉ុន្តែ មិនមានកាតព្វកិច្ចថាត្រូវតែផ្សព្វផ្សាយឡើយ ។

ចាប់តាំងពីការបោះឆ្នោតនៅឆ្នាំ២០០៣ **គ.ជ.ប** បានបង្កើនរយៈពេលផ្សាយដោយឥតគិតថ្លៃចំពោះគណបក្សនយោបាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ រហូតដល់ទៅ១០នាទីក្នុងមួយថ្ងៃ ។ ជាក់ស្តែង គណបក្សនយោបាយនានាបានទទួលម៉ោងផ្សាយដោយឥតគិតថ្លៃលើសពីរយៈពេល១០នាទីទៅទៀត ។ នៅតាមស្ថានីយទូរទស្សន៍រដ្ឋ **ទ.ទ.ក** មានកម្មវិធីដូចតទៅនេះ :

- ***ព័តិមានសមធម៌ :*** ឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) គឺជាការផ្សព្វផ្សាយដំណឹងប្រចាំថ្ងៃ រយៈពេលប្រហែលជា២០នាទី ដោយបែងចែកពេលវេលារវាងគណបក្សនយោបាយនានា ដោយស្មើភាពគ្នា (ផ្អែកតាមលទ្ធផលបោះឆ្នោតកន្លងមកក្នុងលក្ខខណ្ឌថាតើគណបក្សទាំងនោះដាក់បេក្ខជនគ្រប់ខេត្ត ឬយ៉ាងណា ។ល។) ។ កម្មវិធីនេះផ្សាយពីរដងក្នុងមួយថ្ងៃ និងមាន***កម្មវិធីសមធម៌ប្រចាំសប្តាហ៍***ពីរដងក្នុងមួយសប្តាហ៍) ។
- ***កម្មវិធីសមធម៌*** របស់ **គ.ជ.ប** ផ្តល់អោយគណបក្សនានារយៈពេល១០នាទី ក្នុងមួយថ្ងៃ ដើម្បីថ្លែងដោយផ្ទាល់ទៅកាន់សាធារណជន ដោយគ្មានការរំខាន ។ គណបក្សតូចៗមួយចំនួន មិនបានប្រើប្រាស់រយៈពេលទាំងអស់របស់ខ្លួនទេ ពីព្រោះគេមិនចង់ថ្លែងរយៈពេលយូររហូតដល់ទៅ១០នាទី ក្នុងមួយថ្ងៃឡើយ ដូច្នេះហើយបទបង្ហាញរបស់ពួកគេក៏មានរយៈខ្លីដែរ ។
- កិច្ចពិភាក្សារយៈពេល២២ម៉ោង រវាងគណបក្សនានា ក្រោមការផ្គត់ផ្គង់មូលនិធិរបស់ NDI ដោយការបែងចែកពេលវេលាស្មើគ្នារវាងគណបក្សទាំងនោះ ក្នុងនោះមានរយៈពេល៨ម៉ោងត្រូវផ្សព្វផ្សាយតាមទូរទស្សន៍ **ទ.ទ.ក** (មានការផ្សាយឡើងវិញ) ។ កិច្ចពិភាក្សាដេញដោលចំនួន២២ ត្រូវផ្សាយតាមស្ថានីយវិទ្យុអេហ្វអឹម១០៥ (វិទ្យុសម្បុកឃ្មុំ) វិទ្យុអេហ្វអឹម៩៣.៥ និងវិទ្យុអេហ្វអឹម៩០ ។
- IRI ក៏បានឧបត្ថម្ភកិច្ចពិភាក្សាដេញដោលនេះដែរ ប៉ុន្តែសម្រាប់ក្រុមយុវជនរបស់គណបក្សនយោបាយនានា ដែលក្នុងនោះកិច្ចពិភាក្សាដេញដោលមួយ ត្រូវផ្សាយតាមស្ថានីយទូរទស្សន៍ឯកជន **ស៊ីធីអិន** ក្នុងអំឡុងពេលដែលមានអ្នកទស្សនាច្រើនបំផុត នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ ។

មានគណបក្សតូចៗមួយចំនួន រួមទាំងគណបក្សខ្មែរឈប់ក្រ និងគណបក្សសង្គមយុត្តិធម៌ ផងដែរ បានតវ៉ាទៅកាន់ **គ.ជ.ប** នៅពេលចាប់ផ្តើមនៃយុទ្ធនាការឃោសនារកសំឡេងឆ្នោត និងបន្ទាប់មកទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ទាក់ទងទៅនឹង

ការបែងចែករយៈពេលផ្សព្វផ្សាយដោយឥតគិតថ្លៃនៅក្នុងកម្មវិធី ***ព័ត៌មានសមធម៌*** ។ ការប្តឹងតវ៉ារបស់គណបក្សទាំងនេះទាក់ទងនឹងការដែលកម្មវិធី ***ព័ត៌មានសមធម៌*** ត្រូវបែងចែកភាគរយនៃរយៈពេលផ្សាយ ទៅអោយគណបក្សដែលធំជាងរឹងមាំជាង ច្រើនជាងគណបក្សដែលទើបបង្កើត និងតូចជាង (ឧទាហរណ៍ គណបក្សប្រជាជនកម្ពុជាបានទទួល ២០ភាគរយ គណបក្សសមរង្ស៊ី ១៣ភាគរយ គណបក្សហ៊្វុនស៊ិនប៉ិច ១១ភាគរយ គណបក្សសិទ្ធិមនុស្ស ៨ភាគរយ គណបក្សខ្មែរឈប់ក្រ ៤ភាគរយ គណបក្សសង្គមយុត្តិធម៌ ៣ភាគរយ) ។ បណ្តឹងទាំងនេះពុំមានមូលដ្ឋានពិតប្រាកដឡើយ ដោយសារកម្មវិធី ***ព័ត៌មានសមធម៌*** គឺតំណាងអោយម៉ោងផ្សាយឥតគិតថ្លៃបន្ថែមសម្រាប់គ្រប់គណបក្សទាំងអស់ ហើយបណ្តឹងនេះក៏ត្រូវបដិសេធ ។ តាមរយៈការផ្សាយឡើងវិញ គណបក្សនានាបានទទួលរយៈពេលផ្សាយឥតគិតថ្លៃជិត២០នាទី ក្នុងមួយថ្ងៃតាមទូរទស្សន៍រដ្ឋ ។

### គ. ការតាមដានការផ្សព្វផ្សាយអំពីការបោះឆ្នោតរបស់ប្រព័ន្ធផ្សព្វផ្សាយ

ក្រុមតាមដានប្រព័ន្ធផ្សព្វផ្សាយរបស់ EU EOM បានពិនិត្យមើលគំរូតាងរបស់ការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ និងប្រព័ន្ធផ្សព្វផ្សាយតាមឯកសារបោះពុម្ព ។ ទូរទស្សន៍ និងវិទ្យុត្រូវបានត្រួតពិនិត្យតាមដានក្នុងអំឡុងពេលដែលមានអ្នកទស្សនា និងស្តាប់ច្រើនបំផុត ។ រយៈពេល និងឱកាសផ្សព្វផ្សាយដែលផ្តល់ជូនគណបក្សនយោបាយ និង រដ្ឋាភិបាល ព្រមទាំងភាពស្មើគ្នានៃការផ្សព្វផ្សាយ (អវិជ្ជមាន អព្យាក្រឹត ឬវិជ្ជមាន) ត្រូវបានវាយតម្លៃ ។ ប្រព័ន្ធផ្សព្វផ្សាយខាងក្រោមនេះ ត្រូវបានតាមដាននៅអំឡុងពេលនៃប្រតិបត្តិការ :

| | **ទូរទស្សន៍ ម៉ោង១៨០០-២៣០០** |
|---|---|
| ១. | ទ.ទ.ក |
| ២. | ស៊ីធីអិន |
| ៣. | អប្សរា |
| ៤. | បាយ័ន |
| ៥. | កងយោធពលខេមរភូមិន្ទ ប៉ុស្តិ៍លេខ៥ |
| ៦. | ប៉ុស្តិ៍លេខ៩ |
| | **វិទ្យុ ម៉ោង ០៦០០-០៩០០** |
| ១. | វិទ្យុជាតិកម្ពុជា អេហ្វអឹម៩៦ |
| ២. | អប្សរា អេហ្វអឹម៩៧ |
| ៣. | សម្បុកឃ្មុំ អេហ្វអឹម១០៥ |
| ៤. | មណ្ឌលព័ត៌មានស្ត្រីកម្ពុជា អេហ្វអឹម១០២ |
| ៥. | រាជធានីភ្នំពេញ អេហ្វអឹម១០៣ |
| | **សារព័ត៌មាន (កាសែត)** |

| | |
|---|---|
| ១. | រស្មីកម្ពុជា |
| ២. | កោះសន្តិភាព |
| ៣. | កម្ពុជាថ្មី |
| ៤. | មនសិការខ្មែរ |
| ៥. | សំឡេងយុវជនខ្មែរ |

លទ្ធផលត្រូវប្រមូលមកពីការអាត់សំឡេង/រូបភាពទូរទស្សន៍ និងវិទ្យុ និងច្បាប់ចម្លងរបស់សារព័ត៌មាន ចាប់ពីថ្ងៃទី ២១ ខែមិថុនា ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។

ការផ្សព្វផ្សាយអំពីការបោះឆ្នោតរបស់ប្រព័ន្ធផ្សព្វផ្សាយ ត្រូវគ្រប់ដណ្តប់ដោយគណបក្សកាន់អំណាច ក្នុងកម្រិតមួយដែលមិនស្របនឹងបទដ្ឋានអន្តរជាតិស្តីពីលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយសេរី និងស្មើភាពសម្រាប់គណបក្សប្រកួតប្រជែងក្នុងការបោះឆ្នោតទាំងអស់ឡើយ ។

គ្រប់គណបក្សប្រឆាំងទាំងអស់បានទទួលលទ្ធភាពផ្សព្វផ្សាយនៅទូរទស្សន៍រដ្ឋ **ទ.ទ.ក** និងវិទ្យុរដ្ឋ **វ.ជ.ក** យោងតាមច្បាប់បោះឆ្នោត ព្រមទាំងម៉ោងផ្សាយឥតគិតថ្លៃនៅតាមវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា អេហ្វអឹម១០២ ដោយមានគណបក្ស៥ បានជួលម៉ោងផ្សាយនៅរលកអាកាសវិទ្យុសម្បុកឃ្មុំអេហ្វអឹម១០៥ ។ មានស្ថានីយវិទ្យុឯកជន ឬវិទ្យុគណបក្សមួយចំនួនតូច បានផ្សាយពីគណបក្សប្រឆាំងដែរ ។ សារព័ត៌មាន មានសេរីភាពផ្សាយពីគណបក្សណាមួយដែលខ្លួនពេញចិត្ត ។ ទោះជាយ៉ាងណាក៏ដោយ ទាក់ទងនឹងការផ្សាយជារួម ការគ្រប់ដណ្តប់របស់គណបក្សប្រជាជនកម្ពុជា អាចរារាំងដល់លទ្ធភាពប្រជាជនកម្ពុជា ក្នុងការទទួលព័ត៌មានក្នុងបរិមាណគ្រប់គ្រាន់ អំពីគណបក្សនានា ដើម្បីធ្វើការជ្រើសរើសដោយមានព័ត៌មានគ្រប់គ្រាន់ ។

ស្ថានីយទូរទស្សន៍បានចំណាយការផ្សាយបន្តិចបន្តួចបំផុតអំពីគណបក្សប្រឆាំង ជាទូទៅក្នុងទំនោរអវិជ្ជមាន ។ ផ្ទុយទៅវិញ គេបានផ្តោតទៅលើអ្វីដែលគេហៅថាសមិទ្ធិផលជាវិជ្ជមានជាច្រើនរបស់គណបក្សប្រជាជនកម្ពុជានៅក្នុងរដ្ឋាភិបាល ។ ស្ថានីយទូរទស្សន៍រដ្ឋ **ទ.ទ.ក** បានចំណាយម៉ោងផ្សាយជាច្រើនដល់គ្រប់គណបក្សទាំងអស់ នៅអំឡុងពេលឃោសនារកសំឡេងឆ្នោត៣០ថ្ងៃ ដោយបំពេញកាតព្វកិច្ចផ្នែកបច្ចេកទេសរបស់ខ្លួនចំពោះ **គ.ជ.ប** និងផ្តល់ពេលបន្ថែមដល់គណបក្សនានាក្នុងកិច្ចពិភាក្សាដេញដោលដែលចាក់ផ្សាយតាមទូរទស្សន៍ រៀបចំឡើងដោយ NDI ។ ជាមួយគ្នានេះដែរ **ទ.ទ.ក** ក៏បានផលិតកម្មវិធីព័ត៌មានសមធម៌អំពីការបោះឆ្នោតផ្សាយតាមទូរទស្សន៍ប្រកបដោយវិជ្ជាជីវៈបំផុត ហៅថា***ព័ត៌មានសមធម៌*** ក្រោមជំនួយឧបត្ថម្ភរបស់អង្គការ UNDP ។ ប៉ុន្តែ គេមិនបានកាត់បន្ថយមុខងារឃោសនារបស់ខ្លួននៅអំឡុងពេលបោះឆ្នោត ដោយចំណាយពេលចំនួន៩០០នាទីនៅក្នុងកម្មវិធីព័ត៌មានរបស់ខ្លួនចំពោះរដ្ឋាភិបាលទេ បើប្រៀបធៀបនឹងគណបក្សប្រឆាំង បានទទួលតែ ៤នាទីប៉ុណ្ណោះ ។ ទង្វើរបស់ក្រុមហ៊ុនទូរទស្សន៍ឯកជនរឹតតែអាក្រក់ណាស់ទៅទៀត ដោយស្ទើរតែគ្មានឱកាសផ្តល់ទៅអោយគណបក្សផ្សេងដើម្បីបង្ហាញទស្សនៈត្រឹមត្រូវរបស់ពួកគេ ក្រៅតែពីគណបក្សប្រជាជនកម្ពុជាប៉ុណ្ណោះ ។

ក្នុងចំណោមស្ថានីយវិទ្យុ ដែលបានត្រួតពិនិត្យតាមដានដោយ EU EOM គ្រប់វិទ្យុទាំងអស់បានចំណាយពេលភាគច្រើនបំផុតទៅលើគណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាល ។ ស្ថានីយវិទ្យុរដ្ឋ **វ.ជ.ក** បានចំណាយពេលបួនម៉ោងក្នុងមួយថ្ងៃចំពោះគណបក្សទាំងអស់ដែលចូលរួមក្នុងការបោះឆ្នោត ប៉ុន្តែផ្តោតកម្មវិធីព័ត៌មានរបស់ខ្លួនទៅលើការរួមចំណែករបស់

រដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាចំពោះប្រទេសជាតិក្នុងទំនោរវិជ្ជមាន ។ តុល្យភាពប្រសើរជាងនេះ ធ្វើឡើងដោយវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា អេហ្វអឹម១០២ និងវិទ្យុសម្បុកឃ្មុំ អេហ្វអឹម១០៥ ដែលបានផ្សាយឡើងវិញនូវវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) និងវិទ្យុអាស៊ីសេរី (RFA) ។ ការផ្សាយរិះគន់រដ្ឋាភិបាលខ្លះៗ មាននៅក្នុងវិទ្យុ VOA និង RFA ទោះជាយ៉ាងណាក៏ដោយ ការផ្សាយរបស់វិទ្យុទាំងពីរនេះ គ្រប់ដណ្តប់គណបក្សទាំងអស់ មានលក្ខណៈអព្យាក្រឹតជាចម្បង ។

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃនាំមុខគេបីនៅកម្ពុជាគឺ ***រស្មីកម្ពុជា កម្ពុជាថ្មី*** និង ***កោះសន្តិភាព*** បានចំណាយការផ្សាយយ៉ាងច្រើនអំពីគណបក្សប្រជាជនកម្ពុជា ជារឿយៗ ក្នុងទំនោរវិជ្ជមាន ។ ចំណែកសារព័ត៌មាន***មនសិការខ្មែរ*** និង ***សំឡេងយុវជនខ្មែរ*** បានគាំទ្រដោយចំហចំពោះ គណបក្សសមរង្ស៊ី និង គណបក្សនរោត្តមរណឫទ្ធិ ដោយបានបោះពុម្ពផ្សាយអត្ថបទ និងមតិរិះគន់យ៉ាងខ្លាំងអំពីគណបក្សកាន់អំណាច ។

## ១០. ការចូលរួមរបស់សង្គមស៊ីវិល

ការចូលរួមរបស់អង្គការសង្គមស៊ីវិល និងអ្នកសង្កេតការណ៍ដែលមានការអនុញ្ញាតមួយចំនួនធំ គឺជាលក្ខណៈវិជ្ជមានរបស់ការបោះឆ្នោតឆ្នាំ២០០៨ ។ **ច.ប.ត.រ** បានកំណត់អោយមានការសង្កេតការណ៍ដោយអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ។ អង្គការសង្គមស៊ីវិលកម្ពុជាសរុបចំនួន ៧២ ត្រូវបានអនុញ្ញាតធ្វើជាអ្នកសង្កេតការណ៍ក្នុងស្រុកដោយ **គ.ជ.ប** ។ ក្នុងចំណោមអង្គការទាំងនោះ គេបានចុះឈ្មោះអោយអ្នកសង្កេតការណ៍សរុបចំនួន ៣១.២៦២នាក់ សម្រាប់ថ្ងៃបោះឆ្នោត ។ មានបណ្តាញអ្នកសង្កេតការបោះឆ្នោតក្នុងស្រុកជាប្រពៃណីសំខាន់ចំនួនពីរ ពោលគឺ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (**ខុមហ្វ្រែល**) និងគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (**និចហ្វិច**) បានជ្រើសរើស និងដាក់ពង្រាយអ្នកសង្កេតការណ៍បោះឆ្នោតរយៈពេលយូរជាច្រើនរូប ដែលជាផ្នែកសំខាន់មួយនៃវិធីសាស្ត្រសង្កេតការណ៍បោះឆ្នោតគួរអោយទុកចិត្តបាន ។ អង្គការទាំងពីរនេះ ក៏បានចូលរួមធ្វើសវនកម្មការចុះឈ្មោះអ្នកបោះឆ្នោតរៀបចំឡើងដោយអង្គការ NDI ផងដែរ ។ លទ្ធផលនៃសវនកម្មនេះ ផ្តល់ទិន្នន័យដែលពាក់ព័ន្ធតែមួយគត់ទាក់ទងនឹងគុណភាពនៃដំណើរការចុះឈ្មោះអ្នកបោះឆ្នោត ។

**ខុមហ្វ្រែល** បានដាក់ពង្រាយអ្នកសង្កេតការណ៍រយៈពេលយូរ ចំនួន២០០នាក់ និងអ្នកសង្កេតការណ៍នៅថ្ងៃបោះឆ្នោតមានចំនួនច្រើនបំផុត[៦៩] ។ អង្គការនេះបានបង្ហាញរបាយការណ៍បោះឆ្នោតប្រកបដោយគុណភាពមួយចំនួនទាក់ទងនឹងដំណាក់កាលផ្សេងៗនៃដំណើការរៀបចំការបោះឆ្នោត ។ ដោយមានការគាំទ្រពី NDI, **ខុមហ្វ្រែល** ក៏បានធ្វើការបូកសរុបសន្លឹកឆ្នោតស្របគ្នា (parallel vote tabulation-PVT)[៧០] ផ្អែកតាមសំណាកលទ្ធផលពីស្ថានីយបោះឆ្នោតចំនួន១.៣១៩ ស្ថានីយ ដែលមានឥទ្ធិពលជាវិជ្ជមានទៅលើតម្លាភាពនៃការបោះឆ្នោត ។

---

[៦៩] អ្នកសង្កេតការណ៍ EU EOM ដែលបានដាក់ពង្រាយនៅតាមខេត្តក្រុងទាំង២៤ បានជួបអ្នកសង្កេតការណ៍ **ខុមហ្វ្រែល** នៅតាមស្ថានីយបោះឆ្នោត ដែលខ្លួនបានទៅសង្កេតការណ៍ចំនួន៥០% នៅថ្ងៃបោះឆ្នោត ។ ភាគរយនេះតំណាងអោយអ្នកសង្កេតការណ៍ជាង ៧.៥០០នាក់ ។ ចំនួនអាចខ្ពស់ជាងនេះឆ្ងាយ ដោយសារ **ខុមហ្វ្រែល** បានសម្រេចចិត្តដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួន ជាសំខាន់នៅតាមបណ្តាខេត្តដែលមានអាសនៈលើសពីមួយនៅក្នុងរដ្ឋសភា ។

[៧០] PVT គឺជាវិធីសាស្ត្រសង្កេតការណ៍បោះឆ្នោត ដែលគេប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់ដោយឯករាជ្យនូវលទ្ធផលបោះឆ្នោត ដែលរួមមានការបូកសរុបដោយឯករាជ្យនូវលទ្ធផលតាមស្ថានីយបោះឆ្នោតផ្លូវការ ស្របជាមួយអាជ្ញាធររៀបចំការបោះឆ្នោត ។

អង្គការ **និចហ្វិច** ដែលជាបណ្តាញអ្នកសង្កេតការណ៍បោះឆ្នោតធំជាងគេលំដាប់ទីពីរ បានជ្រើសរើសអ្នកសង្កេតការណ៍រយៈពេលយូរចំនួន១៨៥នាក់ ដែលបានសង្កេតការណ៍បោះឆ្នោតនៅគ្រប់ខេត្តក្រុងទាំងអស់នៅកម្ពុជា ។ **និចហ្វិច** ក៏បានបង្ហាញការសង្កេតការណ៍ផ្អែកតាមសំណាក (sample based observation-SBO) របស់ខ្លួន លើសំណាកនៃការសង្កេតការណ៍នៅតាមស្ថានីយបោះឆ្នោតចំនួន ៤០០ ស្ថានីយ ផងដែរ ។.

ទាំង **ខុមហ្វ្រែល** និង **និចហ្វិច** បានជួបប្រទះបញ្ហាក្នុងការជ្រើសរើសអ្នកសង្កេតការណ៍ស្ម័គ្រចិត្តរបស់ខ្លួន ដោយសារកង្វះធនធានហិរញ្ញវត្ថុ ។ ទោះជាយ៉ាងណាក៏ដោយ អង្គការទាំងពីរនេះ បានអះអាងថា ខ្លួនមានចំនួនអ្នកសង្កេតការណ៍នៅថ្ងៃបោះឆ្នោត តាមការគ្រោងទុក[៧១] ។

អង្គការដទៃទៀតមួយចំនួនធំ ក៏ត្រូវបានអនុញ្ញាតអោយសង្កេតការណ៍នៅថ្ងៃបោះឆ្នោតដែរ ។ ក្នុងចំណោមអង្គការទាំងនោះ បណ្តាញដែលធំបំផុត គឺ សហព័ន្ធនិស្សិត និងបញ្ញវន្តប្រជាធិបតេយ្យកម្ពុជា (Cambodian Democratic Students and Intellectuals Federation-CDSIF)[៧២] ដែលបានអនុញ្ញាតអោយមានអ្នកសង្កេតការណ៍ចំនួនប្រហែលជា ១.៧០០នាក់នៅថ្ងៃបោះឆ្នោត ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន អង្គការនេះ បានបង្ហាញការវាយតម្លៃជាវិជ្ជមានចំពោះការបោះឆ្នោតដោយពុំមាននិយាយលម្អិតខ្លាំងអំពីដំណើរការរៀបចំការបោះឆ្នោតឡើយ ។

## ១១. ការចូលរួមរបស់ស្ត្រី

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា CEDAW នៅឆ្នាំ១៩៧៩ ។ ដូចនៅក្នុងបណ្តាប្រទេសជាច្រើនដទៃទៀតដែរតាមប្រវត្តិសាស្ត្រ ស្ត្រីកម្ពុជា ពុំមានតំណាងគ្រប់គ្រាន់នៅក្នុងមុខងារនយោបាយ និងរដ្ឋបាលឡើយ ។ ទោះបីស្ត្រីមានចំនួនពី៦០-៦៤ ភាគរយនៃប្រជាជនខ្មែរនៅក្រោយរបបខ្មែរក្រហមនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ក៏ដោយ ក៏កិច្ចប្រឹងប្រែងនានាដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងដំណើរការបោះឆ្នោត និងការគ្រប់គ្រងជាតិ មិនបាននាំអោយមានផ្លែផ្កាតាមការរំពឹងទុកឡើយ ។ មុនពេលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០២ គេបានពិភាក្សាអំពីកូតា៣០ភាគរយសម្រាប់ស្ត្រី ប៉ុន្តែត្រូវគណបក្សនយោបាយនានាបានបដិសេធ ។ កូតាមានគុណសម្បត្តិមួយចំនួន ដូចតទៅនេះ : កូតាធានាអោយមានអាសនៈសម្រាប់ស្រី ហេតុដូច្នេះហើយកូតាបង្កើនចំនួនស្ត្រីឈរឈ្មោះ និងចំនួនស្ត្រីដែលត្រូវបានបោះឆ្នោតអោយចូលបម្រើការងារ ។ កូតាមានបំណងបង្កើនសមត្ថភាពស្ត្រី ក្នុងនាមជាអ្នកធ្វើការសម្រេចចិត្ត ហើយបង្កើនកិច្ចប្រឹងប្រែងរបស់ថ្នាក់ដឹកនាំគណបក្សនយោបាយអោយទាក់ទាញ និងជំរុញការចូលរួមរបស់ស្ត្រី ។ នៅឆ្នាំ២០០៣ មានស្ត្រីចំនួន២២នាក់ (១៧,៨%) ត្រូវបានបោះឆ្នោតអោយចូលបម្រើការក្នុងរដ្ឋសភា ដែលចំនួននេះពុំធ្លាប់មានឡើយពីមុនមក ។ ចំណុចនេះផ្តល់ជាមូលដ្ឋានដ៏ប្រសើរសម្រាប់បង្កើនការចូលរួមរបស់ស្ត្រី ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ការបោះឆ្នោតឆ្នាំ២០០៨នេះ គណបក្សនយោបាយបានជ្រើសតាំងស្ត្រីតែចំនួន ១៧២នាក់ ប៉ុណ្ណោះអោយធ្វើជាបេក្ខជនឈរឈ្មោះពេញសិទ្ធិ ដែលចំនួននេះតំណាងអោយតួលេខ

---

[៧១] **ខុមហ្វ្រែល** មានគម្រោងជ្រើសរើស និងដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន១០.០០០នាក់ និង **និចហ្វិច** ចំនួន ៧.០០០នាក់ ។ អ្នកសង្កេតការណ៍ **និចហ្វិច** មានវត្តមាននៅតាមស្ថានីយតែ ៣,៣ភាគរយ នៃស្ថានីយដែលអ្នកសង្កេតការណ៍ EU EOM បានទៅដល់ប៉ុណ្ណោះ ។

[៧២] អ្នកសង្កេតាការណ៍ CDSIF មានវត្តមាននៅតាមស្ថានីយបោះឆ្នោត ៦,២% ដែលអ្នកសង្កេតការណ៍ EU EOM បានទៅដល់ ។

១៨.៨% នៃចំនួនបេក្ខជនឈរឈ្មោះពេញសិទ្ធិសរុបទាំងអស់ ដ៏គួរអោយខកចិត្ត ។ លទ្ធផលនៃការបោះឆ្នោតបង្ហាញថា ក្នុងចំណោមបេក្ខនារីទាំងនេះ មានតែស្ត្រីចំនួនតែ ១៩ នាក់ប៉ុណ្ណោះ នឹងបានទទួលអាសនៈ នៅរដ្ឋសភាអាណត្តិទីបួន ។

មានបេក្ខនារី និងអ្នកនយោបាយជាស្ត្រីមួយចំនួនបានជម្រាបអ្នកសង្កេតការណ៍ EU អំពីការរើសអើងដែលពួកគេបានទទួលរង នៅក្នុងអំឡុងដំណើរការជ្រើសតាំងបេក្ខជន-បេក្ខនារី និងនៅក្នុងការបោះឆ្នោតជ្រើសរើសផ្ទៃក្នុងរបស់គណបក្សនយោបាយ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកនយោបាយជាបុរសអះអាងថា ខ្លួនមានការលំបាកក្នុងការលើកទឹកចិត្តអោយស្ត្រីចូលប្រឡូកក្នុងជីវភាពនយោបាយ ។ ប៉ុន្តែគួរធ្វើការកត់សម្គាល់ថា អ្នកនយោបាយជាស្ត្រី ពុំមានវត្តមាននៅកិច្ចប្រជុំណាមួយ ដែលអ្នកសង្កេតការណ៍ EU បានរៀបចំឡើងជាមួយអ្នកដឹកនាំគណបក្សនយោបាយ និងតំណាងជាន់ខ្ពស់នៅថ្នាក់ជាតិ មុនថ្ងៃបោះឆ្នោតឡើយ ។

យោងតាម **គ.ជ.ប** ស្ត្រីមានចំនួន ៥៣.៥២ ភាគរយនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះបោះឆ្នោត ហើយអ្នកសង្កេតការណ៍ បានឯកភាពថា មានស្ត្រីជាច្រើនបានចេញទៅបោះឆ្នោត ។ ទោះបីជាចំនួន៣៧ភាគរយនៃបុគ្គលិកបោះឆ្នោតនៅតាមស្ថានីយបោះឆ្នោតដែលអ្នកសង្កេតការណ៍ EU បានទៅដល់នៅថ្ងៃបោះឆ្នោត ជាស្ត្រី ក៏ដោយ ជាទូទៅ ស្ត្រីមានតំណាងមិនគ្រប់គ្រាន់នៅក្នុងរដ្ឋបាលរៀបចំការបោះឆ្នោតឡើយ ។ ជាឧទាហរណ៍ មានស្ត្រីតែពីរនាក់ប៉ុណ្ណោះ ដែលបម្រើការនៅក្នុង **គ.ជ.ប** ក្នុងចំណោមសមាជិកគណៈកម្មការរៀបចំការបោះឆ្នោត សរុប៩នាក់ ហើយបុគ្គលិក **គ.ជ.ប** តែ១៩ភាគរយប៉ុណ្ណោះ ក្នុងចំណោមបុគ្គលិក **គ.ជ.ប** ទាំងអស់ ជាស្ត្រី ។ លំនាំនេះបានកើតឡើងដូចគ្នាដែរនៅក្នុងថ្នាក់គ្រប់គ្រង **គ.ខ/ក.ប** និង **គ.ឃ/ស.ប** ។ ជាងនេះទៅទៀត ស្ត្រីកម្របានកាន់តំណែងដែលមានអំណាចធ្វើការសម្រេចចិត្តណាស់ នៅក្នុងការងាររៀបចំការបោះឆ្នោត ប៉ុន្តែបែរជាកាន់មុខតំណែងរដ្ឋបាលកម្រិតទាបជាងនេះទៅវិញ ។ អ្នកសង្កេតការណ៍ក្នុងស្រុកស្ទើរតែមួយភាគបីដែលបានទទួលការអនុញ្ញាតអោយបំពេញការងារជាស្ត្រី ដោយឡែកប្រមាណជា ២០ភាគរយនៃភ្នាក់ងារគណបក្សដែលបានទទួលការអនុញ្ញាតអោយបំពេញការងារជាស្ត្រី ។

## ១២. ការចូលរួមរបស់ជនជាតិភាគតិច

ប្រទេសកម្ពុជាបានចូលជាសមាជិកគណៈកម្មាធិការដើម្បីការលុបបំបាត់អំពើប្រកាន់ពូជសាសន៍ CERD នៅឆ្នាំ ១៩៦៦ ហើយក្នុងនាមជារដ្ឋសមាជិកអង្គការសហប្រជាជាតិ គួរប្រព្រឹត្តអោយស្របនឹងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិជនជាតិដើម នៃមហាសន្និបាតអង្គការសហប្រជាជាតិ[៧៣] ។ ប្រជាពលរដ្ឋកម្ពុជាជាង៩០ភាគរយជាជនជាតិខ្មែរ ចំណែកចំនួនដែលនៅសល់ប៉ុន្មាន ត្រូវបែងចែកក្នុងចំណោមក្រុមជាតិពន្ធ ចិន វៀតណាម ចាម (អ៊ីស្លាមបរិស័ទ) និងជនជាតិដើម១៧ក្រុមទៀត ដែលរស់នៅតាមតំបន់ដាច់ស្រយាល ភាគច្រើននៅតាមតំបន់ភ្នំនៃភូមិភាគឦសាន ។ ក្នុងចំណោមជនជាតិខ្មែរ ជនជាតិខ្មែរក្រោមដែលមានដើមកំណើតពីអតីតដែនដីកម្ពុជា ដែលបច្ចុប្បន្នស្ថិតនៅក្នុងតំបន់សណ្តទន្លេមេគង្គប្រទេសវៀតណាមនោះ ក៏បង្កើតបានជាក្រុមដោយឡែកមួយផងដែរ ។

[៧៣] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គកាសហប្រជាជាតិ A/61/L.67 ត្រូវបានអនុម័តទទួលយកនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧ ។

ហេតុផលជាចម្បងដែលនាំអោយមានភាពជាតំណាងទាបរបស់ក្រុមជនជាតិភាគតិច នៅក្នុងជីវភាពនយោបាយកម្ពុជា គឺបណ្តាលមកពីការអប់រំទាបនៅក្នុងចំណោមក្រុមទាំងនេះ ពោលគឺតិចតួចបំផុតនៅក្នុងចំណោមក្រុមជនជាតិដើម និងសហគមន៍ខ្មែរក្រោម ដែលមានអាត្រាអនក្ខរភាព អាចខ្ពស់ដល់ទៅ ៩០ភាគរយ ចំណែកឯស្ថានភាពសង្គមមានលក្ខណៈធ្ងន់ធ្ងរ ។ ជាងនេះទៅទៀត ការដែលជនជាតិដើមរស់នៅតាមតំបន់ដាច់ស្រយាលនៃប្រទេស ក៏នាំអោយពួកគេស្ថិតក្នុងស្ថានភាពកាន់តែចាញ់ប្រៀប ដោយសារពុំសូវមានលទ្ធភាពទទួលបានព័ត៌មាន ។ កត្តាទាំងនេះហើយ ដែលនាំអោយតួលេខចុះឈ្មោះអ្នកបោះឆ្នោត មានកម្រិតក្រោមមធ្យមភាគ ក្នុងចំណោមក្រុមជនជាតិភាគតិច ។ ទោះបីជាជនជាតិចិន ត្រូវបានទទួលយកជារួម នៅក្នុងសង្គមកម្ពុជា ក៏ដោយ ក៏ជនជាតិវៀតណាម ជួនកាល គឺជាមុខសញ្ញានៃភាពអមិត្ត ដោយមានជនជាតិខ្មែរខ្លះមើលឃើញពួកគេជាការគំរាមកំហែងចំពោះអធិបតេយ្យ និងវប្បធម៌ជាតិរបស់ប្រទេសកម្ពុជា ។ ជាផ្នែកមួយនៃសារឃោសនារកសំឡេងឆ្នោតរបស់ខ្លួន មានគណបក្សប្រឆាំងខ្លះ បានអំពាវនាវអោយមានការស៊ើបអង្កេតយ៉ាងម៉ត់ចត់អំពីការបញ្ជូលអន្តោប្រវេសន៍ ដែលជាយុទ្ធសាស្ត្រអាចត្រូវមើលឃើញថា ជាការធ្វើមូលធនភាវូនីយកម្មនយោបាយលើមតិប្រឆាំងនឹងជនជាតិវៀតណាម[៧៤] ។ អ្នកសង្កេតការណ៍ EU បានទទួលរបាយការណ៍អំពី "ការចេញអត្តសញ្ញាណប័ណ្ណខុសច្បាប់ និងការចុះឈ្មោះខុសច្បាប់" អោយជនអន្តោប្រវេសន៍វៀតណាម ដែលមិនមែនជាពលរដ្ឋកម្ពុជា តែគេមិនអាចកំណត់បានថា នេះជាករណីជាក់ស្តែង ឬយ៉ាងណាឡើយ ។

ទោះបីជាគ្មានឧបសគ្គផ្លូវច្បាប់ ចំពោះការចូលរួមក្នុងដំណើរការបោះឆ្នោតពីសំណាក់ជនជាតិភាគតិចរបស់ប្រទេសនេះក៏ដោយ ផ្ទុយទៅវិញក៏គ្មានកូតាជាស្រេចដើម្បីធានាអោយភាពជាតំណាងរបស់ក្រុមទាំងនេះឡើយ ។ នៅក្នុងការបោះឆ្នោតកន្លងមក ក្រុមជនជាតិភាគតិចមានតំណាងនៅក្នុងកម្រិតនយោបាយថ្នាក់ជាតិ ។ សមាជិកសភា១១នាក់នៃរដ្ឋសភាដែលផុតអាណត្តិ គឺមកពីក្រុមជនជាតិភាគតិចរបស់ប្រទេសនេះ ក្នុងនោះមានជនជាតិចាមពីររូប និងតំណាងជនជាតិដើមពីររូបទៀត ។ អ្នកនយោបាយដែលមានសាវតារជាជនជាតិភាគតិច ព្យាយាមលាក់លៀមអត្តសញ្ញាណរបស់ខ្លួន ហើយមិនត្រូវបានគេមើលឃើញជាសំឡេងដែលនិយាយការពារសិទ្ធិ និងសេរីភាពរបស់ក្រុមជនជាតិភាគតិចឡើយ ។ នេះមិនមែនជាវិឱ្យនភាពល្អសម្រាប់លទ្ធិប្រជាធិបតេយ្យពហុបក្សនៅកម្ពុជាទេ ដូច្នេះហើយ គួរតែមានការពិភាក្សា និងពិចារណាអំពីការកំណត់កូតាសម្រាប់ក្រុមដែលខ្វះខាតតំណាងភាគច្រើន ។

## ១៣. ថ្ងៃបោះឆ្នោត

### ក. ការបោះឆ្នោត

នៅថ្ងៃបោះឆ្នោត EU EOM បានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួន១៣០នាក់ នៅគ្រប់ខេត្តក្រុងទាំង២៤នៅកម្ពុជា ។ អ្នកសង្កេតការណ៍ទាំងនេះបានសង្កេតមើលការបើកស្ថានីយបោះឆ្នោត ការបោះឆ្នោត ការបិទស្ថានីយបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការដឹកជញ្ជូនសម្ភារៈឯកសារបោះឆ្នោតពីស្ថានីយបោះឆ្នោតទៅកាន់ **គឃ/សប** ។ អ្នកសង្កេតការណ៍ EU បានទៅពិនិត្យមើលស្ថានីយបោះឆ្នោតចំនួន ៧១៧ ស្ថានីយ នៅថ្ងៃបោះឆ្នោត ។

[៧៤] មានការអះអាងចំពោះអ្នកសង្កេតការណ៍ EU ថា នេះជាការចាំបាច់សម្រាប់កែលម្អការត្រួតពិនិត្យលការចូលមកក្នុងប្រទេសនេះតាមរយៈការឆ្លងព្រំដែនទ្វេភាគី ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញក៏រកឃើញថា តួលេខក្រៅផ្លូវការដែលបានគណនានោះគឺហួសពីការពិត ។

ជាទូទៅ ការបើកស្ថានីយបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត បានធ្វើឡើងដោយសន្តិវិធី និងមានរបៀបរៀបរយ ។ ស្ថានីយបោះឆ្នោតទាំង ១៥.២៥៥ កន្លែង ត្រូវបើក ហើយការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត បានបញ្ចប់នៅថ្ងៃបោះឆ្នោត ។ ការត្រៀមលក្ខណៈសម្រាប់បើកស្ថានីយបោះឆ្នោត ធ្វើឡើងស្របតាមកាលវិភាគ ដូចបានព្រៀងទុកនៅក្នុងសៀវភៅឯកសារស្តីពីការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ហើយការបើកស្ថានីយបោះឆ្នោតធ្វើឡើងទាន់ពេលវេលា នៅតាមស្ថានីយបោះឆ្នោតទាំងអស់ដែលអ្នកសង្កេតការណ៍ EU បានចុះទៅពិនិត្យ ។ សម្ភារៈឯកសារសំខាន់ៗ ដែលត្រូវការចាំបាច់សម្រាប់រៀបចំការបោះឆ្នោត មានហើយជាស្រេច និងមានវត្តមានបុគ្គលិកស្ថានីយបោះឆ្នោត បន្ថែម របស់ **គ.ជ.ប** ពេញលេញគ្រប់គ្រាន់ ។ គេពុំបានសង្កេតឃើញមានភាពមិនប្រក្រតីធំដុំកំភួនឡើយ ។ ការវាយតម្លៃជារួមអំពីដំណើរការបើកស្ថានីយបោះឆ្នោត គឺស្ថិតក្នុងចន្លោះល្អ និងល្អណាស់ (៩១ភាគរយ) ។

ការបោះឆ្នោតជាទូទៅ ធ្វើឡើងដោយមានសណ្តាប់ធ្នាប់ និងក្នុងបរិយាកាសយ៉ាងស្ងប់ស្ងាត់ និងសន្តិភាព ។ បុគ្គលិកបោះឆ្នោតរបស់ **គ.ជ.ប** បង្ហាញថាមានការប្តេជ្ញាចិត្ត មានប្រសិទ្ធផល ជាទូទៅបានទទួលការបណ្តុះបណ្តាលយ៉ាងល្អ និងបង្ហាញអោយឃើញនូវការយល់ដឹងយ៉ាងច្បាស់អំពីនីតិវិធីផ្សេងៗ ។ តំណាងរបស់ស្ត្រីនៅក្នុងសមាជិកភាពគណៈកម្មការស្ថានីយបោះឆ្នោត (Polling Station Commissions-PSCs) នៅតាមស្ថានីយបោះឆ្នោតនានាដែលបានចុះទៅពិនិត្យ មានលក្ខណៈគួរអោយពេញចិត្ត (៣៧ភាគរយ) បើប្រៀបធៀបនឹងភាគរយដ៏ទាបនៃស្ត្រីដែលបម្រើការជាមន្ត្រីបោះឆ្នោតជាន់ខ្ពស់នៅរដ្ឋបាលរៀបចំការបោះឆ្នោត ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមស្ថានីយដែលបានចុះទៅពិនិត្យ មានស្ថានីយបោះឆ្នោតតែ១៧ភាគរយប៉ុណ្ណោះ មានប្រធានជាស្ត្រី ។

ទោះបីស្ទើរតែគ្មានសម្ភារៈឯកសារឃោសនា ឬសកម្មភាពឃោសនា ត្រូវបានសង្កេតឃើញនៅថ្ងៃបោះឆ្នោតក៏ដោយ ក៏អ្នកសង្កេតការណ៍ EU នៅខេត្តតាកែវ និងខេត្តបន្ទាយមានជ័យ បានរាយការណ៍ពីសកម្មភពឃោនាកើតមាននៅក្រៅស្ថានីយបោះឆ្នោត និងមានមេភូមិ និងជំទប់ភូមិ នៅក្រវែលជុំវិញស្ថានីយបោះឆ្នោតនៅអំឡុងពេលបើកស្ថានីយបោះឆ្នោតផងដែរ ។

តំណាងគណបក្សនយោបាយមានវត្តមាននៅគ្រប់ស្ថានីយបោះឆ្នោតដែលបានចុះទៅពិនិត្យ ភាគច្រើនមកពីគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសមរង្ស៊ី និងមានកម្រិតតិចតួចមកពីគណបក្សនរោត្តមរណឫទ្ធិ និងគណបក្សសិទ្ធិមនុស្ស ។ ទោះជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍ EU បានរាយការណ៍ថា ជាពិសេសនៅតាមសហគមន៍ជនបទ តំណាងគណបក្សនយោបាយជាទូទៅ មិនចេះអក្សរ ពុំបានទទួលការបណ្តុះបណ្តាល ឬព័ត៌មានជាមូលដ្ឋានអំពីភារកិច្ច ឬករណីយកិច្ចរបស់ខ្លួនឡើយ ជួនកាលមិនទាំងអាចហៅឈ្មោះគណបក្សដែលខ្លួនតំណាងអោយនោះបានទៀតផង ។

អ្នកសង្កេតការណ៍ក្នុងស្រុក មានវត្តមាននៅតាមស្ថានីយបោះឆ្នោត ៥៨ភាគរយដែលបានចុះទៅពិនិត្យ ។ **ខុមហ្វ្រែល** គឺជាបណ្តាញធំជាងគេ និងមានអ្នកសង្កេតការណ៍ចំនួន៥០ភាគរយនៃស្ថានីយបោះឆ្នោតដែលបានចុះទៅពិនិត្យ ។

គេបានសង្កេតឃើញភាពមិនប្រក្រតីមួយចំនួនតូច ទាក់ទងនឹងការអនុវត្តនីតិវិធីរៀបចំការបោះឆ្នោត នៅតាមស្ថានីយ ដែលបានចុះទៅពិនិត្យ ។ ស្ថានីយ៤១,៥ភាគរយដែលបានចុះទៅពិនិត្យ សមាជិកបុគ្គលិកស្ថានីយបោះឆ្នោតមិនបានពិនិត្យមើលម្រាមដៃអ្នកបោះឆ្នោត ដើម្បីពិនិត្យមើលទឹកខ្មៅដែលលុបមិនច្រាស បើទោះជាការជ្រលក់ម្រាមដៃអ្នកបោះឆ្នោតនឹងទឹកខ្មៅ ត្រូវបានអនុវត្តស៊ីសង្វាក់គ្នា នៅគ្រប់ស្ថានីយបោះឆ្នោតទាំងអស់ក៏ដោយ ។ ភាពមិនប្រក្រតី ផ្នែកនីតិវិធីផ្សេងទៀត

ដូចជា ហិបឆ្នោតមិនត្រូវបានបិទអោយបានត្រឹមត្រូវ និងមានការអនុញ្ញាតអោយមនុស្សបោះឆ្នោតដោយគ្មានអត្តសញ្ញាណត្រឹមត្រូវ ក៏ត្រូវបានរាយការណ៍ដោយអ្នកសង្កេតការណ៍ EU ថា បានកើតមានមួយចំនួនតូចផងដែរ នៅតាមស្ថានីយដែលបានចុះទៅពិនិត្យ ។ ជារួម អ្នកសង្កេតការណ៍ EU បានវាយតម្លៃការអនុវត្តការងាររបស់បុគ្គលិករៀបចំការបោះឆ្នោតថាមានលក្ខណៈល្អ ឬ ល្អណាស់ នៅតាមស្ថានីយបោះឆ្នោត ៩២ភាគរយដែលបានចុះទៅពិនិត្យ ។

បញ្ហាចម្បងដែលបានកើតមានឡើងនៅថ្ងៃបោះឆ្នោត គឺមានអ្នកបោះឆ្នោតជាច្រើន ដែលឈ្មោះរបស់ពួកគេត្រូវបានគេលុបចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬឃើញគេគូសសម្គាល់ថាបានបោះឆ្នោតរួចហើយនៅលើបញ្ជីបោះឆ្នោត និងអ្នកបោះឆ្នោតដែលមិនអាចរកស្ថានីយបោះឆ្នោតរបស់ខ្លួនឃើញ ។ បញ្ហានេះត្រូវបានសង្កេតឃើញមាននៅតាមស្ថានីយចំនួន ១៩.៤ភាគរយ ដែលបានចុះទៅពិនិត្យ ។ អ្នកសង្កេតការណ៍ EU បានកត់សម្គាល់ឃើញថា មានអ្នកបោះឆ្នោតជាច្រើនបានរអ៊ូរទាំថា ខ្លួនមិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬមិនអាចរកស្ថានីយបោះឆ្នោតឃើញ ។ ស្ថានីយបោះឆ្នោតទាំងនេះ ភាគច្រើនប្រមូលផ្តុំនៅខេត្តកំពង់ចាម និងខេត្តកំពង់ស្ពឺ ព្រមទាំងក្រុងភ្នំពេញផងដែរ ។

ចំនួនចង្អុលបង្ហាញពីអ្នកបោះឆ្នោតដែលរងគ្រោះដោយសារបញ្ហាទាំងនេះ មានផ្តល់ជូនដោយអង្គការ **និចហ្វិច** នៅក្នុងលទ្ធផលនៃការសង្កេតផ្អែកលើសំណាករបស់ខ្លួន[៧៥] ។ អ្នកសង្កេតការណ៍អង្គការ **និចហ្វិច** បានរាយការណ៍ថា នៅតាមស្ថានីយបោះឆ្នោតចំនួនមួយភាគបួន (២៤.៩ភាគរយ) មានជាង៥ករណី ដែលអ្នកបោះឆ្នោតមានឯកសារអត្តសញ្ញាណត្រឹមត្រូវ ប៉ុន្តែមិនអាចរកឈ្មោះរបស់ខ្លួនឃើញនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ បើគិតតាមស្ថានីយបោះឆ្នោតជាមធ្យម អ្នកបោះឆ្នោតចំនួន៥នាក់ តំណាងអោយ១ភាគរយនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ។ របកគំហើញរបស់អ្នកសង្កេតការណ៍ទាំងនោះ អាចបកស្រាយបានថា ក្នុងចំណោមបីភាគបួននៃស្ថានីយបោះឆ្នោត មានអ្នកបោះឆ្នោតដែលត្រូវបដិសេធមិនអោយបោះឆ្នោត តិចជាងមួយភាគរយ ។

ភាពមិនប្រក្រតីមិនសូវជាទូលំទូលាយ ប៉ុន្តែមានភាពធំដុំដែលរកឃើញ និងរាយការណ៍ជាចម្បងដោយគណបក្សនយោបាយនោះ គឺការចេញដោយខុសច្បាប់នូវឯកសារសម្គាល់អត្តសញ្ញាណ[៧៦] ឬហៅថា ទម្រង់១០១៨ ។

## ខ. ការរាប់សន្លឹកឆ្នោត

គេបានធ្វើការសង្កេតការបិទ និងការរាប់សន្លឹកឆ្នោតនៅតាមស្ថានីយបោះឆ្នោតចំនួន ៥៧ ស្ថានីយ ។ ស្ថានីយបោះ-ឆ្នោតទាំងអស់ដែលបានធ្វើការសង្កេត បានបិទនៅម៉ោង១៥:00 ហើយគ្មានអ្នកបោះឆ្នោតឈរតម្រង់ជួររង់ចាំបោះឆ្នោតទេ ។ ការបិទស្ថានីយបោះឆ្នោតនេះ ធ្វើឡើងក្នុងបរិយាកាសស្ងៀមស្ងាត់ និងសន្តិភាព ។ តំណាងគណបក្ស មានវត្តមានពេលបិទ

[៧៥] របកគំហើញរបស់អង្គការ **និចហ្វិច** គឺផ្អែកតាមកការសង្កេតផ្អែកតាមសំណាកនៅតាមស្ថានីយបោះឆ្នោតចំនួន៣៧៤ នៅគ្រប់ខេត្តក្រុង ។ ក្នុងចំណោម២៤.៩ភាគរយនៃស្ថានីយបោះឆ្នោតដែលអ្នកបោះឆ្នោតរកឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតមិនឃើញ អង្គការ **និចហ្វិច** មិនបានប្រមូលចំនួនអ្នកបោះឆ្នោតពិតប្រាកដដែលទទួលរងគ្រោះទេ ។

[៧៦] ទោះបីជាគណបក្សនយោបាយប្រឆាំងបានចោទប្រកាន់ថា ឃុំបានចេញឯកសារបញ្ជាក់អត្តសញ្ញាណក្នុងចំនួនយ៉ាងច្រើនក៏ដោយ ក៏អង្គការ **ខុមហ្វ្រែល** បានរាយការណ៍នៅឯសន្និសិទ្ធសារព័ត៌មានរបស់ខ្លួន អំពីឧទាហរណ៍តែមួយគត់នៃការចេញទម្រង់១០១៨ ទៅអោយអ្នកបោះឆ្នោត នៅថ្ងៃបោះឆ្នោតនៅខេត្តរតនគិរី ។ អ្នកសង្កេតការណ៍អង្គការ **និចហ្វិច** មិនបានរាយការណ៍អំពីបញ្ហានេះទេ មកទល់ពេលនេះ ។ អ្នកសង្កេតការណ៍ EU EOM បានរាយការណ៍មួយករណីអំពីការចេញទម្រង់១០១៨ ដោយខុសច្បាប់ នៅថ្ងៃបោះឆ្នោតនៅខេត្តបន្ទាយមានជ័យ ។

និងរាប់សន្លឹកឆ្នោត នៅតាមស្ថានីយបោះឆ្នោតទាំងអស់ដែលបានចុះទៅពិនិត្យ ហើយអ្នកសង្កេតការណ៍ក្នុងស្រុក មានវត្តមាននៅតាមស្ថានីយបោះឆ្នោត៧៧ភាគរយដែលបានចុះទៅពិនិត្យ ។ នីតិវិធីបិទស្ថានីយបោះឆ្នោត ត្រូវបានអនុវត្តត្រឹមត្រូវ ដោយមានភាពមិនប្រក្រតីតូចតាចមួយចំនួន ទាក់ទងនឹងដំណាក់កាលផ្ទៀងផ្ទាត់សន្លឹកឆ្នោត ។ ការរាប់សន្លឹកឆ្នោតចាប់ផ្តើមឡើងភ្លាម ហើយគេពុំបានសង្កេតឃើញមានករណីរំខាន ឬការគំរាមកំហែងអ្វីឡើយ ។ ទោះបីជានៅតាមស្ថានីយបោះឆ្នោតនានាដែលបានសង្កេត នីតិវិធីរាប់សន្លឹកឆ្នោតត្រូវបានគោរពជាទូទៅ និងត្រូវបានអនុវត្តតាមនីតិវិធីក៏ដោយ នៅតាមស្ថានីយបោះឆ្នោត១១ភាគរយ ចំនួនសរុបនៃឈ្មោះអ្នកបោះឆ្នោត ដែលបានគូសសម្គាល់នៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត មិនស្មើគ្នានឹងចំនួនសន្លឹកឆ្នោតនៅក្នុងហិបឆ្នោតឡើយ ។ ដោយមិនគិតពីការភ្លាំងភ្លាត់ផ្នែកនីតិវិធីនោះ ការវាយតម្លៃជារួមរបស់អ្នកសង្កេតការណ៍ EU អំពីដំណើរការបិទស្ថានីយ និងរាប់សន្លឹកឆ្នោត គឺមានលក្ខណៈល្អ និងល្អណាស់ ក្នុងកម្រិត៨៤ភាគរយក្នុងចំណោមស្ថានីយបោះឆ្នោតដែលបានចុះទៅពិនិត្យ ។

ក្នុងចំណោម៩១ភាគរយនៃស្ថានីយបោះឆ្នោត ដែលបានសង្កេត មានវត្តមានតំណាងគណបក្សប្រឆាំង ហើយមានតែស្ថានីយបោះឆ្នោត២ភាគរយប៉ុណ្ណោះ ដែលតំណាងទាំងនេះ បានប្តឹងតវ៉ាប្រឆាំងនឹងដំណើរការរាប់សន្លឹកឆ្នោត ។ ក្នុងចំណោម១០ភាគរយនៃស្ថានីយបោះឆ្នោត មានការមិនឯកភាពគ្នាទាក់ទងនឹងសន្លឹកឆ្នោតមិនបានការ និងនៅស្ថានីយបោះឆ្នោតចំនួនបីសន្លឹកឆ្នោតមិនបានការ មិនត្រូវបានកំណត់តាមនីតិវិធីឡើយ ។ ក្នុងចំណោម៩៦ភាគរយនៃស្ថានីយបោះឆ្នោតដែលបានសង្កេតតំណាងគណបក្ស បានទទួលច្បាប់ចម្លងទម្រង់ ១១០៤ ហើយបើទោះបីក្នុងចំណោម៤៦ភាគរយនៃច្បាប់ចម្លងឯកសារមុខការមិនត្រូវបានបិទផ្សាយនៅក្រៅស្ថានីយបោះឆ្នោតក៏ដោយ ភាពមិនប្រក្រតីនេះ ត្រូវបានវាយតម្លៃថា ជាកំហុសអចេតនារបស់សមាជិកគណកម្មការរាប់សន្លឹកឆ្នោត (Ballot Counting Commission-BCC) ។

## គ. ការប្រមូល និងការបូកសរុបលទ្ធផល

អ្នកសង្កេតការណ៍ EU បានសង្កេតមើលការបញ្ជូន និងការប្រមូលទម្រង់លទ្ធផលបោះឆ្នោត (ថ្ងៃបោះឆ្នោត-e-day) និងការបូកសរុបលទ្ធផលបោះឆ្នោត (e-day+1) នៅតាមគណកម្មឃុំ/សង្កាត់រៀបចំការបោះឆ្នោត (**គឃ/សប**) ចំនួន ៤៩ ។ ការវាយតម្លៃជារួមរបស់ពួកគេ មានលក្ខណៈវិជ្ជមានតិចជាងដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ ការបញ្ជូនឯកសារ និងការប្រមូលលទ្ធផលបោះឆ្នោត (e-day) ត្រូវបានវាយតម្លៃក្នុងកម្រិត ៥៩ភាគរយ គឺមានលក្ខណៈល្អ ឬល្អណាស់ ហើយការបូកសុរបលទ្ធផល (e-day +1) មានកម្រិត ៧៧ ភាគរយ មានលក្ខណៈ ល្អ ឬល្អណាស់ ទោះជាយ៉ាងណាក៏ដោយ ពុំមានរបាយការណ៍អំពីភាពមិនប្រក្រតីជាដុំកំភួនឡើយ ។ ក្នុងករណីជាច្រើន បរិវេណ **គឃ/សប** មានការរៀបចំមិនបានល្អ និងមានការខ្វះខាត (ខ្វះទីកន្លែង ជួនកាលអ៊ូរអរខ្លាំងពេក) ដើម្បីបន្តដំណើរការទទួលឯកសារ និងបូកសរុបលទ្ធផល ។ ការប្រមូលឯកសារមកវិញ ក្នុងករណីខ្លះ ពុំមានសណ្តាប់ធ្នាប់ និងខ្វះតម្លាភាព ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ **គឃ/សប** បានផ្តល់លទ្ធផលដែលទទួលបានភ្លាមទៅអោយ **គខ/កប** ផងដែរ ។ ដំណើការនៃការប្រមូលលទ្ធផលក្រៅផ្លូវការដែលផ្អែកតាមលទ្ធផលលើទម្រង់១១០៤ តាមស្ថានីយបោះឆ្នោតចាប់ផ្តើមឡើងភ្លាម ទម្រង់នេះត្រូវបានបំពេញនៅកម្រិតស្ថានីយបោះឆ្នោត រួចហើយបញ្ជូនទៅអោយ **គឃ/សប** ។

ទោះបី **គ.ជ.ប** បានចាប់ផ្តើមរៀបចំទម្រង់លទ្ធផលសម្រាប់ការប្រកាសលទ្ធផលបឋមក្រៅផ្លូវការហើយក៏ដោយ ក៏ដំណើរការបញ្ជូន ពិនិត្យ និងបូកសរុបលទ្ធផល ផ្អែកតាមឯកសារ និងទម្រង់ទាំងឡាយមកពីស្ថានីយបោះឆ្នោត កំពុងតែបានដំណើរការនៅឡើយនៅ **គឃ/សប** ។ **គឃ/សប** បានបញ្ចប់ការបូកសរុបលទ្ធផលមកពីស្ថានីយបោះឆ្នោត នៅថ្ងៃទី២៩ ខែកក្កដា ។ ដំណើរការបូកសរុបលទ្ធផលនៅថ្នាក់ឃុំ ត្រូវបានវាយតម្លៃថា មានលក្ខណៈវិជ្ជមានតិចជាង[៧៧] ដំណើរការរាប់សន្លឹកឆ្នោត ដោយអ្នកសង្កេតការណ៍ EU ប៉ុន្តែ ក៏គ្មានរបាយការណ៍អំពីភាពមិនប្រក្រតីធំដុំឡើយ ។ ជារួម សមាជិក **គឃ/សប** មិនបានបង្ហាញអោយឃើញថា មានកម្រិតចំណេះដឹង និងការយល់ដឹងដែលគេចង់បានអំពីនីតិវិធីនោះទេ ។ នេះសបញ្ជាក់អោយឃើញថា មានកង្វះខាតមួយចំនួននៅក្នុងការបណ្តុះបណ្តាលដែលពួកគេបានទទួល និងអះអាងអំពីសញ្ញាណយ៉ាងរឹងមាំ នៅអំឡុងពេលដំណើរការរៀបចំការបោះឆ្នោត អំពីភាពខ្សោយផ្នែកធនធានមនុស្សរបស់ **គឃ/សប** ។

វត្តមានរបស់តំណាងគណបក្ស មានកម្រិតទាបជាងខ្លាំង បើប្រៀបធៀបនឹងវត្តមានរបស់ពួកគេនៅកម្រិតស្ថានីយបោះឆ្នោត ។ អ្នកសង្កេតការណ៍ EU បានសង្កេតឃើញមានតំណាងគណបក្សនៅតាម **គឃ/សប** តែ២៩ភាគរយប៉ុណ្ណោះ ហើយស្ទើរតែគ្មានអ្នកសង្កេតការណ៍ក្នុងស្រុក មានវត្តមានសង្កេតមើលដំណើរការបុកសរុបលទ្ធផលនៅថ្នាក់ឃុំឡើយ ។

## ១៤. លទ្ធផលនៃការបោះឆ្នោត

### ក. ការប្រកាសលទ្ធផល

លទ្ធផលក្រៅផ្លូវការមួយផ្នែក ត្រូវប្រកាសដោយទូរទស្សន៍ **ទ.ទ.ក** នៅយប់ថ្ងៃបោះឆ្នោត ។ នៅថ្ងៃបន្ទាប់ **គ.ជ.ប** បានប្រកាសលទ្ធផលបឋមក្រៅផ្លូវការ ផ្អែកតាមទម្រង់លទ្ធផលពីស្ថានីយបោះឆ្នោតទាំងអស់ (១០០%) ។ នៅថ្ងៃដដែលនោះដែរ លទ្ធផលក្រៅផ្លូវការតាមខេត្តនីមួយៗ ត្រូវបានចុះផ្សាយតាមវ៉ែបសាយត៍របស់ **គ.ជ.ប** ។

ក្រោយពីការបូកសរុបនៅថ្នាក់ **គឃ/សប** គណៈកម្មាការខេត្ត/ក្រុងរៀបចំការបោះឆ្នោត (**គខ/កប**) បានត្រួតពិនិត្យឡើងវិញ និងបូកសរុបលទ្ធផលដែលទទួលបានពី **គឃ/សប** សម្រាប់ខេត្តរបស់គេរៀងៗខ្លួន ។ យោងតាមកាលវិភាគបោះឆ្នោតចេញដោយ **គ.ជ.ប** ការបូកសរុបលទ្ធផលបោះឆ្នោត ត្រូវបញ្ចប់នៅថ្នាក់ខេត្ត នៅថ្ងៃទី០៣ ខែសីហា ហើយលទ្ធផលបឋមផ្លូវការសរុប ត្រូវប្រកាសអោយដឹងនៅថ្ងៃទី០៩ ខែសីហា ។

### ខ. ទស្សនៈនយោបាយអំពីលទ្ធផលនៃការបោះឆ្នោត

យោងតាមលទ្ធផលបឋមផ្លូវការប្រកាសដោយ **គ.ជ.ប** នៅថ្ងៃទី០៩ ខែសីហា អ្នកចេញទៅបោះឆ្នោត មានចំនួន ៧១ភាគរយ បង្ហាញថាមានការថយចុះយ៉ាងខ្លាំង បើប្រៀបធៀបទៅនឹងការចេញទៅបោះឆ្នោតនៅឆ្នាំ២០០៣ មានចំនួន ៨១.៥ ភាគរយ ។ គណបក្សប្រជាជនកម្ពុជា បានលេចមុខជាអ្នកឈ្នះយ៉ាងច្បាស់លាស់ ដោយបានទទួលសំឡេងឆ្នោតប្រមាណជា ៥៨ ភាគរយ ហើយ គណបក្សសមរង្ស៊ី បានក្លាយជាគណបក្សប្រឆាំងយ៉ាងច្បាស់ ដោយបានទទួលសំឡេងឆ្នោតប្រមាណជា ២១.៩ភាគរយ ។ គណបក្សសិទ្ធិមនុស្ស បានទាក់ទាញសំឡេងឆ្នោតបាន ៦.៦១ ភាគរយ ចំណែកឯគណបក្ស

[៧៧] ក្នុងចំណោម **គឃ/សប** ចំនួន៤៨ ដែលបានសង្កេត ដំណើរការបូកសរុបលទ្ធផលត្រូវបានវាយតម្លៃមានលក្ខណៈ ល្អ ឬ ល្អណាស់ ក្នុងកម្រិត ៧៤.៩ ភាគរយ មធ្យម ១៨.៨ភាគរយ និងអន់ ៦.៣ភាគរយ ។

នរោត្តមរណឫទ្ធិ បានទទួលសំឡេង ៥,៦២ ភាគរយ និងគណបក្សហ៊្វុនស៊ិនប៉ិច ៥,០៥ភាគរយ ។ ក្នុងចំណោមគណបក្សតូចៗ ៦ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ធ្វើបានល្អជាងគេ ដោយបានទទួលសំឡេង ១,១៤ ភាគរយ ។ មានន័យថា គណបក្សចំនួន៥ នឹងមានតំណាងនៅក្នុងរដ្ឋសភាថ្មី ដោយមានការបែងចែកជាអាសនៈដូចតទៅនេះ : គណបក្សប្រជាជន : ៩០ គណបក្សសមរង្ស៊ី : ២៦ គណបក្សសិទ្ធិមនុស្ស : ៣ គណបក្សនរោត្តមរណឫទ្ធិ : ២ និង គណបក្សហ៊្វុនស៊ិនប៉ិច : ២ ។

នៅតាមមណ្ឌលបោះឆ្នោតជនបទដែលមានអាសនៈតែមួយ ចំនួន៩ គណបក្សប្រជាជនឈ្នះទាំងអស់ ចំណែកគណបក្សសមរង្ស៊ី បានទទួលអាសនៈថ្មីនៅមណ្ឌលកំពង់ឆ្នាំង និងក្រចេះ ។ នៅរាជធានីភ្នំពេញ គណបក្សប្រជាជនកម្ពុជាឡើងបានបីអាសនៈ ចំណែកគណបក្សសមរង្ស៊ីបាត់បង់មួយអាសនៈ បើប្រៀបធៀបជាមួយឆ្នាំ២០០៣ ។ អ្នកដឹកនាំទាំងអស់របស់គណបក្សប្រកួតប្រជែងគ្នាសំខាន់ទាំង៥ សុទ្ធតែបានជាប់ឆ្នោត ។

លទ្ធផលបោះឆ្នោតនេះ ត្រូវបានជំទាស់ដោយគណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តមរណឫទ្ធិ និងគណបក្សហ៊្វុនស៊ិនប៉ិច នៅក្នុងសេចក្តីថ្លែងការណ៍រួមមួយនៅថ្ងៃបន្ទាប់ពីការបោះឆ្នោត ក្នុងខណៈពេលដែលមានពាក្យចចាមអារាមថា មានអ្នកបោះឆ្នោតជាច្រើនមិនអាចរកឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការអះអាងថា មានការប្រើប្រាស់ច្រើនហួសហេតុនូវទម្រង់ ១០១៨ ។ ទោះជាយ៉ាងណាក៏ដោយ ប៉ុន្មានថ្ងៃក្រោយមកទៀត នៅថ្ងៃ៣១ ខែកក្កដា គណបក្សហ៊្វុនស៊ិនប៉ិច បានប្រកាសថាខ្លួនបានទទួលយកលទ្ធផលនេះហើយនាពេលនេះ ។ គណបក្សបីរួមមាន គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស និងគណបក្សនរោត្តមរណឫទ្ធិ បានចុះហត្ថលេខាលើលិខិតមួយច្បាប់ថ្វាយទៅព្រះមហាក្សត្រ សុំអោយព្រះអង្គធ្វើព្រះរាជអន្តរាគមន៍ ដើម្បីធានាថា ពលរដ្ឋកម្ពុជាទាំងអស់ត្រូវបានធានាសិទ្ធិបោះឆ្នោតដែលទទួលស្គាល់នៅក្នុងរដ្ឋធម្មនុញ្ញ ។ គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស និងគណបក្សនរោត្តមរណឫទ្ធិបានដាក់បណ្តឹងផ្លូវការទៅកាន់ **គ.ជ.ប** ដោយបដិសេធលទ្ធផលផ្លូវការនៃការបោះឆ្នោតជាតិនេះ ។ បណ្តឹងទាំងអស់ត្រូវច្រានចោល ។ នៅថ្ងៃទី១២ ខែសីហា គណបក្សនរោត្តមរណឫទ្ធិបានដកខ្លួនចេញពីសម្ព័ន្ធភាពប្រឆាំង ដោយបញ្ជាក់ថា ខ្លួនបានទទួលយកលទ្ធផលបោះឆ្នោតនេះហើយ ។

## គ. បណ្តឹងតវ៉ាទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត

មានបណ្តឹង៥ ប្រឆាំងនឹងលទ្ធផលបណ្តោះអាសន្នដែលប្រកាសដោយ **គ.ជ.ប** នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨ ។ បណ្តឹងទាំងអស់នេះ ត្រូវច្រានចោលដោយ **គ.ជ.ប** ដោយពុំមានបើកសវនាការឡើយ ។ មានករណីបី ត្រូវបានប្តឹងឧទ្ធរណ៍ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ : ១) សំណើរបស់គណបក្សសមរង្ស៊ី អោយរាប់សន្លឹកឆ្នោតឡើងវិញនៅខេត្តស្វាយរៀង ដែលនៅទីនោះ គណបក្សប្រជាជនកម្ពុជា ឈ្នះអាសនៈសភាទាំង ៥ ។ បណ្តឹងឧទ្ធរណ៍នេះ ផ្អែកទៅលើតួលេខខុសគ្នានៅក្នុងទម្រង់ ១១០៤ (តារាងលទ្ធផលមកពីតាមស្ថានីយបោះឆ្នោត/រាប់សន្លឹកឆ្នោតនីមួយៗ)[៧៨] ដែលទទួលបានដោយភ្នាក់ងារគណបក្សសមរង្ស៊ី និង តារាងលទ្ធផលរាប់សន្លឹកឆ្នោតដែលប្រមូលដោយ **គ.ជ.ប** ។ បណ្តឹងឧទ្ធរណ៍នេះ ដើមឡើយមានបំណងអោយរាប់សន្លឹកឆ្នោតឡើងវិញនៅក្នុងខេត្តស្វាយរៀងទាំងមូល ប៉ុន្តែ ក្រោយមកទៀតបានដាក់កម្រិតការស្នើសុំអោយមានការបោះ-

[៧៨] ទម្រង់ ១១០៤ មានចំនួនសន្លឹកឆ្នោតដែលគណបក្សនយោបាយនីមួយៗ បានទទួលពីស្ថានីយបោះឆ្នោត រៀងៗខ្លួន ។ យោងតាមបទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការបោះឆ្នោតឆ្នាំ២០០៨ ប្រធានស្ថានីយបោះឆ្នោតនីមួយៗ ត្រូវបំពេញទម្រង់ ១១០៤ ក្រោយពីរាប់សន្លឹកឆ្នោត រួចហើយប្រគល់ទម្រង់នេះមួយច្បាប់ទៅអោយគ្រប់គណបក្សនយោបាយនៅថ្ងៃបោះឆ្នោត ។

ឆ្នោតជាថ្មីនៅតាមស្ថានីយចំនួន១៦ ហើយនៅទីបញ្ចប់អោយមានការបោះឆ្នោតឡើងវិញនៅក្នុងស្ថានីយបោះឆ្នោតមួយ ។ ២) សំណើរបស់គណបក្សសមរង្ស៊ីអោយរៀបចំការបោះឆ្នោតឡើងវិញនៅទូទាំងប្រទេស ដែលក្រោយមកទៀតបានកាត់បន្ថយនៅត្រឹមតែបួនខេត្ត ៖ ស្វាយរៀង កំពត ពោធិ៍សាត់ និងកំពង់ចាម ។ យោងតាមគណបក្សប្តឹងឧទ្ធរណ៍ ខេត្តទាំងនេះត្រូវបានជ្រើសរើស ពីព្រោះមានការលួចបន្លំជាច្រើនទាក់ទងនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងទម្រង់ ១០១៨ ដែលអាចធ្វើអោយមានការផ្លាស់ប្តូរលទ្ធផលឆ្នោតនៅទីនោះ[៧៩] ។ ៣) សំណើរបស់គណបក្សសិទ្ធិមនុស្សអោយរៀបចំការបោះឆ្នោតឡើងវិញនៅខេត្តកំពង់ចាម និងកំពង់ស្ពឺ (ផ្អែកលើមូលដ្ឋានដូចគ្នានឹងបណ្តឹងឧទ្ធរណ៍របស់គណបក្សសមរង្ស៊ីដែរ) ។

ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែសីហា ក្រុមប្រឹក្សាធម្មនុញ្ញ បានបើកសវនាការលើបណ្តឹងឧទ្ធរណ៍ទាំងបី ។ សមាជិក៨រូបនៃក្រុមប្រឹក្សាធម្មនុញ្ញបានបង្ហាញវត្តមាន ។ សវនការទាំងនោះមានលក្ខណៈបំពេញតាមទម្រង់ការហួសហេតុ ដោយពុំមានការសាកសួរមួយសំណួរណាសោះឡើយពីសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គ្មានការស្តាប់សាក្សី និងការពិនិត្យ ឬពិភាក្សាអំពីភស្តុតាង បានកើតមានឡើងនៅក្នុងបន្ទប់សវនាការឡើយ ។ សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ហាក់ដូចជាមានការរៀបចំទុកមុនបានយ៉ាងល្អហើយជាស្រេច ។ តាមការយល់ឃើញរបស់អ្នកសង្កេតការណ៍ EU គឺ ទោះបីជាមានភស្តុតាងអ្វីក៏ដោយ ក៏ក្រុមប្រឹក្សាធម្មនុញ្ញ បានធ្វើការសម្រេចចិត្តរបស់ខ្លួនរួចស្រេចបាត់ទៅហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចច្រានចោលបណ្តឹងឧទ្ធរណ៍ទាំងបី ដោយតម្កល់ទុកសេចក្តីសម្រេចរបស់ **គ.ជ.ប** ។ បណ្តឹងឧទ្ធរណ៍ទាំងនេះត្រូវច្រានចោលដោយផ្អែកលើមូលដ្ឋានថា "គ្មានភស្តុតាងគ្រប់គ្រាន់" ឬ "ការសម្រេចរបស់ **គ.ជ.ប** ធ្វើឡើងផ្អែកទៅតាមច្បាប់" ដោយពុំមានផ្តល់សេចក្តីពន្យល់ ឬហេតុផលបន្ថែមឡើយ ។

លទ្ធផលនៃការកាត់ក្តីបណ្តឹងឧទ្ធរណ៍នៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញនេះ ធ្វើអោយមានការព្រួយបារម្ភជាខ្លាំង ។ ប្រសិនបើការចោទប្រកាន់ថា ទម្រង់១១០៤ ត្រូវបានគេកោសលុបនោះ ការរាប់សន្លឹកឆ្នោតឡើងវិញនៅតាមស្ថានីយបោះឆ្នោតមួយចំនួន អាចនឹងបង្កើនតម្លាភាព យ៉ាងពិតប្រាកដ ។ ប៉ុន្តែ ក្រុមប្រឹក្សាធម្មនុញ្ញ បានបដិសេធ មិនបើកមើលឡើងវិញនូវហិបឆ្នោត សូម្បីតែមួយឡើយ ។

គណបក្សសមរង្ស៊ី បានប្រមូលទម្រង់១០១៨ ដែលគេបានចេញដោយក្លែងបន្លំ រួមទាំងសេចក្តីថ្លែងការណ៍របស់មនុស្សដែលជាប់ពាក់ព័ន្ធផងដែរ បានជាង១០០ទម្រង់ ។ ជាឧទាហរណ៍ ក្នុងចំណោមទម្រង់ទាំងនេះ មានទម្រង់មួយត្រូវបានចេញអោយបុរសអាយុ ៨២ឆ្នាំ ប៉ុន្តែ ត្រូវបានបុរសអាយុ២៤ឆ្នាំម្នាក់ ប្រើប្រាស់ដោយគ្មានបញ្ហាអ្វីទាំងអស់នៅថ្ងៃបោះឆ្នោត ។ ជាងនេះទៅទៀត រូបថតនៃទម្រង់នេះ មិនបានបោះត្រាក្រុមប្រឹក្សាឃុំឡើយ ផ្ទុយទៅវិញបែរជាបោះត្រា **គ.ជ.ប** ទៅវិញ ។ គណបក្សសមរង្ស៊ី ក៏បានប្រមូលសេចក្តីថ្លែងការណ៍ដែលមានផ្តិតមេដៃរបស់មនុស្សចំនួនជាង ១៧.០០០ នាក់ ដែលអះអាងថា ពួកគេត្រូវបានបំបាត់សិទ្ធិបោះឆ្នោត ។ ភស្តុតាងទាំងអស់នេះ គួរបានជាហេតុផលសម្រាប់អោយមានការពិនិត្យអោយបានដិតដល់ជាងនេះ ។

[៧៩] អាសនៈបន្ថែមមួយនៅក្នុងរដ្ឋសភា អាចមានសារៈសំខាន់ណាស់សម្រាប់គណបក្សប្រឆាំង ពីព្រោះវាអាចផ្តល់លទ្ធភាពអោយពួកគេអនុវត្តសិទ្ធិមួយចំនួនដូចជា ៖ ការធ្វើញត្តិដកសេចក្តីទុកចិត្ត ព្រមទាំងស្នើអោយនាយករដ្ឋមន្ត្រី ឬសមាជិក គណៈរដ្ឋមន្ត្រីឆ្លើយសំណួរផ្សេងៗ នៅក្នុងរដ្ឋសភាទៀតផង ។

ជារួម ដំណើរការដោះស្រាយបណ្តឹង និងបណ្តឹងឧទ្ធរណ៍បោះឆ្នោត មិនបានដោះស្រាយជាចម្បងលើដំណើរការបោះឆ្នោត អោយបានសមរម្យឡើយ ហើយមិនបានរួមចំណែកដល់ទំនុកចិត្តរបស់អ្នកពាក់ព័ន្ធនឹងការបោះឆ្នោត ចំពោះដំណើរការនេះទេ ។ ការដោះស្រាយបណ្តឹង និងបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងថ្ងៃបោះឆ្នោត ព្រមទាំងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងលទ្ធផលបោះឆ្នោតបណ្តោះអាសន្ន មានកម្រិតមិនដល់បទដ្ឋានអន្តរជាតិឡើយ ពីព្រោះស្ថាប័ននានាមិនបានធ្វើការស៊ើបអង្កេតអោយបានត្រឹមត្រូវអំពីបណ្តឹងទាំងនោះទេ ។ ដូច្នេះហើយ ប្រទេសកម្ពុជា បានរំលោភទំនួលខុសត្រូវរបស់ខ្លួន ក្នុងការធានាអោយមានឧបាស្រ័យប្រកបដោយប្រសិទ្ធភាព[៨០] ។

នៅពេលដែលបណ្តឹងទាក់ទងនឹងការបោះឆ្នោត និងដំណើរការបណ្តឹងឧទ្ធរណ៍ បង្ហាញថាគ្មានប្រសិទ្ធភាព គណបក្សសមរង្ស៊ីបានធ្វើការចោទប្រកាន់អំពីករណីព្រហ្មទណ្ឌចំនួនពីរ ទៅតុលាធម្មតា ប្រឆាំងនឹងចៅសង្កាត់នៅភ្នំពេញ និងមេឃុំនៅបាត់ដំបង ដែលបានចេញទម្រង់ ១០១៨ ក្លែងក្លាយ ដោយរំលោភមាត្រា ៤៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៩២ (ពីបទក្លែងបន្លំឯកសារសាធារណៈ) ។

## ឃ. ផលប៉ះពាល់ផ្នែកនយោបាយនៃលទ្ធផលបោះឆ្នោត

ទោះបីជាគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស មិនអាចផ្តល់ភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការទាមទារអោយមានការរៀបចំការបោះឆ្នោតជាថ្មីក៏ដោយចុះ ក៏ភាពជឿជាក់ទៅលើការបោះឆ្នោតនេះ ប្រហែលជាបន្តនាំអោយមានការមន្ទិលសង្ស័យ ដោយសារមានភាពមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត នៅក្នុងការចុះឈ្មោះអ្នកបោះឆ្នោត និងការអះអាងថាទម្រង់១០១៨ ត្រូវបានគេប្រើប្រាស់ដោយក្លែងបន្លំក្នុងទ្រង់ទ្រាយធំ ។ គណបក្សប្រឆាំងនៅតែរក្សាជំហរថា ការទទួលស្គាល់បណ្តឹងពីបទក្លែងបន្លំ និងការរៀបចំបោះឆ្នោតជាថ្មី នៅតាមមណ្ឌលចំនួនមួយ ឬពីរ អាចមានសារៈសំខាន់ផ្នែកនយោបាយខ្លាំងណាស់ ។ តាមរយៈការបានទទួលអាសនៈមួយបន្ថែមទៀតនៅក្នុងរដ្ឋសភា គណបក្សប្រឆាំង អាចនឹងបានអាសនៈ៣០ ជាចំនួនដែល ត្រូវការចាំបាច់ ដើម្បីធ្វើញត្តិដកសេចក្តីទុកចិត្ត ព្រមទាំងអាចស្នើអោយនាយករដ្ឋមន្ត្រី ឬសមាជិកគណៈរដ្ឋមន្ត្រីមកឆ្លើយសំណួរផ្សេងៗ នៅក្នុងរដ្ឋសភា ។ នៅចុងបញ្ចប់នៃប្រតិបត្តិការរបស់ EU EOM គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានគំរាមធ្វើពហិការមិនចូលប្រជុំសភាដំបូង ដែលនៅអំឡុងពេលនោះ សមាជិកតំណាងរាស្ត្រជាប់ឆ្នោតថ្មី ត្រូវធ្វើសច្ចាប្រណិធានចូលកាន់តំណែង ។ ទោះជាយ៉ាងណាក៏ដោយ ក្រោយមកទៀត គណបក្សទាំងពីរបានបន្ទន់ឥរិយាបថរបស់ខ្លួនចំពោះបញ្ហានេះ ។ គណបក្សប្រជាជនបានប្រឈមមុខនឹងសំណើនេះដោយថ្លែងថា ពហិការបែបនេះ មានន័យស្មើនឹងចេតនាចង់បោះបង់អាសនៈសភារបស់ខ្លួន ហើយក្នុងករណីនេះ បានស្នើអោយមានការបែកចែកអាសនៈទាំង២៩ របស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សក្នុងចំណោមគណបក្សដទៃទៀត ។ យោងតាមវិសោធនកម្មរដ្ឋធមនុញ្ញឆ្នាំ២០០៦ គណបក្សប្រជាជនកម្ពុជា អាចបង្កើតរដ្ឋាភិបាលថ្មី តែម្នាក់ឯងបាន ។ ទោះជាយ៉ាងណាក៏ដោយ គេបានបង្ហាញអោយឃើញថារដ្ឋាភិបាលថ្មីនេះ នឹងត្រូវបន្តបញ្ចូលគណបក្សហ៊្វុនស៊ិនប៉ិចដែលថយចុះអាសនៈសំឡេងយ៉ាងច្រើន ព្រមទាំងគណបក្សនរោត្តម

[៨០] បទដ្ឋានអន្តរជាតិ : សិទ្ធិទទួលបានឧបាស្រ័យប្រកបដោយប្រសិទ្ធភាព : "រដ្ឋភាគីនីមួយៗ មានករណីយកិច្ច : ធានាថា បុគ្គលគ្រប់រូបដែលសិទ្ធិ និងសេរីភាពរបស់ខ្លួនត្រូវបានរំលោភបំពាន បានទទួលឧបាស្រ័យប្រកបដោយប្រសិទ្ធភាព មិនគិតថា ការរំលោភបំពាននោះ ត្រូវបានប្រព្រឹត្តិដោយបុគ្គល ដែលបំពេញសមត្ថកិច្ចផ្លូវការរបស់ខ្លួន ឬយ៉ាងណានោះទេ" ។ មាត្រា ២ (៣) (ក) និង (គ) នៃ ICCPR ។

រណបឫទ្ធិ ផងដែរ ។ ប៉ុន្តែគណបក្សប្រជាជនកម្ពុជា បានផ្តល់សញ្ញាហើយថា គណបក្សដៃគូតូចៗមិនបាច់រំពឹងចង់បានតំណែងរដ្ឋមន្ត្រីឡើយ ។

## ១៥. អនុសាសន៍

អនុសាសន៍ខាងក្រោមនេះ ធ្វើឡើងដើម្បីជាការរួមចំណែកជួយដល់ការអភិវឌ្ឍ និងការកែលម្អជាបន្ត នូវដំណើរការប្រជាធិបតេយ្យ បោះឆ្នោត និងនយោបាយនៅកម្ពុជា មុនពេលបោះឆ្នោតជ្រើសតាំងសមាជិកសភាអាណត្តិក្រោយ ដែលគ្រោងនឹងធ្វើឡើងនៅឆ្នាំ២០១៣ ។ អនុសាសន៍ទាំងនេះផ្តល់ជូនជាពីរផ្នែក : ផ្នែកចាំបាច់ និងផ្នែកគួរអនុវត្ត ។

### ក. អនុសាសន៍ចាំបាច់

រដ្ឋាភិបាលកម្ពុជា ត្រូវចាត់វិធានការដែលគួរអោយទុកចិត្តបាន ដើម្បីធានាអោយ **គ.ជ.ប** បំពេញការងារ ជាស្ថាប័នឯករាជ្យទាំងស្រុង នៅគ្រប់លំដាប់ថ្នាក់ ដើម្បីបង្កើនភាពជឿជាក់ និងការទទួលយកនូវស្ថាប័ននេះ ក្នុងចំណោមអ្នកបោះឆ្នោត ។ សមាជិករបស់ **គ.ជ.ប** គួរទទួលបានការយល់ព្រមជាឯកច្ឆន្ទ ក្នុងចំណោមគណបក្សនយោបាយនៅក្នុងរដ្ឋសភា ។ ជាពិសេសប្រធាន **គ.ជ.ប** គួរតែជាបុគ្គលដែលអាចទទួលយកបានចំពោះគណបក្សនយោបាយទាំងអស់ នៅក្នុងរដ្ឋសភា ។ គួរពិចារណាការកំណត់អាណត្តិរបស់តំណែងប្រធាន និងសមាជិករបស់ **គ.ជ.ប** ។

ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ជាពិសេសគោលការណ៍ណែនាំ និងនីតិវិធីរបស់**គ.ជ.ប** គួរអោយមានលក្ខណៈសាមញ្ញ និងដាក់បញ្ចូលគ្នា ដើម្បីលុបបំបាត់ភាពមិនស៊ីសង្វាក់គ្នា ភាពមិនច្បាស់លាស់ ចំណុចមិនចាំបាច់ និងភាពខ្វះចន្លោះ ។ សេចក្តីណែនាំធ្វើឡើងដោយ **គ.ជ.ប** គួរតែអាចបញ្ចូលនៅក្នុងបទប្បញ្ញត្តិ និងនីតិវិធី នៃការបោះឆ្នោតអោយបានច្រើនបំផុត ។

ការប្រើប្រាស់ទម្រង់ ១០១៨ គួរលុបបំបាត់ចោល មុនពេលបោះឆ្នោតនៅពេលអនាគត ។

ក្រសួងមហាផ្ទៃ គួរបង្កើនអាត្រាការផ្តល់អត្តសញ្ញាណប័ណ្ណ និងកែលម្អដំណើរការត្រួតពិនិត្យដំណើរការផ្តល់អត្តសញ្ញាណប័ណ្ណនេះ ។ ក្នុងករណីអ្នកបោះឆ្នោតមិនមានអត្តសញ្ញាណប័ណ្ណ ឬឯកសារសម្គាល់អត្តសញ្ញាណដទៃទៀត រដ្ឋអំណាចគួរស្វែងរកដំណោះស្រាយផ្សេង ដើម្បីផ្តល់លទ្ធភាពអោយអ្នកបោះឆ្នោតសម្គាល់ខ្លួនបាននៅថ្ងៃបោះឆ្នោត ។ ដោយមិនគិតអំពីដំណោះស្រាយនេះ កំណត់ត្រានៃអ្នកបោះឆ្នោតដែលប្រើប្រាស់អត្តសញ្ញាណប័ណ្ណផ្សេង ត្រូវរក្សាទុកជាសម្ងាត់ និងជាព័ត៌មាន ដើម្បីជួយគាំទ្រដល់ការងារបោះឆ្នោតកម្ពុជា ជាបន្ថែមទៀត ។

មេភូមិ មិនត្រូវអនុញ្ញាតអោយបំពេញតួនាទីសំខាន់ ក្នុងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (VIN) ឡើយ ។ **គ.ជ.ប** គួរស្វែងរកមធ្យោបាយផ្សេង ដើម្បីចែកប័ណ្ណនេះ ដែលអាចធ្វើឡើងដោយមានវត្តមានរបស់ភ្នាក់ងារគណបក្ស និងសមាជិក **គឃ/សប** ។

បរិយាកាសផ្សព្វផ្សាយព័ត៌មានសេរី មានសារៈសំខាន់ណាស់ក្នុងការធានាថា កិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងដោះស្រាយបញ្ហាពុករលួយ និងការការពារសិទ្ធិមនុស្សជាមូលដ្ឋាន បានសម្រេចជោគជ័យ ។ រដ្ឋាភិបាលត្រូវបង្ហាញការប្តេជ្ញាចិត្តឆ្ពោះទៅសម្រេចគោលដៅនេះ ដោយបង្កើតអោយមានអាជ្ញាធរគ្រប់គ្រងការផ្សព្វផ្សាយឯករាជ្យមួយ ដែលទទួលខុសត្រូវចំពោះការផ្តល់អាជ្ញាប័ណ្ណ និងរលកអាកាសដល់ប្រព័ន្ធផ្សព្វផ្សាយ ដោយបើកចំហ និងមានតម្លាភាព ។

រដ្ឋាភិបាលកម្ពុជា និង **គ.ជ.ប** គួរចាប់ផ្តើមដំណើរការពិគ្រោះយោបល់អំពីជម្រើសសម្របសម្រួល និងកែលម្អនីតិវិធីចុះឈ្មោះអ្នកបោះឆ្នោត ។ គួរតែមានការចូលរួមជាបន្ថែមរបស់បុគ្គលិក **គ.ជ.ប** នៅអំឡុងពេលធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោត ។ ហេតុផលសម្រាប់ការលុបឈ្មោះអ្នកបោះឆ្នោត ត្រូវរក្សាទុកជាឯកសារអោយបានត្រឹមត្រូវ ។

ស្ថាប័នរដ្ឋាភិបាល រួមទាំង **គ.ជ.ប** និងអង្គការសង្គមស៊ីវិលផងដែរ គួរផ្តល់អាទិភាពដល់គំនិតផ្តួចផ្តើមអប់រំពលរដ្ឋអោយបានទូលំទូលាយ និងមានគោលដៅជាមុន ដោយយកចិត្តទុកដាក់ចំពោះអត្រាអក្ខរកម្មដ៏ទាបនៅកម្ពុជា ។ គំនិតផ្តួចផ្តើមដូចពោលនេះ អាចដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សា ដែលផ្តល់ដោយស្ថាប័នអប់រំសាធារណៈ និងឯកជននៅគ្រប់កម្រិតទាំងអស់ ។

ស្ថាប័នរដ្ឋ រួមមានរដ្ឋាភិបាលដែលកំពុងកាន់តំណែង ផងដែរ ត្រូវខិតខំអោយបានប្រសើរឡើងថែមទៀត ដើម្បីដាក់ទណ្ឌកម្មចំពោះការប្រើប្រាស់ធនធានរបស់រដ្ឋសម្រាប់បម្រើគោលបំណងឃោសនារកសំឡេងឆ្នោត ។ នៅតាមផ្នែកនីមួយៗរបស់រដ្ឋាភិបាល គួរធ្វើការប្រកាសជាសាធារណៈ អំពីចំនួនបុគ្គលិក ដែលបានទទួលការអនុញ្ញាតអោយឈប់សម្រាកពិសេសសម្រាប់យុទ្ធនាការឃោសនារកសំឡេងឆ្នោត ហើយការប្រើប្រាស់ធនធានរបស់រដ្ឋសម្រាប់ឃោសនារកសំឡេងឆ្នោត ត្រូវតែទទួលការផ្តន្ទាទោស ។

កាលកំណត់សម្រាប់ដាក់ និងដោះស្រាយពាក្យបណ្តឹង គួរធ្វើការកែសម្រួលឡើងវិញ ។ និយាយដោយឡែកកាលកំណត់សម្រាប់ការដាក់ពាក្យបណ្តឹងនៅថ្នាក់ **គឃ/សប** នៅអំឡុងពេលយុទ្ធនាឃោសនារកសំឡេងឆ្នោត (៣ថ្ងៃ) ព្រមទាំងកាលកំណត់សម្រាប់ការដាក់ពាក្យបណ្តឹងជំទាស់នឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត (ម៉ោង ១១:៣០ ព្រឹកនៅថ្ងៃ បន្ទាប់ពីការបោះឆ្នោត) មានរយៈពេលខ្លីពេក និងគួរធ្វើការពន្យាពេល ។ ជាងនេះទៅទៀត កាលកំណត់រយៈពេល ៤៨ម៉ោង សម្រាប់អោយ **គ.ជ.ប** ធ្វើការសម្រេចពាក្យបណ្តឹងជំទាស់នឹងលទ្ធផលបោះឆ្នោត មិនអាចអនុញ្ញាតអោយ **គ.ជ.ប** ធ្វើការ ស៊ើបអង្កេតអោយបានហ្មត់ចត់ឡើយ ។

យុត្តាធិការជាទូទៅរបស់ **គ.ជ.ប** ក្នុងការដោះស្រាយពាក្យបណ្តឹងគ្រប់ប្រភេទ ទាក់ទងនឹងដំណើរការរៀបចំការបោះឆ្នោត គួរតែថែង (ឡើងវិញ) អោយបានច្បាស់លាស់ ។ ពីព្រោះការបែងចែកតាមផ្នែកនូវនីតិវិធីបណ្តឹង បច្ចុប្បន្ននេះ ជំពូក១១ នៃ **ច.ប.ត.រ** និងបទប្បញ្ញត្តិ និងនីតិវិធីដែលពាក់ព័ន្ធ ខកខានមិនបានដោះស្រាយភាពមិនប្រក្រតីធ្ងន់ធ្ងរបំផុតដែលយើងបានសង្កេតឃើញនៅថ្ងៃបោះឆ្នោតទេ (ឧទាហរណ៍ ការចេញឯកសារបោះឆ្នោតក្លែងបន្លំ ដោយមន្ត្រីរដ្ឋបាលមូលដ្ឋាន) ។

